សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា

# KhmerPost USA

E-mail: info@khmerpost.us / Website : khmerpost.us
Advertising: 978-656-8141/ Hotline news: 978-942-1641


**Free**

មាតិការរឿង **Issue 173 Mar. 23rd. - 6th April**


១-"ប្រេសគ្លីប"ជាអ្វី?....................................០៣
២-ដំណើរពីអាមេរិកទៅអាស៊ី (ភាគបញ្ចប់)...........០៤
៣-សញ្ញាប័រប្បធម៌នៃជនជាតិ អៀវឡង់...............០៥
៤-បូជនីយស្ថាននៅសាលាក្រុងឡូវែល...................០៧
៥-អ្នកសល់ពីរាលពិឃាតខ្មែរមកជួប......................១០
៦-ក្រុមសិល្បៈ"ព្រះរាជាណាចក្រកម្ពុជា"...............១១
៧-ទឹកដីកម្ពុជាក្រោម និងប្រទេសចំប៉ា..................១២
៨-ព្រឹត្តិការណ៍សំខាន់ៗនៅខាងអ៊ីសានប្រទេសថៃ.........១៧



**Office:** Tel: (978) 677-7163 Fax: (978) 677-7092
45 Merrimack St. Suite 218A Lowell, MA 01852


## ព្រះអង្គម្ចាស់ធម្មិកោ : សង្គ្រោះជាតិមានយុទ្ធសាស្ត្រ ដើម្បីដឹកនាំប្រទេស

**ដោយ ស្គាយ បុណ្យ**

ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ ធ្លាប់ជាប្រធាននៃគណបក្សហ៊្វុនស៊ិនប៉ិចកាលជាង២០ឆ្នាំមុន ឥឡូវជាសមាជិកជាន់ខ្ពស់នៃគណបក្សសង្គ្រោះជាតិ។ **តទៅទំព័រទី ០៥**



## លោកស្រី មីស្សែល អូបាម៉ា បំពេញទស្សនកិច្ចនៅកម្ពុជា ដើម្បីជួយលើកស្ទួយការអប់រំសិស្សស្រី

**ដោយ : ស្គាយ បុណ្យ**

លោកស្រី មីស្សែល អូបាម៉ា ភរិយាលោកប្រធានាធិបតីអាមេរិក បារ៉ាក់ អូបាម៉ា ធ្វើដំណើរទៅកាន់ខេត្តសៀមរាប **តទៅទំព័រទី ១៩**



លោកជំទាវ ប៊ុនរ៉ានី ហ៊ុន សែន, ឯ.ឧ វីលៀមថដ ទទួលជំទាវ [illegible] ស្សែល អូបាម៉ា
ពេលចុះពីយន្តហោះពិ[illegible]


## ការិយាល័យច្បាប់ រ៉ូសា និង តាំង



Francisco J. Rosa, Esq.
មេធាវី ហ្វ្រង់ ស៊ីស្កូ ជេ.រ៉ូសា



Andrew 'Bunna' Taing, Esq.
មេធាវី អែន ឌ្រូវ៉ប៊ុណ្ណា តាំង

Law Office of
**Rosa & Taing**
ATTORNEY AT LAW

| SERVICES | តំណាងក្តីដូចខាងក្រោម |
|---|---|
| Auto Accidents/ Personal Injury | គ្រោះថ្នាក់រថយន្ត/ របួសរូបរាងកាយ |
| Bankruptcy | ក្ស័យធន |
| Immigration | អន្តោប្រវេសន៍ |
| Consumer Protection | ការពារអតិថិជន |
| Real Estate Closings/Disputes | ទំនាស់ផ្នែកអចលនវត្ថុ |
| Divorces Child Custody | លែងលះ និងអាណាព្យាបាលកិច្ច |

1550 Middlesex Street Lowell, MA 01851
Phone: **978-458-0934** | help@attorneyrosa.com
www.attorneyrosa.com





# សេចក្តីអញ្ជើញរបស់ក្លឹបសារព័ត៌មាន
# PRESS CLUB INVITATION

Dear Friends, Community Members and Leaders:

Please join us on Thursday, April 9, 2015 from noon until 2 pm at Lowell Telecommunications, 246 Market St in Lowell, for the next KhmerPost USA PRESS CLUB event.

The first portion of this PRESS CLUB will review and discuss the proposal to install a Cambodian monument on Lowell City Hall Plaza.The second part of the meeting will continue the discussion began at previous PRESS CLUBS between Cambodian business owners and city officials about the challenges faced by these businesses and about how city government can assist.

PRESS CLUB provides a valuable opportunity for the Cambodian community and government officials in Lowell to learn more about the challenges each face and to improve overall communications. Because the KhmerPost USA publishes articles about what is discussed at these meetings, the information is shared with the entire Cambodian community. Please consider joining us on April 9th. Lunch will be served.

Sincerely Yours,

Soben Pin

Soben Pin, Managing Partner
KhmerPost USA, LLC,
45 Merrimack St. Ste. 218A

សមាជិក,អ្នកដឹកនាំ ព្រមទាំងមិត្តទាំងអស់ ជាទីរាប់អាន

សូមអញ្ជើញចូលរួម"ប្រេសក្លឹប"ជាមួយយើងខ្ញុំ នៅថ្ងៃព្រហស្បតិ៍ ទី៩ មេសា ឆ្នាំ២០១៥, វេលាម៉ោង២រសៀល នៅអាសយដ្ឋាន : LTC 246 Market St in Lowell

ក្នុងភាគដំបូងនៃ"ប្រេងសក្លឹប" និងធ្វើការពិភាក្សាគំរោងសាងរូបវិមាន ដែលត្រូវសង់ឡើងនៅទីលានមុខសាលាក្រុងឡូវែល ។ ក្នុងភាគទី២ និងលើកយកបញ្ហាអាជីវកម្មដែលបានធ្វើការពិភាក្សាក្នុង"ប្រេសក្លឹប"គ្រាកន្លងមក រវាងអាជីវកម្មខ្មែរ និងមន្ត្រីរដ្ឋបាល, ថា: តើមានអ្វីដែលរដ្ឋបាលក្រុងអាច និងជួយបានទៀត ។

ក្លឹបសារព័តិមានឬ"ប្រេសក្លឹប" ផ្តល់ឱកាសដល់សហគមន៍ខ្មែរ និងរដ្ឋបាល ក្រុងឡូវែល ធ្វើបទសិក្សារាល់ជ្រុងជ្រោយ ដើម្បីរកភាពចម្រើន សម្រាប់សហគមន៍ធ្វើការវិវឌ្ឍទៅមុខ ។ កាសែតខ្មែរផុស និងលើកមកចុះផ្សាយនូវអត្ថន័យក្នុងកិច្ចពិភាក្សា "ប្រេសក្លឹប" នេះ, ផ្សព្វផ្សាយទូទាំងសហគមន៍ខ្មែរឱ្យបានដឹង ។

ហេតុនេះសូមអញ្ជើញចូលរួមជាមួយ"ប្រេសក្លឹប"យើងខ្ញុំនៅថ្ងៃទី៩ មេសា,

នឹងមានផ្តល់ជូនអាហារថ្ងៃត្រង់ ។

សូមអរគុណទុកជាមុន!

978-677-7163 (Office) | 978-677-7092 (Fax)www.khmerpostusa.com | www.khmerpost.us

# "ប្រេសក្លឹប" ជាអ្វី?

**ពិន សំខុន**

មានអ្នកអានខ្លះយល់ថា"ប្រេសក្លឹប"ជាព្រឹត្តការណ៍ឯកជន ហើយថា សាធារណជនមិនអាចចូលរួមបានទេ ។ តាមពិតអ្នកកាសែតអាជីព ក៏គេអាចមាន"ក្លឹបអ្នកកាសែត"ជាឯកជនបានដែរ តែ"ប្រេសក្លឹប"ក៏មានន័យ "ប្រមូលព័ត៌មានសាធារណៈដែលអាចជឿបានមកផ្សព្វផ្សាយក្នុងទំព័រអង្គការសារព័ត៌មានដែលមានការទទួលខុសត្រូវ"បានដែរ ។ គឺជាព័ត៌មានដែលមានប្រភពមានហេតុផល គួរយកជាព័ត៌មានសម្រាប់ជាការពិចារណាបានខុសគ្នានឹង"ហ្វេសប៊ុក"ដែលគេអាចបង្កើតព័ត៌មានសំរាប់បំពេរអារម្មណ៍ ដោយពុំចាំបាច់ខ្វល់ខ្វាយពីជំនឿរបស់អ្នកអានក៏បានដែរនោះ។ "ប្រេសក្លឹប" យើងនេះ ជាចំណងដៃ "ខ្មែរផុសស.រ.អា."ជូនសហគមន៍ឡូវែលនេះ ឱ្យខ្មែរគ្រប់រូបក៏មានសម្លេងឮបានខ្លាំងនឹងឆ្ងាយការពារខ្លួនបានដូចសាសន៍ដទៃ មិនថាខ្លួនជាមន្ត្រីជាពាណិជ្ជករ ឬជាអ្នកមានការធ្វើ ឬក៏អត់ការងារធ្វើការងារ មិនថាក្មេង ឬចាស់នោះទេ...គឺជាផ្នែកមួយនៃរបបប្រជាធិបតេយ្យក្នុងការនិយាយស្ដីដោយសេរីនឹងមានទទួលការខុសត្រូវ។

ក្រុងឡូវែលមានបញ្ហាទំនាស់ច្រើន ដែលត្រូវរំដោះដោយមានការពិគ្រោះទៅតាមក្បួននៅក្នុងលទ្ធិប្រជាធិបតេយ្យដែលយើងអនុវត្តរាល់ថ្ងៃ ដើម្បីផ្ដល់ការចុះសម្រុងគ្នាស្របច្បាប់ក្នុងសហគមន៍ ។ ថ្មីៗនេះក្រុងខ្មែរមានបំណងសង់រូបព្រហ្មបាយ័នមួយនៅជ្រុងផ្លូវ"ប្រេន"នឹង"មីឌលសិ" នាតំបន់ផ្សារប៉ៃលិនមតិមួយចំនួនឱទ្ទានថា "ក្រុងខ្មែរជាក្រុងរបស់ទាំងអស់គ្នាត្រូវតែទទួលយោបល់ពីអ្នកទាំងអស់គ្នាដែលជាខ្មែររស់នៅឡូវែលនេះមុននឹងសម្រេចធ្វើអ្វីមួយនៅក្រុងខ្មែរ"ក្រុងខ្មែរបានឱ្យដឹងដែរថា **តទៅទំព័រទី ២០**




# What is Press Club?

**By Pin Samkhon**

"Press Club" is misconstrued by some people as a private event which is closed to the public. It is true that journalists may organize their private Press Club. Nonetheless a Press Club is also for collecting the reliable public sources of information which will eventually be published in a responsible news media. Unlike the information on Facebook, such sources are more reasonably objective.

Our Press Club is a gift from the Khmer Post to the people of Lowell. They, now get their voices heard out loud and meaningfully. Like members of other ethnic groups either they are officials, businesspeople, the employed or the unemployed of all walks of life they have some form of support to rely upon todefend themselves. This Press Club offers them a space to express themselves freely and responsibly. It helps foster a democratic environment.

Several issues in Lowell need to be addressed through a democratic discussion which is conductive to a promising and legitimate solution for the community. Recently Cambodia Town is considering erecting a monument of Taprum on a piece of land located on the corner of Branch Street and Middlesex Street in the region of the Pailin Plaza. Khmer community members argued that since Cambodia Town is for all, it shall not make any final decisions without getting their opinion. However Cambodia Town has made it clear that the decision has been made. **Continued to Page 30**

MIDDLESEX Community College
BEDFORD • LOWELL



LOWELL OPEN HOUSE



**Saturday, MARCH 28 • 9:30 a.m.**

33 Kearney Square • Lowell, MA 01852

Learn more about ...

**FREE Tutoring Services • Placement Testing • Dual Enrollment • Disability Support • Academic, Career & Transfer Counseling**



Middlesex offers 75+ degree & certificate programs, and hundreds of noncredit courses. Earn a degree, begin a bachelor's degree or upgrade your skills.

Everyone teaches, everyone learns.

REGISTER NOW!

To learn more or to RSVP call 1-800-818-3434
or visit: www.middlesex.mass.edu/OH

# ដំណើរពីអាមេរិកទៅអាស៊ី (ភាគ៥បញ្ចប់)

**តពីលេខមុន**

**ដោយ : ពិន សំខុន**

យន្តហោះបានចុះចតនៅព្រលានហុងកុង នាថ្ងៃ១៥ វិច្ឆិកា ២០១៤ ពេលនោះខ្ញុំដឹងថា ទីនេះ



វាខុសពីអ្វីៗដែលយើងបានឃើញពីមុនមកទាំងអស់ គឺយើងឆ្លងពីវប្បធម៌អម្បូរមន-ថៃ នាប្រទេសថៃ មកអម្បូរឥណ្ឌា-មន-ខ្មែរ នាកម្ពុជា ជាបន្តមកទៀតវប្បធម៌នៃអម្បូរខ្មែរក្រោម ឥទ្ធិពលចិន-វៀតណាម ចុងក្រោយនេះគឺវប្បធម៌នៃជនជាតិចិន ក្រោមឥទ្ធិពលនៃវប្បធម៌អង់គ្លេស ។

គេធ្លាប់តែឮជូលផ្ទះ ជួលដី ឥឡូវឮចិនជួលប្រទេសទៀត -ប្រវត្តិ១០០ឆ្នាំនៃចក្រភពអង់គ្លេសមកត្រួតត្រាជាម្ចាស់ទឹកដីលើហុងកុងផ្នែកមួយនៃចិនកុម្មុយនីស្តបានបន្សល់ទុកនូវវប្បធម៌ថ្មីមួយដែលជនជាតិចិន៣-៤ជំនាន់ ត្រូវរស់នៅជាអង់គ្លេស ។ បន្ទាប់ពីជួលហុងកុងចំនួន១០០ឆ្នាំចប់រួចមក នាថ្ងៃទី១ កក្កដាឆ្នាំ១៩៩៧មក ហុងកុងក៏បានត្រឡប់ទៅជាសម្បត្តិនៃប្រទេសចិនវិញ ក៏ប៉ុន្តែតាមអត្ថន័យនៃ-លក្ខន្តិកៈហុងកុងនៅរក្សាគ្រប់គ្រងតាមរបៀបរបបបែបអង់គ្លេសនៃចិនហុងកុងដដែលបន្ត៥០ឆ្នាំទៀត ដោយគ្រាន់តែមានអភិបាលក្រុងថ្មីមកពីរដ្ឋបាលកុម្មុយនិស្តតែម្នាក់ប៉ុណ្ណោះ។ ការគ្រប់គ្រងជាសម្បត្តិ



របស់ចិនប្រជាមានិតហុងកុង គឺជារដ្ឋមានស្វយ័តភាពបរិបូរណ៍ក្នុង"ប្រទេសមួយមានរចនាសម្ព័ន្ធពីរ" ដែលនៅប្រើរដ្ឋធម្មនុញ្ញរបស់ខ្លួនផ្ទាល់នឹងនៅប្រើច្បាប់នៃប្រទេសអង់គ្លេសនៅឡើយ លើកលែងតែផ្នែកកងទ័ពនឹងកិច្ចការនយោបាយបរទេស ទើបស្ថិតនៅជាអំណាចចិនប្រជាមានិត... ដូច្នេះនៅ៥០ឆ្នាំក្រោយមក ទើបចិនកុម្មុយនីស្តអាចផ្លាស់ប្តូររបបបាន។ យើងបានទៅទស្សនាក្រុងចិនមួយនេះ ចំពេលដែលចិនកុម្មុយនិស្តមានបំណងប្តូររបបមុនពេលកំណត់ក៏បង្កើតជាបាតុកម្មដ៏ធំចំបងមួយនៃចិនហុងកុងចំនួនច្រើនថ្ងៃ ដើម្បីទប់ស្កាត់ការប៉ុនប៉ងរបស់រដ្ឋបាលចិនប្រជាមានិតកុម្មុនីស្តនោះ។

ទៅដល់ហុងកុងយើងមានការកក់ក្តៅចំពោះសុវត្ថិភាពទាំងចរាចរទាំងការលួចឆក់ទាំងការតែបន្លំក្លែងក្លាយពាណិជ្ជកម្ម នាទីផ្សារបានច្រើន ដោយដឹងថាទីនោះ មានការគោរពច្បាប់ដ៏ច្បាស់លាស់របស់អជ្ញាធរបន្តរពីជំនាន់មុនដែលយើងធ្លាប់បានស្គាល់ដូចគ្នានឹងនៅអាមេរិកដែរ ។ ខ្ញុំបានឡើងជិះតាក់ស៊ីដែលមានការណែនាំពីប៉ូលីសឱ្យហៅរកពួកគេ ប្រសិនបើមានការមិនប្រក្រតីណាមួយ -តាក់ស៊ីក៏នាំយើងមកដល់គោលដៅយ៉ាងឆាប់រហ័សដែលនៅទីនោះសូបិននឹងប៉ុណ្ណារ៉ូមកដល់សណ្ឋាគារទាន់សម័យដ៏ខ្ពស់មួយមុនមួយថ្ងៃរួចជាស្រេច ។

ហុងកុងសម្បូរទៅដោយផ្ទះខ្ពស់សន្ធឹមណាស់ដោយសារតែខ្វះដី **តទៅទំព័រទី ០៦**


## ដំណឹងលក់អគារពាណិជ្ជកម្ម ដាក់លក់ដោយម្ចាស់ដើម

## MULTI UNITS RETAIL BUILDING

**FOR SALE BY OWNER**

1687 Middlesex St, Lowell, MA 01851

អគារមានទំហំ 4.264 sq ft ដោយ
មានកន្លែងចតរថយន្ត

កន្លែងសម្បូរហាងទំនិញច្រើន នៅតាមផ្លូវ
MIDDLESEX ST
នៅក្នុងទីក្រុងឡូវែលតំបន់ HIGHLAND

សព្វថ្ងៃអគារនេះ ជាទីតាំងសម្រាប់ធ្វើពាណិជ្ជកម្ម មានទ្វារកញ្ចក់ខាងមុខពីរ និងមានពីរជាន់ និងមានកន្លែងចតរថយន្តនៅខាងក្រោយ



1687 Middlesex St, Lowell, MA 01851

Retail Trade Building | 4,264 sqft
with Parking

PRIME BUSINESS LOCATION ON
BUSY MIDDLESEX ST
IN LOWELL, HIGHLAND AREA

CURRENTLY OPERATE AS COMER-
CIAL SPACE
CONSISTS OF 2 STOREFRONTS &
AND SECOND FLOOR
WITH PARKINGS on the rear

GREAT SPACE FOR CONVINIENCE
STORES OR COMMUNITY OFFICE
SPACES

ជាទីតាំងល្អបំផុតសម្រាប់បើកហាងលក់ទំនិញ
ឬកន្លែងការិយាល័យលក់ក្នុងតម្លៃ $499,999

**SELL AS IS AT PRICE $499,999**

សូមទូរស័ព្ទមកកាន់លេខ ៩៧៨-៥៦៩-៦០៦២
ដើម្បីណាត់គ្នាមើលអគារ

**CALL BUN 978-569-6062**
TO MAKE APPOINTMENT FOR SHOWINGS

# សប្តាហ៍វប្បធម៌នៃជនជាតិ អៀរឡង់

**ដោយ រីឆាត ហាវ ជូនៀ**
**ប្រែសម្រួលដោយ ថាច់ វណ្ណា**

ក្នុងឆ្នាំ១៨២២ មានពលករមួយក្រុមធ្វើដំណើរពីក្រុង ឆល្លីថោន ទៅក្រុងឡូវែល រដ្ឋម៉ាសាឆូសីត, ដើម្បីជីកប្រឡាយ និងស្ថាបនារោងចក្រ (Mill)ធ្វើឱ្យក្រុងឡូវែលទៅជាទីក្រុងសំខាន់មួយក្នុងប្រទេសអាមេរិក,ប្រជារាស្ត្រអៀរឡង់រាប់សែននាក់ បានធ្វើដំណើរមកជាបន្តបន្ទាប់, រហូតដល់ពេលដែលប្រជារាស្ត្រខ្មែរបានមកដល់នៅឆ្នាំ១៩៨០, ពេលនោះក្រុមប្រជារាស្ត្រអៀរឡង់ ជាក្រុមមានមនុស្សច្រើនជាងគេក្នុងក្រុងឡូវែល ។

អំឡុង៣២ឆ្នាំកន្លងមក, ប្រជារាស្ត្រអៀរឡង់-អាមេរិកាំងក្រុងឡូវែល បានធ្វើពិធីបុណ្យសប្តាហ៍នៃកេរតំណែលវប្បធម៌ជនជាតិអៀរឡង់នឹងត្រូវបានប្រារព្ធនៅពាក់កណ្តាលខែមីនា, ជាធម្មតាគេចាប់ផ្តើមនៅព្រឹកថ្ងៃអាទិត្យដង្ហែរក្បួនពីវិហារ Patrick's ទៅសាលាក្រុងចំកន្លែងដែលបានតម្លើងទង់ជាតិ អៀរឡង់ បន្ទាប់មក, គេ និងយកកម្រងស្លឹកឈើទៅបំពាក់លើរូបបដិមាករនៅផ្លូវ Cardinal O'Connell Parkway។ មានកម្មវិធីសំខាន់មួយទៀតក្នុងសប្តាហ៍នៅកន្លែង Acre Forum, ឆ្នាំនេះមានកិច្ចពិភាក្សារួមរាល់មុខដំណាងជនជាតិដែលបានរស់នៅក្នុង Acre, ដោយ អៀរឡង់ផ្ទាល់, បារាំង-កាណាដា, ហ្គ្រិក, កូឡុម្ប៊ី បៀន, វៀតណាម, ខ្មែរ និងភូមា, គេ និងលើកយកការដកពិសោធន៍របស់បុព្វបុរស និងបុព្វការីជនរបស់ពួកគេពេលដែលទើប និងបានមក ដល់Acre, កិច្ចពិភាក្សានេះធ្វើឡើង ដើម្បីដោះស្រាយបញ្ហាដូចគ្នាក្នុងក្រុមជនជាតិក្នុងក្រុងឡូវែលប្រសើរជាងទុកបញ្ហាទាំងនោះ ឱ្យនៅទីផ្សេងៗពីគ្នា។

សប្តាវប្បធម៌នៃជនជាតិ អៃរីសហ៍ មានការជប់លៀងពិសេស, ដូតន្ត្រី, ច្រៀង រាំ និងភាពយន្តបញ្ចាំងឱ្យឃើញនៅការវិវឌ្ឍន៍នៃវប្បធម៌, ថ្ងៃបុណ្យ St. Patrick's ១៧ មិនាក៏ជាសប្តាហ៍វប្បធម៌ជនជាតិ អៃរីសដែរ, ហេតុនេះវាជាឱកាសល្អសំរាប់អស់លោកអ្នកក្នុងក្រុងឡូវែល, មិនថា ជាជនជាតិណាមានប្រវត្តិយ៉ាងណា ក៏អាចចូលរួមសប្បាយនៅថ្ងៃបុណ្យកេរតំណែលនៃជនជាតិអៀរឡង់បានដូចគ្នា ៕

# Irish Cultural Week

**By Richard P. Howe Jr. (March 19, 2015)**

In 1822 a group of Irish laborers walked from Charlestown, Massachusetts to Lowell to help dig the canals and build the mills that made Lowell one of the most important cities in America.



Tens of thousands of people from Ireland followed. Until the arrival of the Cambodians in the 1980s, the Irish were the largest ethnic group in Lowell.

For the past 32 years, the Irish-Americans of Lowell celebrate their heritage during Irish Cultural Week which comes in the middle of March. The week always begins on a Sunday morning with a parade from St. Patrick's Church to City Hall where the Irish flag is raised and then a wreath is placed at the Irish monument on Cardinal O'Connell Parkway. Another major event during the week is the Acre Forum which this year included a panel discussion of representatives from the different ethnic groups that have settled in the Acre. Individuals representing the Irish, French-Canadians, Greeks, Columbians, Vietnamese, Cambodians and Burmese all talked about what they or their ancestors experienced when they first arrived in the Acre. The discussion made it clear that there are more similarities between the ethnic groups in Lowell than there are differences.

Irish Cultural Week also features banquets, dancing, music, songs, films, performances and other cultural activities. St. Patrick's Day which is March 17 falls within Irish Cultural Week and provides an additional opportunity for everyone in Lowell regardless of ethnic background to celebrate and enjoy the heritage of the Irish.


វិជ្ជាស្ថានរៀន
ថែសម្ផស្សមុខនិងក្រចក

ទើបបើកថ្មី

Chelmsford Beauty Academy

**60 Chelmsford St.,2nd Floor Chelmsford, MA. 01824**
**Tel: (978)328-9722 ឬ (978) 250-4488**





- យើងខ្ញុំបានបើកវគ្គបង្រៀនធ្វើក្រចក និងថែសម្ផស្សមុខ គ្រូបង្ហាត់ មានការដកពិសោធន៍ច្រើនឆ្នាំ មានថ្នាក់រៀនក្រៅម៉ោង និងពេញម៉ោង្ស៧ថ្ងៃក្នុង១សប្តាហ៍
- យើងខ្ញុំបើកវគ្គសិក្សា៣០០ម៉ោង សម្រាប់ថ្នាក់ថែសម្ផស្សមុខ និងវគ្គ ១០០ម៉ោង
- សម្រាប់ថ្នាក់ធ្វើក្រចក។
- សូមចុះឈ្មោះជាប្រញាប់ !

**ជួយណែនាំរកការងារធ្វើ ពេលចប់ការសិក្សា**

Chelmsford Beauty Academy មានចម្ងាយ៥នាទីពីក្រុង Lowell,
និង១៥នាទីពីក្រុង Lawrence, ចម្ងាយ១០នាទីពី Burlington Mall, និង១០នាទី Andover.

**ព័ត៌មានបន្ថែមទាក់ទងជាមួយយើងខ្ញុំថ្ងៃនេះទូរស័ព្ទលេខ : (978)328-9722** ឬលេខ : **(978)250-4488**

## តមកពីទំព័រទី ០៤ ដំណើរពីអាមេរិកទៅអាស៊ី...

សម្រាប់ពលរដ្ឋដ៏ច្រើនជាងគេក្នុងពិភពលោកសម្រាប់រស់នៅចំនួនពលរដ្ឋដែលរស់នៅក្នុងផ្ទៃក្រឡាមួយគីឡូម៉ែត្រការ៉េមានជាមធ្យមដល់ទៅជាង៨០០០នាក់ឯណោះ ។ ពលរដ្ឋចិនរស់យ៉ាងប្រជ្រៀតគ្នានៅលើដីត្រួតគ្នាជាច្រើនសិបជាន់ត្រួតទៅក្រោមដីច្រើនជាន់បន្ថែមទៀត នៅលើគោកក៏មាននៅក្នុងទឹកលើទូកក៏មានគ្មានចន្លោះដីទំនេរទេ ។ ពីបន្ទប់ដ៏ទូលាយរៀបចំទទួលភ្ញៀវយ៉ាងស្អាតឥតខ្ចោះពីមុខទ្វារកញ្ចក់របស់យើងឆ្ពោះសមុទ្រវែងដាច់កន្ទុយភ្នែកលំអដោយកោះតូចៗជាច្រើន ក៏ប៉ុន្តែនៅចន្លោះកោះទាំងនោះ មាននាវាដឹកទំនិញជាច្រើនសិប រហូតដល់រយទៀតផង ដែលចតឆ្ងាយពីច្រាំងសមុទ្រហុងកុងជាសញ្ញាថា មានការដោះដូរពាណិជ្ជកម្មជាមួយប្រទេសក្រៅយ៉ាងមមាញឹក -នេះគ្រាន់តែនៅពីមុខយើងតែប៉ុណ្ណោះ ចុះនៅតំបន់ផ្សេងៗទៀតជុំវិញកោះ តើទំហំផ្លាស់ប្តូរពាណិជ្ជកម្មអាចនឹងមានរាប់ពាន់នាវាដែរឬទេ សម្រាប់តែថ្ងៃមួយនេះ? តាមពិតទៅហុងកុង គឺជាច្រកទ្វារពាណិជ្ជកម្មដ៏សំខាន់មួយរបស់ចិនកុម្មុយនីស្តសម្រាប់បញ្ចេញទំនិញទៅអឺរ៉ុប អាមេរិក ឬអូស្ត្រាលី តាំងតែពីមុនហុងកុងត្រឡប់ទៅចិនវិញមកម្ល៉េះ ហើយឥឡូវនេះ តាំងតែពីហុងកុងចូលទៅជាចិនតែមួយវិញនោះ ឧស្សាហករណ៍ចិនដីគោកជាច្រើនបានមកវិនិយោគបន្ថែមច្រើនទៀតនៅតំបន់កោះហុងកុងយ៉ាងតក្រើកក្រេង ។

រសៀលនេះ ខ្ញុំមិនបានសម្រាកទេ យើងរៀបខ្លួនចេញទៅរកបាយទឹកនៅកោះមួយនៅទល់មុខហុងកុងនោះ គឺ "កាវលូន" គឺយើងត្រូវជិះតាក់ស៊ី រួចហើយជិះសាឡាង ឆ្លងទៅកាវលូន រកហូបម្ហូបចិននាហាងតូចៗ ដែលសម្បូរម្ហូបដែលយើងជាខ្មែរចូលចិត្ត ដូចជាគុយទាវ មី បាយស្ងោរ ជាដើម ។ នៅតាមផ្លូវហាងលក់ដូរយ៉ាងសម្បូរហូរហៀរ រថយន្តឯកជន តាក់ស៊ី រថយន្តបើស ធ្វើចរាចរបើកខាងឆ្វេង តាមរបៀបអង់គ្លេស រត់ឆ្វាត់ឆ្វែងយ៉ាងលឿនមិនខ្លាចប៉ះគ្នាទេ ។


ភោជនីយដ្ឋានបណ្តែតទឹក ចេមបូ និងកាយប៉ាក់


ទិដ្ឋភាពក្រុងហុងកុង

មនុស្សដើរក៏សម្បូរណាស់ដែរ ហាងនីមួយៗពោរពេញទៅដោយភ្ញៀវមិនមានស្ងាត់ទេ ហុងកុងមិនត្រឹមតែមានមនុស្សច្រើនដូចស្រមោចរស់នៅទេ តែក៏មានទេសចរច្រើនណាស់ដែរ សម្រុកទៅលេងហុងកុងទៅមើលពួកចិនពូកែរកស៊ីណាស់ មើលការតុបតែងជាវប្បធម៌ចិនបូរាណទៅមើលក្រុងដែលប្រព័ន្ធទាក់ទងធំៗ នៃកាសែត ទូរទស្សន៍ ភាពយន្តតាំងទីនៅទីនោះ ទៅភ្លក់រស់ជាតិម្ហូបចម្លែកៗមិនដែលប្រទះ ឬក៏ស្វែងរកទស្សនីយភាពកម្រមានឥតខ្ចោះខាតទាំងអស់នេះហើយដែលធ្វើឱ្យហុងកុងមានភាពរស់រវើកទាំងថ្ងៃក៏ដូចពេលយប់គ្មានសម្រាកបន្តិចណាឡើយ ។ យើងបានថតរូបជារូបថត នឹងជាវីដេអូបានច្រើនសម្រាប់ជាការចងចាំរបស់យើង នឹងសម្រាប់យកមកបង្ហាញចែករំលែកដល់មិត្តភ័ក្តិនូវការរៀនសូត្រទាំងឡាយពីដំណើររបស់យើងផង ។

ស្អែកឡើងយើងស្រស់ស្រូបពេលព្រឹកនៅក្នុងសណ្ឋាគារ រួចហើយទៅមើលគ្រួសារចិនរាប់ម៉ឺននាក់រស់នៅលើទូក រកស៊ីលើទូក នាតំបន់ "អាបើឌីន" ទោះជាបានឃើញហើយក៏ដោយក្តីទីនោះនៅតែជាតំបន់នៃអាថ៌កំបាំងដ៏ជ្រាលជ្រៅដដែល ពីព្រោះយើងនៅតែមិនដឹងថា ពួកគេទាំងអស់គ្នាមានមុខរបរចិញ្ចឹមជីវិតរៀងៗខ្លួន ឬក៏អត់? ធ្វើម្ហូប ដេកពួនក្នុងកន្លែងដ៏តូចតែមួយយ៉ាងដូចម្តេច? ទឹកស្អាត ឬភ្លើងអគ្គីសនីមកដល់របៀបណា? បទដៃបទជើងយ៉ាងម៉េច? សំអាតសំលៀកបំពាក់យ៉ាងណា? ទាំងនេះសុទ្ធតែជាសំណួរដែលគ្មានចម្លើយនៅឡើយ ពីព្រោះតែពេលវេលាស្នាក់អាស្រ័យនៅទីនោះ មានរយៈពេលខ្លីពេក ។ ប៉ុណ្ណារ៉ូ សូបិន នឹងខ្ញុំ យើងបានជិះទូកចិនក្នុងដៃសមុទ្រចិនដែលទឹកនៅថ្លាឆ្វង់នៅឡើយ មួយជុំធំជុំវិញតំបន់ "អាបើឌីន" បន្ទាប់មកក៏នាំគ្នាចូលទៅរកហូបអាហារនៅភោជនីយដ្ឋានបណ្តែតទឹកកណ្តាលសមុទ្រដ៏ធំ ហើយដ៏ល្បីល្បាញមួយដែលម្ខាងមានឈ្មោះថា "ថៃប៉ាក់" ម្ខាងទៀតឈ្មោះ "ជុំបូ" ភោជនីយដ្ឋាននោះ មានរូបរាងដូចជាប្រាសាទនៃស្តេចក្រុងចិនដ៏ធំមានទទួលភ្ញៀវនៅជា៣ជាន់ តាមរបៀបរបបប្រពៃណីចិនបូរាណ ។ ពេលល្ងាចយើងនាំគ្នាជិះរថយន្តឈ្នួល "បើស" ត្រឡប់មកម្តុំកំពង់ចំលង នា "កាវលូន" ដ៏សម្បូរដោយហាងលក់ទំនិញប្រណិតគ្រប់យ៉ាងទស្សនាបណ្តើររកមើលកន្លែងលក់ឥវ៉ាន់ចុះថ្លៃផង តែមិនទាន់រកឃើញនៅឡើយ ។ ប៉ុណ្ណារ៉ូ ថ្វីត្បិតតែនៅក្មេងអាយុ៤ឆ្នាំកន្លះតែរីករាយនឹងដើរតាមយើងជាចាស់ៗគ្មាននឿយហត់នឹងគ្មានរអ៊ូរទាំក្រៅពីទារទិញ "ថយ" ល្បែងក្មេងលេងឥតឈប់ឈរតែប៉ុណ្ណោះ ។

ព្រឹកនៃថ្ងៃថ្មីមួយទៀត យើងមិនបាននៅស្រស់ស្រូបពេលព្រឹកនៅក្នុងសណ្ឋាគារទេ ពីព្រោះប្រញាប់ទៅហូបគុយទាវនៅកណ្តាលក្រុង រួចហើយដើរមើលរបស់របរនៅផ្សារដែលមានលក់របស់របរតម្លៃថោកតែមិនទាន់ពេញចិត្តសុបិននៅឡើយទេ នៅពេលរសៀលយើងឡើងទៅលើកំពូលភ្នំដែលខ្ពស់ជាងគេបង្អស់ឈ្មោះ "ភីក" សម្រាប់មើលមកឃើញក្រុងហុងកុងទាំងមូល ជាពិសេសរង់ចាំមើលទេសភាពដ៏ត្រកាលនៃទីក្រុងហុងកុង នាពេលថ្ងៃលិចចំរុះពន្លឺ៧ពណ៌ធ្វើឱ្យយើងបំភ្លេចផ្ទាំងគំនូរធម្មជាតិនោះមិនបាន ។ ពេលចុះមកវិញ រាត្រីកាលក៏មកដល់ តែសូបិនបានរកឃើញអស័យដ្ឋាននៃទីផ្សារថ្មីមួយទៀត ដែលជាផ្សារចល័តនៅផ្លូវ "ឡេឌី" មានលក់របស់ប្រើប្រាស់នឹងរបស់អនុស្សាវរីយ៍ល្អៗក្នុងតម្លៃថោកៗផង... ម៉ោង១០យប់ទៅហើយគេផ្តើមសារតូបរើឥវ៉ាន់ចូលទុកដាក់យើងក៏ឡើងតាក់ស៊ីត្រឡប់មកសណ្ឋាគារវិញដែរ ដោយគ្រោងថានឹងត្រឡប់ទៅទីនោះវិញ នាថ្ងៃស្អែកម្តងទៀត មុននឹងរៀបឥវ៉ាន់ត្រឡប់មកអាមេរិកវិញ ។

នៅហុងកុង៤ថ្ងៃនោះ យើងមានការរៀនសូត្រច្រើនពីសង្គមចិន-អង់គ្លេស នៅទីនោះ ដែលបង្ហាញថា ចិនមានប្រវត្តិជាអ្នករកស៊ីពូកែរតស៊ូរាប់រកក្រុមគ្រួសាខ្លួនរបានល្អរក្សាវប្បធម៌តពូជអម្បូរចិនក៏មាំទាំមានការកែរទម្រង់វប្បធម៌ចាស់ ហើយគោរពច្បាប់សង្គមនៃជនជាតិប្រទេសខាងលិច គឺស្មើភាពនឹងយុត្តិធម៌ ហេតុដូច្នេះហើយហុងកុងបានក្លាយជាតំបន់នៃ "សំណាងល្អ" **តទៅទំព័រទី ២៥**



# បូជនីយស្ថាននៅសាលាក្រុងឡូវែល



Richard Howe

**ដោយ: Richard P. Howe Jr. (ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៥)**

ខណៈនេះប្រជាជនខ្មែរនៅទីក្រុងឡូវែលកំពុងគ្រោងសង់បូជនីយស្ថានមួយសម្រាប់សហគមន៍នៅទីក្រុងឡូវែល។ ក្នុងការសង់បូជនីយស្ថាននេះជាការល្អ គេគួរមើលគំរូបូជនីយស្ថានរបស់ជនជាតិភាគតិចដទៃទៀត ដែលបានសង់ក្នុងបរិវេណ សាលាក្រុងឡូវែលកន្លងមក។

នៅលើវាលស្មៅខាងមុខសាលាក្រុងឡូវែលមានបូជនីយដ្ឋានពីរ មួយឧទ្ទិសជនជាតិកាណាដាសញ្ជាតិបារាំងដែលបានចូលមករស់នៅទីក្រុងឡូវែល និងមួយទៀតឧទ្ទិសប្រជាជនមកពីប្រទេសប៉ូឡូញ។ បូជនីយស្ថានរបស់បារាំងជាជួងដែលព្យួរលើទម្រថ្មក្រានីត។ នៅលើទម្រថ្មក្រានីតនោះ មានឆ្លាក់អក្សរថា "សូមសម្តែងសេចក្តីគោរពចំពោះពលរដ្ឋបារាំងសញ្ជាតិអាមេរិកនៃទីក្រុងឡូវែល រដ្ឋម៉ាស្សាឈូសេត, ឆ្នាំ១៩៨៤"។ បូជនីយស្ថានរបស់ប៉ូឡូញជាចម្លាក់ថ្មក្រានីតបញ្ឈរមានរាងបួនជ្រុងទ្រវែង មានអក្សរឆ្លាក់ថា "សូមឧទ្ទិសដោយក្តីគោរព ចំពោះជនជាតិប៉ូឡូញសញ្ជាតិអាមេរិកនៃទីក្រុងឡូវែល, ខែឧសភា ឆ្នាំ១៩៧៧"។

នៅចំហៀងសាលាក្រុងសងខាងទូលដែលមានស្មៅដុះនៅចំកណ្តាលសួន Cardinal O'Connell Parkway មានបូជនីយស្ថានជនជាតិភាគតិចពីរផ្សេងទៀត មួយឧទ្ទិសជនជាតិអៀរឡង់ដោយមានចារឹកថា "សូមឧទ្ទិសជនអៀកឡង់សញ្ជាតិអាមេរិកនៃទីក្រុងឡូវែល, ឆ្នាំ១៩២២-ឆ្នាំ១៩៧៧" មួយទៀតឧទ្ទិសជនជាតិក្រិកមានចារឹកថា "កូនចៅជំនាន់ក្រោយ សូមឧទ្ទិសដល់បុព្វការីជនអន្តប្រវេសន៍ក្រិក, ឆ្នាំ១៩៨៣"។

បូជនីយស្ថានសម្រាប់ការឧទ្ទិសស្រដៀងគ្នានេះ មានសង់ពីរបន្ថែមទៀត នៅចំខាងមុខសាលាក្រុង។ បូជនីយស្ថានទីមួយសង់ឧទ្ទិសជនជាតិព័រទុយហ្កាល់ដែលបានមកនៅទីក្រុងឡូវែល។ លើបូជនីយស្ថាននោះ មានចារឹកថា "សូមសម្តែងសេចក្តីគោរពចំពោះកេរតំណែល និងការបរិច្ចាគរបស់សហគមន៍ព័រទុយហ្កាល់សម្រាប់ទីក្រុងឡូវែល, ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៩"។

ឆ្នាំមុននេះមានបូជនីយស្ថានថ្មីក្រោយគេបង្អស់សង់លេចធ្លោជាងគេក្នុងបរិវេណសាលាក្រុង។ សហគមន៍ជនជាតិអាមេរិកជាអ្នកសង់បូជនីយស្ថាននេះឡើង ដោយចារឹកថា "សូមរម្លឹកវិញ្ញាណក្ខន្ធជនរងគ្រោះដោយអំពើប្រល័យពូជសាសន៍អាមេរិក, ឆ្នាំ១៩១៥-ឆ្នាំ១៩២៣")។ អក្សរចារឹកនេះ បានបង្កប់នូវអត្ថន័យបន្ថែមដូចខាងក្រោម:

**ហត្ថាមាតា**

ហត្ថាមាតាកួចចំណង និងត្បាញប្រវត្តិសាស្រ្តកូនចៅគាត់។ ភាពប៉ិនប្រសប់នៃការក្រង និងចាក់ដោយអំបោះបានក្រងជាថ្មរាងខ្វែងមួយផ្ទាំងនេះ ដែលជានិមិត្តរូបនៃសោភ័ណភាព និងភាពរឹងមាំនៃកេរតំណែលជនជាតិអាមេរិក។ វប្បធម៌បុរាណមានជីវិតជារៀងដរាប។ មិនខុសអ្វីពីអនុស្សាវរីយ៍នៃអំពើប្រល័យពូជសាសន៍នាសតវត្សទី២០ ដែលនៅដក់ជាប់ក្នុងការចងចាំនៃជនជាតិអាមេរិកទូទៅ។ បូជនីយស្ថានថ្មរាងខ្វែងមួយផ្ទាំងនេះ ជាការរម្លឹកគ្មានថ្ងៃភ្លេចនូវការសម្លាប់រង្គាលលើពលរដ្ឋអាមេរិកជាង១.៥លាននាក់ កាលពីក្នុងសម័យចក្រភព Ottoman Empire។ ទោះបីជារស់រងការឈឺចាប់ខ្លោចផ្សារ និងភាពភ័យភិតនៃអំពើប្រល័យពូជសាសន៍យ៉ាងណាក្តី ក៏ពលរដ្ឋអាមេរិកគ្រប់ទិសទី រួមគ្នាកួចចំណង និងត្បាញសេចក្តីសង្ឃឹម និងក្តីសុបិនរបស់ពួកគេ ដើម្បីឈានទៅរកវឌ្ឍនភាព និង វិបុលភាពជាលំដាប់៕

# City Hall Monuments

**By Richard P. Howe Jr. (March 19, 2015)**

As the Cambodian people of Lowell begin the work of creating a monument for their community here in Lowell, it might be helpful to consider the other ethnic monuments that have already been erected on the grounds of Lowell City Hall.

On the lawn in front of City Hall sit two monuments, one to the French Canadians who came to the city; the other to those who **Continued to Page 8**



Continued from page 07

## City Hall Monuments

came from Poland. The Franco monument is a bell on a granite base. On the base is inscribed "In honor of the Franco Americans of Lowell, Mass. 1984." The Polish monument is a upright rectangle of granite inscribed with "Dedicated in Honor of the Polish Americans of Lowell. May 3, 1977."

To the side of City Hall at either end of the grassy island in the middle of Cardinal O'Connell Parkway sit two other ethnic monuments, one to the Irish ("Dedicated to the Irish Americans of Lowell. 1822 - 1977"), the other to the Greeks ("Dedicated to the early Greek immigrants by their grateful progeny. 1983").




The two most recent monuments to be dedicated sit right in front of City Hall. The first honors the Portuguese who came to Lowell. It is inscribed "In honor of the heritage and contributions of the Portuguese Community to the City of Lowell. June 10, 2009."

Perhaps the most elaborate monument on the grounds of City Hall is also the newest. It was dedicated by the Armenian community just last year. It has an inscription ("In Memory of the Victims of the Armenian Genocide: 1915 - 1923") but it also carries an explanation of its meaning:




**A Mother's Hands**

Knot by know, her hands weave the history of her people. The delicacy of the crochet integrated into this cross stone is symbolic of the beauty and strength of the Armenian heritage. This ancient culture lives forever, just as the imprint of the first genocide of the 20th century lives in the collective memory of the Armenians. The blooming cross stone is the permanent reminder that the massacre of more than 1.5 million Armenians within the Ottoman Empire will never be forgotten, that in spite of the pain and horror of the genocide, knot by knot, the Armenian People everywhere weave their hopes and dreams, as they bloom and prosper.






# តមកពីទំព័រទី ០១ ព្រះអង្គម្ចាស់ធម្មិកោ : សង្គ្រោះជាតិមាន...

ព្រះអង្គបានយាងមកជួបសហគមន៍ខ្មែរនៅសហរដ្ឋអាមេរិកចំនួនជាង២ខែ ដើម្បីប្រាប់ពីព្រឹត្តិការណ៍នយោបាយនៅកម្ពុជា។ ព្រះអង្គមានព្រះបន្ទូលនៅទីក្រុងឡូវែលថា:






"កម្ពុជាសព្វថ្ងៃ កំពុងក្លាយជាកម្ពុជាក្រោមទី២។ យួនយកគណបក្សប្រជាជនកម្ពុជាជាឈ្នាន់ ដើម្បីវាយខ្មែរ។ បាវចនាទាំងបី ជាតិ សាសនា ព្រះមហាក្សត្រក្នុងរយៈពេល៣៥ឆ្នាំកន្លងមក យួនខិតខំបំផ្លាញទាំងអស់។ ឧកញ៉ាសម័យ ហ៊ុន សែន បម្រើបក្សយកងារទៅសង្កត់សង្កិនប្រជារាស្ត្រ។ ស្រុកខ្មែរមានឧត្តមសេនីយ៍ជាង៣ពាន់នាក់ លើសឧត្តមសេនីយ៍ដែលមាននៅស្រុកអាមេរិក ៦ដង។ ព្រះមហាក្សត្រខ្មែររងការគាបសង្កត់។ បណ្តាំដូនជីនៅវត្តគោកសំពៅ។ ត្រូវតែមានហ៊ុន ស៊ិនប៊ិច។ យុទ្ធសាស្ត្រសង្គ្រោះជាតិ ដើម្បីត្រៀមដឹកនាំប្រទេសនៅអាណត្តិក្រោយ" ទាំងអស់នេះជាខ្លឹមសារសំខាន់ៗរបស់ព្រះអង្គម្ចាស់ធម្មិកោ ដែលមានព្រះរាជបន្ទូលទៅកាន់អ្នកគាំទ្រគណបក្សសង្គ្រោះជាតិនៅអាមេរិក មុននឹងដំណើរយាងត្រឡប់ទៅមាតុប្រទេសវិញ។

តើប្រការអ្វីខ្លះ ដែលព្រះអង្គម្ចាស់ធម្មិកោហ៊ានអះអាងថា កម្ពុជាសព្វថ្ងៃជាកម្ពុជាក្រោមទីពីរ?

"ជនអន្តោប្រវេសន៍ គឺជាប្រជាជនដែលយួនបញ្ជូនមកនៅស្រុកខ្មែរ ដើម្បីបង្កើតនិគមកសាងជីវភាពរស់នៅ និងរៀបចំអាជីវកម្មរបស់ខ្លួន។ កាលពីដើមយួនបញ្ជូនប្រជាជនមកកម្ពុជាក្រោមបន្ទាប់មកបញ្ជូនរដ្ឋបាល។ ឥឡូវយួនបញ្ជូនប្រជាជនមកប្រទេសកម្ពុជា និងបញ្ជូនរដ្ឋបាលដូចគ្នានៅពេលដែលយួនបញ្ជូនរដ្ឋបាលមកត្រួតត្រាទឹកដីកម្ពុជាក្រោម។ សមាគមយួនមាននៅ២៥ខេត្តក្រុង ដែលយួនរៀបចំ ដើម្បីគ្រប់គ្រងប្រជាជនរបស់ខ្លួននៅលើទឹកដីរបស់យើង។ បញ្ហាដីធ្លីនៅស្រុកខ្មែរនៅចម្ការអំពៅនៅខេត្តកំពង់ស្ពឺ។ ទំនាស់ជាមួយក្រុមហ៊ុនស្ករ និងប្រជាជនខ្មែរតែបែរជាកុងស៊ុលយួនទៅខេត្តកំពង់ស្ពឺ ដើម្បីអន្តរាគមន៍។ ធនាគារយួននៅស្រុកខ្មែរបង្កើតដើម្បីវេរលុយពីស្រុកយួនរាប់ពាន់លានដុល្លារយកមកផ្តល់លទ្ធភាពឱ្យយួនដែលរស់នៅលើទឹកដីយើង ទិញផ្ទះ ទិញដី បង្កើតអាជីវកម្មកសាងជីវភាពរស់នៅរបស់យួន។ យោធាយួនដែលចូលមកស្រុកខ្មែរក្នុងឆ្នាំ១៩៧៩ មិនបានចេញពីដីខ្មែរវិញទេ។ យួនមានប្រជាជនរដ្ឋបាលសេដ្ឋកិច្ច និងកងទ័ពនៅស្រុកខ្មែរ។ មូលហេតុនេះហើយដែលបញ្ជាក់ថា ខ្មែរយើងសព្វថ្ងៃកំពុងក្លាយជាកម្ពុជាក្រោមដែរទៅហើយ។

យួនសម្ងំលាក់ខ្លួននៅក្រោយស្ថាប័នជាតិយើងសព្វថ្ងៃ។ យួនយកគណបក្សប្រជាជនកម្ពុជាជាឈ្នាន់ ដើម្បីឱ្យខ្មែរវាយខ្មែរ។ នេះជាយុទ្ធសាស្ត្ររបស់យួន។ គ្រប់ស្ថាប័នជាតិយួនបំផ្លាញទាំងអស់។ សាសនាក៏យួនបំផ្លាញសង្គមជាតិយើងក៏យួនបំផ្លាញព្រះមហាក្សត្រក៏យួនបំផ្លាញផងដែរ។

សម័យ ប៉ុល ពត គ្មានព្រះសង្ឃនៅស្រុកខ្មែរទេ។ គ្រាន់តែយួនចូលមកក្នុងឆ្នាំ១៩៧៩ ស្រាប់តែមានព្រះសង្ឃពេញវត្ត។ ពេលយួនចូលមកយួនបង្កើតចលនាមួយហៅថា ចលនា២ ធ្នូ ដឹកនាំដោយ ទេព វង់។ យួនបានយកព្រះសង្ឃមួយចំនួនពីខ្មែរក្រោមមកបំបួសសង្ឃខ្មែរយើងបំបួស ទេព វង់ **តទៅទំព័រទី ១៨**


# GATEWAY FAMILY DENTAL

www.gatewayfamilydental.com • (978) 455-5044

151 WARREN STREET, SUITE 120 LOWELL, MA 01852 (Same building as Social Security/near the courthouse)



**DR. SERENA B. CHUOP**

Dr. Serena B. Chuop was born in Cambodia. She received her Bachelor of Science from Boston University and went on to graduate from Boston University Goldman School of Dental Medicine in the year 2000. For over 13 years, she has been in private practices providing all aspects of General Dentistry. Her state of the art dental practice includes digital x-rays, paperless patient chart system, and new dental equipments.




**WE PROVIDE ALL SERVICES INCLUDING: យើងផ្តល់នូវសេវាដូចខាងក្រោមនេះ**

- CLEANING
- FILLINGS
- BONDINGS
- COSMETIC DENTISTRY
- CROWNS/BRIDGES
- DENTURES
- IMPLANTS
- EXTRACTIONS
- TEETH WHITENING
- VENEERS
- EMERGENCY DENTAL TREATMENT
- ROOT CANAL TREATMENT
- DENTAL SERVICES TO CHILDREN

- សំអាតធ្មេញ
- បំពេញធ្មេញប្រហោង
- ថ្នាំសំរាប់ការពារធ្មេញ
- ធ្មេញពាក់ជុំនួសធ្មេញដែលបាក់
- ក្រាសធ្មេញពាក់
- ដាំធ្មេញតាមរន្ធធ្មេញចាស់
- ដកធ្មេញ
- ធ្វើធ្មេញឱ្យសស្អាត
- វ៉ែវនីស្រោបធ្មេញ
- ព្យាបាល និងការពារធ្មេញជាទៀងទាត់
- ព្យាបាល ឬសថ្គាមធ្មេញ
- សេវាព្យាបាលសំរាប់កុមារ

Free Teeth Whitening Kit
(with new patient´s x-ray, exam, cleaning at regular price)

MOST DENTAL INSURANCES ACCEPTED
INCLUDING MASSHEALTH
FINANCING AVALIABLE
យើងទទួលនូវគ្រប់ អ៊ិន ស៊ូរិន
Masshealth
យើងសំរួលការបង់ថ្លៃព្យាបាលប្រចាំខែ
CALL FOR YOUR FREE CONSULTATION
(978) 455-5044

# អ្នកសល់ពីវាលពិឃាតខ្មែរមកជួបសិស្សសាលា

# Survivors of Cambodian Genocide Visit Classroom

នៅថ្នាក់សិក្សាវៀតណាមនៃសាលាគ្រូតុន អាមេរិកាំង អ្នកគ្រូ ជេនីហ្វៀ វ៉ៃឡេស នឹងលោកគ្រូ រូឌី ខាឡុកបានអញ្ជើញភ្ញៀវ៤រូប មកផ្តល់ភស្តុតាងជាសាក្សីនៃព្រឹត្តិការណ៍ ជូនដល់និស្សិតស្រីប្រុសស្តីអំពី"សង្គ្រាមនៅវៀតណាម"អំពីប្រជាជននឹងប្រវត្តិនៃប្រទេសកម្ពុជា ។ អ្នកសល់ពីវាលពិឃាដ គឺ ស ថែល នឹង ស៊ីវខេង ស ជាឪពុកនឹងម្តាយនិស្សិត ថាយល័រ ស ១៥ឆ្នាំ - រ៉ជ័រ សំខុន ពិន អ្នកសារព័ត៌មានខ្មែរនៅឡូវែលតែម្នាក់ដែលបានជួបសម្ភាសន៍ ប៉ុល ពតនឹង ជីម ឡុកនី អតីតយុទ្ធជនក្នុងសង្គ្រាមវៀតណាម។ សូមអញ្ជើញអានសេចក្តីរាយការណ៍របស់សាលា គ្រូតុន ជាភាសាអង់គ្លេស ដូចតទៅ:

Groton's America in Vietnam class received up-close and personal insights into the Cambodian genocide last week, thanks to three visitors who shared their unique experiences.

Teacher Jennifer Wallace welcomed ThelSar, SivkhengSar, and Roger Samkhon Pin to class, where they discussed the impact of the Second Indochinese War (the American war in Vietnam) on the people and history of Cambodia.

ThelSars, parent of Tyler Sar '15, survived the 1975-79 Cambodian genocide. Mr. Sar described being driven out of Phnom Penh by the Khmer Rouge, a Maoist party that attempted to create an agrarian utopia. As a 9-year old boy, he was forced to resort to eating roaches, rats, and leaves—anything to survive the famine, which was a result of the group's failed political and economic policies (and possibly a deliberate punishment to the people). An estimated 2 million people died during this period.

Both Thel and SivkhengSar eventually fled to Thailand and the Philippines before being resettled in the United States. They now live and work in Lowell, Massachusetts.

The third visitor, Mr. Pin, was a journalist for Radio Free Asia; though he did not remain in Cambodia during the genocide, he is one of the few living journalists to have interviewed Pol Pot when he was being held for trial in the 1990s. Pol Pot was the leader of the Khmer Rouge, the communist party responsible for the genocide. Mr. Pin is currently the editor of KhmerPost USA; he also resides in Lowell.




The class, co-taught with Vietnam veterans Jim Lockney and Rudy Kallock, appreciated this first-hand perspective on one of the most excruciating events in 20th-century history.—Jennifer Wallace

Photo: Speaker ThelSar, co-teacher Rudy Kallock, and speaker Roger Samkhon Pin

## កម្សាន្ត កម្សាន្ត

### ខ្សត់គំនិត

"នៅស្ងៀមជាជាងស្រដីទំពារចេកខ្ចីជាជាងទំនេរមាត់" ប្រយោគនេះត្រូវម៉ាច់នឹងអត្តចរិតរបស់ ចយ ដែលជាមនុស្សអៀនមិនសូវហ៊ានបញ្ចេញគំនិត។ ថ្ងៃមួយ ចយ ក្លាហានបានឡើងបញ្ចេញយោបល់ម្តង។

**គ្រូ:** យោបល់ប្អូនឯងប្រៀបបានទៅនឹងត្បូងបរប៉ៃលិន!

**ចយ :** (អរព្រួច លួចញញឹមក្នុងចិត្តគិតថាគ្រូសរសើរ) លោកគ្រូចង់មានប្រសាសន៍ថាគំនិតខ្ញុំមានតម្លៃមែនទេ ?

**គ្រូ:** អត់ទេ! គ្រូចង់ថា វាខ្សត់។

### ដើមទ្រូងប្រាំហត្ថដូចម៉ែ

កុមារាម្នាក់មិនយល់ពាក្យ "បុរសដើមទ្រូងប្រាំហត្ថ"។

**កុមារា :** តើបុរសដើមទ្រូងប្រាំហត្ថ គឺជាអ្វីពុក?

**ឪពុក :** អ្នកណាដែលស្រលាញ់កូនដោយឥតលក្ខខណ្ឌ អ្នកណាដែលព្រយតិតដល់កូនគ្មានពេលល្ហែ និងអ្នកណាដែលថែរក្សាការពារកូនរាល់ថ្ងៃអ្នកនោះឯងគឺជាបុរសដើមទ្រូងប្រាំហត្ថណាកូន! កូនយល់ឬនៅ?

**កុមារា :** បាទ! កូនយល់ហើយពុក! ពេលកូនធំឡើងកូននឹងធ្វើខ្លួនឱ្យទៅជាបុរសដើមទ្រូងប្រាំហត្ថដូចម៉ែដែរ ៕


## "កុំស្មានបងភ្លេច" កម្មវិធីប្រគុំតន្ត្រីឆ្នាំ ២០១៥

### ខ្មែរបាត់បង់តន្ត្រីរ៉ក់

"Don't Think I've Forgotten" Cambodia's Lost Rock and Roll

LIVE CONCERT | DINNER | SOCIAL DANCING

ការប្រគុំតន្ត្រីផ្ទាល់ ដើម្បីរកប្រាក់ចំណូលឱ្យក្រុមតន្ត្រីសម័យរបស់ខ្មែរនៃខចំតន្ត្រី និងតន្ត្រីករដែលធ្លាប់ល្បីល្បាញ កាលពីសម័យមុន!
ម៉ុល កាម៉ាច, ម៉ុល កាញ៉ុល, ហុង សំឡី, តាណា, ទូច ឆាត់តាហា, អ៊ឹក សំអាត
ចូលរួមច្រៀងដោយ ស៊ីន សេដ្ឋាកុល និង ឆោម និមល!

| | |
|---|---|
| ថ្ងៃ អាទិត្យ ទី ២៦ ខែ មេសា | Sunday, April 26th |
| នៅភោជនីយដ្ឋាន សំពៅមាស | SompaoMeas Hall |
| 450 Chelmsford Street, Lowell | 450 Chelmsford Street, Lowell |
| ចាប់ផ្តើមទទួលភ្ញៀវនៅម៉ោង ៦ ល្ងាច | Doors Open at 6pm |
| ពិសាអាហារនៅម៉ោង ៦:៣០ ល្ងាច | Dinner Served at 6:30pm |
| តន្ត្រីប្រគុំនៅម៉ោង ៧:៣០ យប់ | Concert at 7:30pm |
| | Tickets: $30.00 |

តម្លៃសំបុត្រ: ៣០ដុល្លាក្នុង១នាក់ មានបន្ថែមអាហារខ្មែរបួនមុខ!
បើលោកអ្នកចង់ទិញសំបុត្រ ឬព័ត៌មានបន្ថែម
សូមទាក់ទងទៅ ស៊ូ សែន ក្រុមវែល 617-306-7556 និង សូបិន ពិន 978-656-8141
សូមបើកមើលគេហទំព័រ www.dtiflowellconcert.eventbrite.com
កម្មវិធីបញ្ចាំងខ្សែភាពយន្ត ចាប់ពីរថ្ងៃទី ២៤ដល់ ៣០ ខែមេសា
នៅរោងកុន Showcase Cinema
Screening 24-30 April
www.showcasecinema.com/Lowell



# ក្រុមសិល្បៈ“ព្រះរាជាណាចក្រកំប៊ូជ្យា”សំដែងក្នុងពិធីបុណ្យវប្បធម៌អាស៊ាន អាមេរិកាំង ឆ្នាំ២០១៥

ខែមេសា ឆ្នាំ២០១៥, គំរប់៤០ឆ្នាំ តាំងពីសង្គ្រាមវៀតណាមបានចប់, ក៏ជាខណៈដែលទីក្រុងភ្នំពេញ ត្រូវបាត់បង់ក្នុងអំឡុងថ្ងៃទី៣១ មីនា និងថ្ងៃទី៣ មេសាជាខណៈពេលធ្វើឱ្យមានការចងចាំនៅសម័យសង្គ្រាម, ហេតុនេះទើបយើងប្រារព្ធធ្វើបុណ្យរំលឹកនៅភាពជោគជ័យនៃប្រជារាស្ត្រអាស៊ីភាគអាគ្នេយ៍បានមករស់នៅក្នុងស.រ.អា (ព័ត៌មានបន្ថែម និងមានបន្តទៅមុខ) ។

ភាគក្នុងរឿងនេះ, សំដែងនៅថ្ងៃព្រហស្បត្តិ៍, ទី២មេសា,ម៉ោង៧យប់នៅ (Durgin Hall)រួចនិងមានបញ្ចាំងវីឌីអូរឿង( ព្រះរាជាណាចក្រកំប៊ូជ្យា) និងរឿងប្រឌិត"មាតាជនភៀសខ្លួនខ្មែរមានការលំបាកក្នុងការសម្រប់ជាមួយកូនស្រីរបស់ខ្លួន"ព្រមទាំងមានដន្ត្រី និងចម្រៀងដោយក្រុមមហាវិទ្យាល័យក្រុងឡូវែល, មាននាទីរបាំសមាគមអង្គរ, និងក្រុមតន្ត្រីចម្រៀង"ផប"ពីសម័យឆ្នាំ១៩៦០ ។

**ក្រុមអ្នកជួយឧបត្ថម្ភមានៈ** មជ្ឈមណ្ឌលមហាវិទ្យាល័យអេស៊ាន-អាមេរិកាំងក្រុងឡូវែលផ្នែកដូរ្យដន្ត្រី, មហាវិទ្យាល័យវិចិត្រសិល្បៈ




មនុស្សសាស្ត្រនឹងវិទ្យាសាស្ត្រសង្គមហើយនឹងមជ្ឈមណ្ឌលសិល្បៈនឹងគំនិតយោបល់។ កម្មវិធីមួយនេះគាំទ្រមួយផ្នែកដោយការឧបត្ថម្ភដោយក្រុមប្រឹក្សាវប្បធមិក្រុងឡូវែល, ដែលជាអង្គការក្នុងតំបន់គាំទ្រដោយក្រុមប្រឹក្សាវប្បធមិរដ្ឋម៉ាសាឆូសិត, ព័ត៌មានបន្ថែមអញ្ជើញចូលវែបសាយនៅខាងក្រោមៈ www.uml.edu/Research/CAAS

## “The Kingdom of Kambuja”: 2015 Asian American Cultures Festival

April 2015 marks 40 years since the end of the Vietnam War and the fall of Phnom Penh. A series of events March 31-April 3 will serve as a remembrance of the wars as well as a celebration of the resilience and successes of Southeast Asians in the U.S. (More information about these events forthcoming)

As part of this series, on Thursday, April 2, 7pm, in Durgin Hall, Flying Orb Productions will premiere “The Kingdom of Kambuja,” a multimedia play in which a Cambodian refugee mother uses fairy tales to communicate her difficult stories to her daughter. The evening will also include performances by the UMass Lowell World Music Ensemble, Angkor Dance Troupe, and a 1960s Cambodian pop tribute band.

Co-sponsored by the UMass Lowell Center for Asian American Studies, Music Department, College of Fine Arts, Humanities and Social Sciences, and the Center for Arts and Ideas.This program is supported in part by a grant from the Lowell Cultural Council, a local agency which is supported by the Massachusetts Cultural Council, a state agency. For more information, visit www.uml.edu/Research/CAAS or www.flyingorb.com or contact CAAS@uml.edu.

B&M
DISPOSAL
ក្រុមហ៊ុនដឹកជញ្ជូនសំរាម ប៊ីអឹម



កុងទីន័រដាក់សម្រាម 30 YARD CONTAINER
រហូតដល់ ៤ តោន $549
កុងទីន័រដាក់សម្រាម 20 YARD CONTAINER
រហូតដល់ ៣ តោន $449
កុងទីន័រដាក់សម្រាម 15 YARD CONTAINER
រហូតដល់ ២ តោន $349

*សូមបង់ថែម $100 ក្នុង ១០០០ ផោនបន្ថែម ។ អនុញ្ញាតឱ្យដាក់បន្ថែមលើសទម្ងន់អតិបរមានៅលើកុងទីន័រណាមួយខាងលើបាន ។

សូមទាក់ទងឈ្មោះ ប៊ុន ឥឡូវនេះ!
មានផ្តល់សេវាជូនដល់ហាងទំនិញ និងតាមផ្ទះ




BUSINESS – RESIDENTIAL
CAll BUN NOW ! 978-569-6062



## ប្រវត្តិសង្ខេប
# ទឹកដីកម្ពុជាក្រោម និងប្រទេសចំប៉ា



**សង្ខេបប្រវត្តិសាស្ត្រ**
**ដោយ ថាច់ វណ្ណា**

ក្នុងសតវត្សទី១៧ទឹកដីខ្មែរភាគអាគ្នេយ៍ហៅថាកម្ពុជាក្រោមរួមមាន២២ខេត្ត និងកោះ២ ។

ក្នុងសម័យព្រះបាទ ជ័យជេដ្ឋាទី២ គ្រងរាជ្យឆ្នាំ១៦១៨-១៦២៨ បានអនុញ្ញាតឱ្យយួន (សព្វថ្ងៃហៅថាៈ វៀតណាម) ចូលមកតាំងទីលំនៅក្នុងតំបន់ព្រៃនគរ និងរកស៊ីរបរនេសាទត្រីនៅឆ្នាំ១៦២៣ ។

បន្ទាប់មក,ក្នុងឆ្នាំ ១៦៩៨ អាទិទេពនិយម ង្វៀន (Nguyen Lord) សម័យនោះនគរយួនមានឈ្មោះថាៈ ដាយវៀត (Dai Viet) មានទីតាំងនៅភ្នំខាងលិចនៃប្រទេសចិន, ក៏បានតែងតាំងត្រកូលអភិជនម្នាក់ឈ្មោះ ង្វៀន ហ៊ីវកាញ់ ( Nguyen Huu Canh) ជាអ្នករៀបចំបញ្ជូនប្រជារាស្ត្រយួនឱ្យចូលមកតាំងលំនៅក្នុងព្រៃនគរ និងតាមដងទន្លេមេគង្គដោយច្រើនសន្ធឹកសន្ធាប់រួចក៏បានដណ្តើមអំណាចត្រួតត្រាកំពង់ផែព្រៃនគរក្នុងឆ្នាំ១៧៥៧, បន្ទាប់មកក៏ធ្វើការវាយលុកឆ្ពោះទៅភាគខាងត្បូងតាមដងទន្លេមេគុងចូលទៅខេត្តផ្សារដែក និងខេត្តមាត់ជ្រូក,កាត់ផ្តាច់ផ្លូវសេដ្ឋកិច្ចនយោបាយ និងយោធារវាងកម្ពុជាក្រោម និងព្រះរាជាណាចក្រកម្ពុជា,ធ្វើឱ្យកម្ពុជាក្រោមស្ថិតនៅក្នុងភាពឯកោ, រីឯទ័ពយួនវិញ, **តទៅទំព័រទី២៩**


ឧកញ៉ា សឺង គុយ
វិរបុរសខ្មែរក្រោមសតវត្សទី ១៩

### កម្ពុជា ក្រោមមាន២២ ខេត្ត ក្រុងនិងកោះ២

| ឈ្មោះខ្មែរ | | ឈ្មោះយួនប្រែ | |
|---|---|---|---|
| ១ ទីក្រុងព្រៃនគរ | ប្រែទៅជា | ទីក្រុងហោ ជីមិញ | TP.Ho Chi Minh |
| ២ ខេត្តពលលាវ | ប្រែទៅជា | ខេត្ត បាកលីវ | Tinh Bac Lieu |
| ៣ ខេត្ត ឃ្លាំង | ប្រែទៅជា | ខេត្ត សុក ត្រាំង | Tinh Soc Trang |
| ៤ ខេត្តព្រៈត្រពាំង | ប្រែទៅជា | ខេត្ត ត្រា វិញ | Tinh Tra Vinh |
| ៥ ខេត្ត ទឹក ខ្មៅ | ប្រែទៅជា | ខេត្ត កា មៅ | Tinh Ca Mau |
| ៦ ខេត្ត ពាម | ប្រែទៅជា | ខេត្ត ហា តៀង | Tinh Ha Tien |
| ៧ ខេត្ត បាភ៍ជ | ប្រែទៅជា | ខេត្ត ឡុង ស្វៀង | Tinh Long Xuyen |
| ៨ ខេត្ត ក្រមួន ស | ប្រែទៅជា | ខេត្ត កៀន យ៉ាង | Tinh Kien Giang |
| ៩ ខេត្ត ចង្វាត្រពាំង | ប្រែទៅជា | ខេត្ត បៀន ហ្វា | Tinh Bien Hoa |
| ១០ ខេត្តព្រៈសួគ៌ា | ប្រែទៅជា | ខេត្ត ធូយ៉ូវ មោត | Tinh Thu Dau mot |
| ១១ ខេត្ត មាត់ជ្រូក | ប្រែទៅជា | ខេត្ត ចូវ ឌក | Tinh Chau Doc |
| ១២ខេត្តកំពង់ឬស្សី | ប្រែទៅជា | ខេត្ត បេន ត្រែ | Tinh Ben Tre |
| ១៣ខេត្ត លង់ហោរ | ប្រែទៅជា | ខេត្ត វិញ ឡុង | Tinh Vinh Long |
| ១៤ ខេត្តព្រែកឬស្សី | ប្រែទៅជា | ខេត្ត កិន ធើ | Tinh Can Tho |
| ១៥ ខេត្ត មេ ស | ប្រែទៅជា | ខេត្ត មី ថូវ | Tinh My Tho |
| ១៦ ខេត្ត រោង ដំរី | ប្រែទៅជា | ខេត្ត តី និញ | Tinh Tay Ninh |
| ១៧ខេត្តដំបូកកោង | ប្រែទៅជា | ខេត្ត ហ្គូ កុង | Tinh Go Cong |
| ១៨ ខេត្ត មភា | ប្រែទៅជា | ខេត្ត ឌង ណៃ | Tinh Dong Nai |
| ១៩ ខេត្ត ផ្សារដែក | ប្រែទៅជា | ខេត្ត សា ឌាក | Tinh Sa Dec |
| ២០ខេត្តឧកញ៉ាឌិន | ប្រែទៅជា | ខេត្ត យ៉ា ឌិញ | Tinh Gia Dinh |
| ២១ ខេត្ត តានន់ | ប្រែទៅជា | ខេត្ត ឡុង អាន | Tinh Long An |
| ២២ខេត្តអូរកាប់យួន | ប្រែទៅជា | ខេត្ត វុង តាវ | Tinh Vung Tau |
| | រីកោះមាន ២ គឺ | | |
| ១ កោះ ត្រល់ | ប្រែទៅជា | កោះ ភូ ក្វិក | Dao Phu Quoc |
| ២ កោះត្រឡាច | ប្រែទៅជា | កោះ កូន សើន | Dao Con Son |

សូមបញ្ជាក់ថាៈ រដ្ឋាភិបាលយួនតែងតែប្តូរឈ្មោះស្រុក និង ខេត្ត ជា រៀងរាល់ទសវត្សរ៍ ឧទាហរណ៍ៈ ខេត្តវុង តាវ ប្តូរទៅជាស្រុក វុង តាវជាដើម។
(និងមានចុះផ្សាយបន្តលើកក្រោយ)




CONWAY
INSURANCE AGENCY

រយៈពេល២៥ឆ្នាំ ភ្នាក់ងារធានារ៉ាប់រងខុនវេយបានបម្រើសហគមន៍ដោយធានារ៉ាប់រងគ្រប់មុខប្រកបដោយគុណភាពនៅតំបន់ញូអ៊ីងលែន ។
យើងខ្ញុំជាភ្នាក់ងារបំពេញសេវាគ្រប់មុខដូចខាងក្រោម :

**ការធានារ៉ាប់រងគ្រួសារ**
- រថយន្ត
- ផ្ទះ
- ផ្ទះល្វែង
- គ្រឿងអលង្ការ
- វត្ថុសិល្បះ
- វត្ថុបុរាណ

**ការធានារ៉ាប់រងជំនួញ**
- អចលនវត្ថុ
- សុវត្ថិភាពជំនួញ (Liability)
- សុវត្ថិភាពជំនាញ (Professional Liability)
- វិកខឹខម (Worker's Compensation)
- បនដស៍ (Bonds)
- អ្នកមើលថែឡាន និងការ៉ាស់ឡាន
- ធានារ៉ាប់រងពិការភាព និងជីវិត
- កម្មវិធីពិសេសផ្សេងៗទៀត

CONWAY INSURANCE AGENCY
77 E. Merrimack Street. Lowell, MA 01852
Tel: 978-454-5054|Fax 978-453-2480
www.conwayinsurance.com
សូមទាក់ទងមក : ហ្វីលីប មុត, អ្នកគ្រប់គ្រង

ខូម៉ែរ សិប្បកម្មច្នៃបសំណាកក្រានីត
COLMER MONUMENT WORKS
Memorials of Distinction
អាស័យដ្ឋានៈ 1025 Lawrence Street Lowell, MA 01852-4898
(978) 452-7821



- Granite Memorials ផ្នូររាងបញ្ឈរធ្វើពីថ្មក្រានីត
- Granite & Bronze Markers ផ្នូរផ្តេកមានឆ្លាក់សរិទ្ធលេថ្មក្រានីត
- Cemetery Lettering in Khmer មានឆ្លាក់អក្សរខ្មែរលើថ្មនៃផ្នូរ

COLMER Monument Works
ភាពថ្លៃថ្នូរ កិត្តិយស និងការគោរពជូនលោកអ្នក
Honor. Dignity. Respect for All

# KhmerPost USA 5th Annual Gala Celebrates

## Asian/Pacific American Heritage Month
## Friday, May 8th, 2015





2014 Keynote Speaker, Sichan Siv, Former US Ambassador to UN and Author of Golden Bones







*Join us for an evening of APA cultural performances, special guest speaker, and sit down dinner with a live band. and social dancing until midnight. Like last year, this year we have the honor to host another distinguished leader, the Honorable Judge Meng H. Lim of Superior Court from West Georgia.*

*Ticket: $35 Advance Purchased / $40 after May 1st*

*Attire: Evening / Formal*

*RSVP: Soben Pin at 978-656-8141*
*sobenpin@khmerpost.us*

*For sponsorship information, please visit:*
*www.khmerpost.us/Gala*



Honorable Judge Meng H. Lim
2015 Guest Speaker

**Friday, May 8th, 2015**
**6:30PM - Midnight**
**Pailin Restaurant,**
**Lowell, Massachusetts.**

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីកាសែតអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

## រដ្ឋាភិបាលបដិសេធរបាយការណ៍ដែលចោទថា មានការបំពានសិទ្ធិកម្មករ

**ដោយៈ ម៉ិច ដារ៉ា និង ហ្សមប៊រ ភីធឺរ** | **MARCH 16, 2015**

ក្រសួងការងារបានបដិសេធរបាយការណ៍ថ្មីរបស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស Human Rights Watch (HRW) មានមូលដ្ឋាននៅអាមេរិក ដែលលើកឡើងនូវការបំពានជាច្រើនលើសិទ្ធិកម្មករពីសំណាក់រោងចក្រកាត់ដេររបស់ប្រទេសនេះ ដោយទទូចឱ្យក្រុមអធិការរដ្ឋាភិបាលឃ្លាំមើលឱ្យដិតដល់លើនិយោជក។

កាលពីថ្ងៃសៅរ៍ អង្គការសិទ្ធិមនុស្ស HRW បានចេញលទ្ធផលនៃបទសម្ភាសរបស់ខ្លួនជាមួយកម្មករកាត់ដេររាប់រយនាក់កាលពីឆ្នាំមុន ព្រមទាំងជាមួយមន្ត្រីរដ្ឋាភិបាលនិងរោងចក្រផងដែរ។ ក្នុងរបាយការណ៍មាន១៤០ទំព័រ បានឱ្យដឹងថា ការធ្វើការលើសម៉ោងដោយបង្ខំពលកម្មកុមារ ការបំបែកសហជីព និងការបំពានកិច្ចសន្យារយៈពេលខ្លី និងអ្នកម៉ៅការបន្តស្រមោលនៅតែកើតមានជាទូទៅ។

របាយការណ៍នេះបានហៅការត្រួតពិនិត្យមើលរបស់រដ្ឋាភិបាលលើវិស័យមានទឹកប្រាក់៥.៧៥ពាន់លានដុល្លារនេះ ជាឧស្សាហកម្មនាំចេញដ៏ធំបំផុតរបស់ប្រទេសកម្ពុជា និងជាវិស័យផ្តល់ការងារច្រើនបំផុត ថាគួរឱ្យ "ស្រងាកចិត្ត"។

ការលើកឡើងនូវតួលេខដែលផ្តល់ដោយក្រសួងការងាររបាយការណ៍ HRW និយាយថា រដ្ឋាភិបាលបានពិន័យតែ១០រោងចក្រប៉ុណ្ណោះក្នុងចំណោមរោងចក្រកាត់ដេរនាំចេញជាង៥០០របស់ប្រទេសកម្ពុជាក្នុងរយៈពេលប្រាំឆ្នាំពីឆ្នាំ២០០៩ដល់ឆ្នាំ២០១៣ និង២៥រោងចក្រផ្សេងទៀតប៉ុណ្ណោះក្នុងរយៈពេល១១ខែដំបូងនៃឆ្នាំ២០១៤។ អង្គការ HRW បានពណ៌នាតួលេខនេះថា "តិចតួចណាស់" បើធៀបនឹងចំនួនរោងចក្រទាំងអស់ និងបញ្ហាឥតឈប់ឈរនៃការរំលោភសិទ្ធិពលករ"។

ក្នុងសេចក្តីប្រកាសព័ត៌មានមួយចេញកាលពីថ្ងៃសុក្រក្រសួងការងារនិយាយថា ខ្លួនបានធ្វើការជាមួយអង្គការពលកម្មអន្តរជាតិ (ILO) និងកម្មវិធីរោងចក្រល្អប្រសើរនៅកម្ពុជា (BFC) ដើម្បីធ្វើឱ្យលក្ខខណ្ឌការងារប្រសើរឡើង និងបានហៅរបាយការណ៍របស់ HRW ថា "មិនអាចទទួលយកបាន"ទេ។

សេចក្តីប្រកាសព័ត៌មាននេះនិយាយថា "ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈមានការសោកស្តាយយ៉ាងខ្លាំង និងបដិសេធចំពោះរបាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្ស HRW"។

សេចក្តីប្រកាសព័ត៌មាននេះនិយាយថា "សហគមន៍អន្តរជាតិ អ្នកបញ្ជាទិញ និងអង្គការអន្តរជាតិខាងការងារបានគាំទ្រនិងទទួលស្គាល់ថា លក្ខខណ្ឌការងារនៅកម្ពុជាមានភាពល្អប្រសើរស្របតាមបទដ្ឋានអន្តរជាតិ ព្រមទាំងបានលើកទឹកចិត្តឱ្យបណ្តាប្រទេសផ្សេងទៀតយកគំរូតាមប្រទេសកម្ពុជាក្នុងការអនុវត្តគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា។ ដូច្នេះអ្វីដែលបានលើកឡើងក្នុង

**តទៅទំព័រទី១៥**

## Government Rejects Report Alleging Abuse of Workers

**BY MECH DARA AND ZSOMBOR PETER | MARCH 16, 2015**

The Labor Ministry has rejected a scathing new report from U.S.-based Human Rights Watch (HRW) listing a litany of labor abuses by the country's garment factories, insisting that government inspectors keep a close watch over employers.

On Thursday, HRW released the results of its interviews with hundreds of garment workers over the past year, as well as with government and factory officials. In a 140-page report, it says that forced overtime, child labor, union busting and the abuse of short-term contracts and shadowy subcontractors remained rife.

The report also called the government's oversight of the $5.75-billion sector-by far the country's largest export industry, and one of its most prolific job creators-"dismal."

Citing figures provided by the Labor Ministry, the HRW report says the government fined only 10 of the country's 500-plus exporting garment factories in the five years from 2009 through 2013, and only 25 more in the first 11 months of 2014. HRW described the figures as "abysmally low when compared to the number of factories overall and the persistent patterns of labor rights violations."

In a statement released Friday, the Labor Ministry says it has worked with the International Labor Organization (ILO) and its Better Factories Cambodia (BFC) program to improve labor conditions, and calls HRW's report "unacceptable."

"The Ministry of Labor strongly regrets and denies the report by Human Rights Watch," the statement says.

"The international community, buyers and the ILO have supported and acknowledged that working conditions in Cambodia are in compliance with international standards and have encouraged other countries to learn from Cambodia's implementation of the BFC program," it says. "Therefore, what was stated in the report is unacceptable."

The ministry adds that 49 teams carried out 7,191 inspections of 805 "enterprises" in 2014 and fined 128 of them. However, the statement does not name the enterprises, say how many of them were garment factories or specify how much they were fined.

A spokesman for the ministry could not be reached on Sunday.

On Thursday, the Garment Manufacturers Association in Cambodia, which represents the country's exporting garment factories, said the 270 workers HRW interviewed for its report were too few to offer a fair portrayal of a sector that employs some 600,000 people. It also blamed any lack of resources on the part of Labor Ministry inspectors on BFC, which works with the government to improve labor conditions in the factories.

In its report, however, HRW says the program is being thwarted by factory managers who have either coached their workers to give BFC inspectors positive reviews ahead of announced visits or threatened them not to complain.

"In addition to being coached, workers were told to prepare for 'visitors.'" HRW says.

## កូនប្រុសមន្ត្រីគយជាប់សង្ស័យនៅក្នុងការបាញ់បោះក្នុងមជ្ឈមណ្ឌលកម្សាន្ត

**ដោយៈ សាំង សុផន្ធរិទ្ធ** | **MARCH 16, 2015**

យោងតាមនគរបាលបានឱ្យដឹងថា កូនប្រុសរបស់មន្ត្រីគយមានបុណ្យស័ក្តិខ្ពស់ម្នាក់បានជាប់ពាក់ព័ន្ធនៅក្នុងហេតុការណ៍បាញ់បោះមួយនៅមជ្ឈមណ្ឌលកម្សាន្តរ៉ុក ក្នុងខណ្ឌចំការមន រាជធានីភ្នំពេញនៅវេលារំលងអធ្រាត្រកាលពីម្សិលមិញ ដោយបណ្តាលឱ្យបុរសម្នាក់បានរងរបួស។

ទោះបីជារបាយការណ៍ប្រចាំថ្ងៃរបស់នគរបាលរាជធានីដែលកត់ត្រាបទល្មើសកើតឡើង កាលពីម្សិលមិញក្នុងរាជធានីភ្នំពេញ មិនបាននិយាយ

**តទៅទំព័រទី ២៥**



## Customs Official's Son Involved in Club Shooting

**BY SAING SOENTHRITH | MARCH 16, 2015**

The son of a high-ranking customs official was involved in a shooting incident at the Rock nightclub in Phnom Penh's Chamkar Mon district early Sunday morning that left one man injured, according to police.

Though a daily municipal police report, which included a rundown of crimes committed in the city on Sunday, failed to mention the incident, the National Police noted on their website that the son of Keo Sokheng, who heads the mobile inspection unit inside the Finance Ministry's customs and excise department, was part of the group that fired the shots.

The post on the National Police website says a brother of Mr. Sokheng's wife and a bodyguard were also in the group, but does not specify who fired the shots or how many rounds were discharged.

Deputy district police chief Heang Thareth said the shooting occurred in the

**Continued to Page 30**

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីកាសែតអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# លោក កឹម សុខា មិនពេញចិត្តនឹងកិច្ចព្រមព្រៀងកាលពីថ្ងៃទី២២ ខែកក្កដា

ដោយៈ មុិច ដារ៉ា និង អេឡិក វិល្លឹមមីនស៍ | MARCH 17, 2015

លោក កឹម សុខា អនុប្រធានគណបក្សសង្គ្រោះជាតិបានមានប្រសាសន៍នៅក្នុងសុន្ទរកថាមួយនៅសហរដ្ឋអាមេរិក កាលពីសប្តាហ៍មុនថា លោកមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់គណបក្សប្រឆាំងក្នុងការបញ្ចប់ការធ្វើពហិការមិនចូលសភាកាលពីឆ្នាំមុននោះឡើយ ប៉ុន្តែលោកទ្រាំ "លេបគ្រួសលេបថ្ម" ដើម្បីរក្សាការរួបរួមគ្នាជាមួយលោក សម រង្ស៊ី មេដឹកនាំគណបក្សសង្គ្រោះជាតិ។

នៅក្នុងវីដេអូឃ្លីបបង្ហោះតាមអ៊ីនធើណិតកាលពីម្សិលមិញស្តីពីសុន្ទរកថាទៅកាន់អ្នកគាំទ្រគណបក្សសង្គ្រោះជាតិដែលសុទ្ធតែជាជនជាតិខ្មែរសញ្ជាតិអាមេរិកក្នុងរដ្ឋកាលីហ្វ័រញ៉ាកាលពីយប់ថ្ងៃសុក្រលោក កឹម សុខា បានលើកឡើងថា លោកប្រឆាំងទៅនឹងលទ្ធផលនៃការចរចាជាមួយគណបក្សប្រជាជនកម្ពុជា ប៉ុន្តែលោកមានកាតព្វកិច្ចត្រូវតែគាំទ្រជាសាធារណៈចំពោះការចរចានេះ។

លោក កឹម សុខា បានមានប្រសាសន៍ថា "ការចរចាគឺធ្វើឡើងនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ប៉ុន្តែចំពោះខ្ញុំបើនិយាយឱ្យត្រង់ទៅខ្ញុំមិនពេញចិត្តនឹងការចរចានេះឡើយ។ ខ្ញុំមិនពេញចិត្ត



នឹងលទ្ធផលនៃការចរចាទេ ប៉ុន្តែខ្ញុំគោរពតាមគោលនយោបាយ និងជំហររបស់គណបក្សសង្គ្រោះជាតិដែលត្រូវទទួលយកការចរចានេះ ដើម្បីដោះស្រាយបញ្ហា"។

តទៅទំព័រទី ២៣

# Kem Sokha Was Unhappy With July 22 Political Deal

BY MECH DARA AND ALEX WILLEMYNS | MARCH 17, 2015

CNRP Vice President Kem Sokha said in a speech in the U.S. last week that he was unhappy with the opposition party's decision to end its boycott of the National Assembly last year but was prepared to "swallow gravel and rocks" to maintain unity with party leader Sam Rainsy.

In a video recording of a speech delivered to Cambodian-American CNRP supporters in California on Friday night, which was posted online Monday, Mr. Sokha said he was opposed to the results of the negotiations with the ruling CPP but felt obliged to publicly support them.

"The negotiations were on July 22, 2014, but the negotiations, for me, I was not happy with them, to speak frankly," Mr. Sokha said. "I was not happy with the result of the negotiations, but I respected the CNRP's policy and stance that it had to accept it in order to resolve the issues.

"We got a very short agreement and it was not clear or detailed, so the agreement could be interpreted in many ways, but it was also the basis to do work on other things. It was not all bad, but it did not satisfy us fully," he said.

The July 22 agreement, forged during a meeting at the Senate led by Prime Minister Hun Sen and Mr. Rainsy, ended the CNRP's boycott of its 55 seats in the National Assembly following the disputed 2013 national election.

In exchange for the opposition's effective Contined to Page 22

តមកពីទំព័រទី ១៤

# រដ្ឋាភិបាលបដិសេធរបាយការណ៍...

របាយការណ៍របស់អង្គការនេះ គឺមិនអាចទទួលយកបានឡើយ"។

ក្រសួងនេះបានបន្ថែមថា ក្រុមអធិការកិច្ចការងារ៤៩ក្រុមបានធ្វើអធិការកិច្ចការងារចំនួន ៧.១៩១លើកក្នុងចំណោម ៨០៥ "សហគ្រាស" ក្នុងឆ្នាំ២០១៤ និងបានពិន័យ១២៨សហគ្រាស។ ក៏ប៉ុន្តែសេចក្តីប្រកាសព័ត៌មាននេះមិនបានប្រាប់ឈ្មោះសហគ្រាសទាំងនោះ សហគ្រាសប៉ុន្មានជារោងចក្រកាត់ដេរ ឬបញ្ជាក់ថា បានពិន័យពួកគេប៉ុន្មាននោះទេ។

អ្នកនាំពាក្យក្រសួងនេះមិនអាចទាក់ទងបានទេកាលពីថ្ងៃអាទិត្យ។

កាលពីថ្ងៃព្រហស្បតិ៍សមាគមរោងចក្រកាត់ដេរនៅកម្ពុជាហៅកាត់ថា GMAC? ដែលតំណាងឱ្យរោងចក្រផលិតសម្លៀកបំពាក់សម្រាប់ការនាំចេញរបស់កម្ពុជាបាននិយាយថា កម្មករ ២៧០នាក់ ដែល HRW បានសម្ភាសសម្រាប់របាយការណ៍របស់ខ្លួននោះ ជាចំនួនតិចតួចណាស់ មិនអាចតំណាងឱ្យវិស័យមួយដែលមានមនុស្ស ៦០០.០០០នាក់បានឡើយ។

សមាគមនេះក៏បានបន្ទោសកង្វះធនធានលើផ្នែកក្រុមអធិការក្រសួងការងារស្តីពីគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជាដែលធ្វើការជាមួយរដ្ឋាភិបាលដើម្បីឱ្យលក្ខខណ្ឌការងារបានប្រសើរនៅតាមរោងចក្រ។ ក៏ប៉ុន្តែក្នុងរបាយការណ៍របស់ខ្លួន HRW និយាយថា កម្មវិធីនេះកំពុងត្រូវបានរារាំងដោយអ្នកគ្រប់គ្រងរោងចក្រដែលបានណែនាំកម្មកររបស់ខ្លួនឱ្យប្រាប់ក្រុមអធិការ BFC នូវចំណុចវិជ្ជមានមុនការចុះមកពិនិត្យ ឬបានគំរាមពួកគេមិនឱ្យត្អូញត្អែរជាដើម។

HRW និយាយថា "បន្ថែមទៅនឹងត្រូវគេណែនាំឱ្យនិយាយកម្មករត្រូវបានគេប្រាប់ឱ្យត្រៀមខ្លួនសម្រាប់ជួបអ្នកចុះមកពិនិត្យ"។

"គេបានប្រាប់កម្មករឱ្យយកគំនរខោអាវចេញពីម៉ាស៊ីនដេររបស់ខ្លួន ហើយលាក់វា និងបានផ្តល់ស្រោមដៃ និងម៉ាស់មុនក្រុមអធិការមកដល់។ ភ្លើង និងកង្ហារដែលជាធម្មតាត្រូវគេបិទនោះ បានបើកកន្លែងទឹកផឹកត្រូវដាក់បំពេញ ហើយកម្មករក្មេងមិនគ្រប់អាយុត្រូវបានគេលាក់មិនឱ្យឃើញទេ"។

នៅពេលដែល BFC ចាត់វិធានការតបនឹងល្បិចបែបនេះ របាយការណ៍នេះនិយាយថា កម្មករនៅតែចង់បានការទាក់ទងដោយផ្ទាល់នឹងក្រុមអធិការដើម្បីធ្វើការតវ៉ាដោយមិនមានការសងសឹកពីថៅកែរបស់ខ្លួន។

ប្រតិកម្មកាលពីថ្ងៃអាទិត្យទៅនឹងសេចក្តីប្រកាសព័ត៌មានរបស់ក្រសួងការងារលោកស្រី អារុណា កាស៊ីយ៉ាប អ្នកស្រាវជ្រាវសិទ្ធិស្ត្រីជាន់ខ្ពស់របស់ HRW បាននិយាយថា តួលេខថ្មីរបស់ក្រសួងនេះកាន់តែធ្វើឱ្យមានការបារម្ភថែមទៀត។

កាលពីខែធ្នូ ក្រសួងការងារក្នុងការឆ្លើយសំណួរពី HWR បាននិយាយថា ខ្លួនបានចុះធ្វើអធិការកិច្ច១.៦៨៦លើកអំឡុងពេល១១ខែដំបូងនៃឆ្នាំ២០១៤។ លោកស្រីបាននិយាយថា ដោយបានធ្វើអធិការកិច្ច៧.១៩១លើកដែលក្រសួងនេះឥឡូវនេះនិយាយថា ខ្លួនបានធ្វើអធិការកិច្ចតាមរោងចក្រកាត់ដេរកាលពីឆ្នាំមុននោះ ខ្លួននឹងត្រូវធ្វើអធិការកិច្ច៥។៥០៥លើកក្នុងពេលតែមួយខែប៉ុណ្ណោះ ពោលគឺជាមធ្យមធ្វើអធិការកិច្ចជិត ១៧៨លើកក្នុងមួយថ្ងៃ។

លោកស្រី កាស៊ីយ៉ាប បាននិយាយថា "ដូច្នេះយើងបារម្ភណាស់ចំពោះអធិការកិច្ចដែលធ្វើឡើងតាមវិធីប្រញាប់ប្រញាល់រួសរាន់បែបនេះ"។

លោកស្រីបានបន្ថែមថា ហើយបើរដ្ឋាភិបាលច្រានចោលនូវអ្វីដែលកម្មករបានប្រាប់ HRW នោះ "ពួកគេនិយាយថា កម្មកររបស់ខ្លួនជាអ្នកកុហក...។ ហើយនោះជារឿងព្រួយបារម្ភណាស់ ហើយជាសារខកចិត្តបញ្ជូនទៅកម្មករ"។

លោកស្រី កាស៊ីយ៉ាប បាននិយាយថា រដ្ឋាភិបាលគួរបញ្ចេញឱ្យដឹងព័ត៌មានថែមទៀតថាតើរោងចក្រណាខ្លះត្រូវទទួលពិន័យ ពួកគេត្រូវបង់ពិន័យប៉ុន្មាន ហើយថាតើពួកគេបានបង់ពិតមែនដែរឬអត់។

អ្នកស្រាវជ្រាវជាន់ខ្ពស់រូបនេះបាននិយាយថា "សាធារណជននឹងដឹងប្រាកដ ប្រសិនបើរដ្ឋាភិបាលប្តេជ្ញាឱ្យរោងចក្រទទួលខុសត្រូវមែននោះ"៕

និត

# ច្បាប់អនុម័តដោយសភាជាតិ

## ថ្ងៃទី១៩ ខែមិនា ឆ្នាំ២០១៥

## ច្បាប់ស្តីពី

# ការរៀបចំ និងការប្រព្រឹត្តទៅ

# នៃ

# គណៈកម្មាធិការជាតិ

# រៀបចំការបោះឆ្នោត

### ជំពូកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១._**

ច្បាប់នេះមានគោលដៅកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីរៀបចំ ចាត់ចែង និងគ្រប់គ្រងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ព្រមទាំងការបោះឆ្នោតផ្សេងទៀត តាមការកំណត់នៃច្បាប់។

**មាត្រា ២._**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានឈ្មោះជាអក្សរកាត់ "គ.ជ.ប"។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវមានគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត និងគណៈកម្មការការិយាល័យបោះឆ្នោត ដើម្បីអនុវត្តការងាររបស់ខ្លួន។

**មាត្រា ៣._**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវអនុវត្តសមត្ថកិច្ចរបស់ខ្លួន ដោយឯករាជ្យ និងអព្យាក្រឹត ដើម្បីធានាឲ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស។

សមាជិកទាំងឡាយនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងសមាជិកនៃគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវមានជំហរអព្យាក្រឹតឥតលម្អៀងក្នុងការអនុវត្តការងារបោះឆ្នោត។

### ជំពូកទី ២
### គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

### ផ្នែកទី ១
### ការរៀបចំគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

**មាត្រា ៤._**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសមាសភាព០៩ (ប្រាំបួន) រូប ដែលរួមមាន៖

–ប្រធាន ០១ (មួយ) រូប
–អនុប្រធាន ០១ (មួយ) រូប
–សមាជិក ០៧ (ប្រាំពីរ) រូប។

**មាត្រា ៥._**

សមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវជ្រើសរើសក្នុងចំណោមឥស្សរជនខ្មែរទាំងពីរភេទ ដែលមានលក្ខណសម្បត្តិដូចខាងក្រោម៖

–មានសញ្ជាតិខ្មែរពីកំណើត និងមានសញ្ជាតិខ្មែរតែមួយគត់ក្នុងពេលបំពេញការងារនៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
–មានអាយុយ៉ាងតិច៣៥ (សាមសិបប្រាំ) ឆ្នាំ គិតដល់ថ្ងៃតែងតាំង
–មានសិទ្ធិបោះឆ្នោត
–មានសញ្ញាបត្រចាប់ពីថ្នាក់ឧត្តមសិក្សាឡើងទៅ
–មានបទពិសោធន៍ការងារយ៉ាងតិច១០ (ដប់) ឆ្នាំ
–មិនត្រូវជាសហព័ទ្ធ ឬញាតិលោហិត ឬញាតិពន្ធរហូតដល់ថ្នាក់ទី៣របស់ប្រធាន អនុប្រធានគណបក្សនយោបាយ ដែលចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត។

**មាត្រា ៦._**

សមាសភាពទាំង០៩ (ប្រាំបួន) រូប នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវជ្រើសរើសដោយ៖

–០៤ (បួន) រូប ជ្រើសរើសដោយគណបក្សដឹកនាំរាជរដ្ឋាភិបាល
–០៤ (បួន) រូប ជ្រើសរើសដោយគណបក្សមានអាសនៈក្នុងរដ្ឋសភាដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាល និង
–០១ (មួយ) រូបទៀត ជ្រើសរើសដោយមានការព្រមព្រៀងគ្នារវាងគណបក្សទាំងអស់ដែលមានអាសនៈក្នុងរដ្ឋសភា។

ផ្អែកតាមគោលការណ៍ខាងលើនេះ គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភាត្រូវធ្វើការសម្របសម្រួលជាមួយគណបក្សនយោបាយទាំងអស់ ដែលមានអាសនៈក្នុងរដ្ឋសភា ដើម្បីប្រកាសជ្រើសរើសបេក្ខជនសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជាសាធារណៈ ប្រកបដោយលក្ខណៈបើកចំហ និងមានតម្លាភាពក្នុងរយៈពេលយ៉ាងតិច១០ (ដប់) ថ្ងៃ។ បន្ទាប់មក គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភាត្រូវសម្របសម្រួលជាមួយគណបក្សទាំងអស់ ដែលមានអាសនៈក្នុងរដ្ឋសភា ដើម្បីពិនិត្យជ្រើសរើសបេក្ខជនសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតពីក្នុងចំណោមបេក្ខជន ដែលបានដាក់ពាក្យស្នើសុំ ដោយផ្អែកតាមលក្ខណសម្បត្តិដូចមានចែងក្នុងមាត្រា៥ នៃច្បាប់នេះ។

បែបបទ និងនីតិវិធីនៃការជ្រើសរើសបេក្ខជនសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវកំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា។

ផ្អែកលើសមាសភាពដែលបានជ្រើសរើសខាងលើនេះ គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភាត្រូវរៀបចំបញ្ជីសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដាក់ជូនរដ្ឋសភា ដើម្បីបោះឆ្នោតទុកចិត្តតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវតែងតាំងដោយព្រះរាជក្រឹត្យយ៉ាងយូរ០៦ (ប្រាំមួយ) ខែ បន្ទាប់ពីរដ្ឋសភាថ្មីចូលកាន់តំណែង។

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង។

**មាត្រា ៧._**

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានអាណត្តិ០៥ (ប្រាំ) ឆ្នាំ ហើយត្រូវផុតអាណត្តិនៅពេលសមាសភាពថ្មីចូលកាន់តំណែង។

ក្នុងករណីដែលខកខានមិនបានរៀបចំសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលមានស្រាប់ ត្រូវអនុវត្តការងាររបស់ខ្លួនបន្តទៀត និងមានសមត្ថកិច្ច ដើម្បីចាត់ចែងរៀបចំបោះឆ្នោតស្របតាមច្បាប់ជាធរមាន។

**មាត្រា ៨._**

មុខងារជាប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានវិសមិតភាពជាមួយការបំពេញមុខតំណែងក្នុងមុខងារសាធារណៈ និងជាមួយមុខងារជាសមាជិកនៃស្ថាប័នដទៃទៀត ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបានព្យួរសិទ្ធិបោះឆ្នោតជាបណ្តោះអាសន្ន រហូតដល់ថ្ងៃបញ្ចប់មុខតំណែង។

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលជាសមាជិកនៃគណបក្សនយោបាយត្រូវសុំលាលែងពីគណបក្សនយោបាយ ហើយអាចចូលជាសមាជិកគណបក្សនយោបាយវិញបានក្នុងរយៈពេលយ៉ាងតិច០២ (ពីរ) ឆ្នាំ បន្ទាប់ពីបញ្ចប់អាណត្តិការងារ ឬបាត់បង់មុខតំណែង ឬត្រូវបានបណ្តេញចេញ ដូចមានចែងក្នុងមាត្រា៧ មាត្រា៩ និងមាត្រា១០ នៃច្បាប់នេះ។

តទៅលេខក្រោយ

# ព្រឹត្តិការណ៍សំខាន់នៅខាវអ៊ីដងប្រទេសថៃ

**ខ្មែរផុសស.រ.អា**

បន្ទាប់ពីផ្សាយព័ត៌មានអំពីដំណើរលោកគ្រូពេទ្យ ឆាន ទូច ត្រឡប់ទៅខាវអ៊ីដង កាលពីលេខមុនមានមិត្រអ្នកអានយើងផ្សេងទៀត ក៏មានបំណងចង់ឃើញការផ្សព្វផ្សាយពីអ្នករួមក្នុងដំណើរជាមួយគ្នាលើទំព័រកាសែតខ្មែរផុសស.រ.អា. ដែរ។ លោក ស៊ុម បូរ៉េត ពីទីការិយាល័យ ស៊ុម អ៊ូតូ បានអោយដឹងថា ដំណើរនេះ ធ្វើតាមសេចក្តីអញ្ជើញរបស់មន្ត្រីអ.ស.ប. អនឌី ផែនដលថុន Andy Pendleton ធ្លាប់ជាមន្ត្រីប្រចាំការណ៍នៅខាវ អ៊ីដន នាឱកាសខួបទី៣០ឆ្នាំ នៃថ្ងៃបិទជំរុំខាវអ៊ីដន ដែលប្រព្រឹត្តឡើងពីថ្ងៃទី៩មករា ដល់ ១១មករា២០១៥។


កុមារ និងពលរដ្ឋខ្មែរនៅណងចាន់

អតីតជនភៀសខ្លួនខ្មែរនៃជំរំខាវអ៊ីដនទៅពីសហរដ្ឋអាមេរិកទៅមាន: លោក ជុំ ឈាង ឧត្តមសេនីយចូលនិវត្តន៍ជាប្រធានប្រតិភូ- លោក ស៊ុម បូរ៉េត- សាត មហោរី - ជា ច្រៀង - ទូច ឆាន - តាន់ ចេដ្ឋាកេតូ - សុខ វណ្ណា - ពៅ បុផ្ផា - សិក ភារម្យ ចូលរួមដោយដំណាងសមាគមខ្មែរ ៣រូបទៀត នឹងអមដោយប្រតិភូនៃអភិបាលក្រុងឡូវែលដែរ។ អតីតជនភៀសខ្លួនខ្មែរទៅពីប្រទេសកម្ពុជា មាន: លោក វ៉ា សំណាង - ភោគ សារ៉ាត- សាត សាលឹម- លីវ៉ាន់ សុភ័ណ- រាជ សារិន - ប៊ូ សុផល - អ៊ុង ប៊ុនធឿន - នឹងលោក សីហា។


ប្រតិភូ និងអភិបាលក្រុងឡូវែល


ជួបជុំគ្នានៅអារញ្ញប្រាថេត



លោក ស៊ឹម បូរ៉េត និងឧត្តមសេនីយ៍ ជុំ ឈាង

អ្នកដំណើរខ្មែរទាំងអស់មានបំណងចូលរួមសម្តែងការអរគុណយ៉ាងជ្រាលជ្រៅដល់ អ.ស.ប. ដែលបានរៀបចំជាជំរុំសង្គ្រោះជីវិតខ្មែរជាច្រើន ដែលបានគេចផុតពីសង្គ្រាមឆេះរាលដាលនៅកម្ពុជា នាអំឡុងឆ្នាំ៧០-៨០ ហើយក៏មានបំណងផងដែរថា យើងដែលជាអ្នកបានរស់ហើយ ក៏សម្រាប់មកធ្វើបុណ្យជូនកុសលដល់អ្នកដែលបានចែកឋានក្នុងជំនាន់នោះដែរ។

ភ្ញៀវប្រមាណជា២០០នាក់ ចម្រុះគ្រប់សាសន៍មកពី១៣ប្រទេសសុទ្ធសឹងជាអតីតបុគ្គលិកបំរើការក្នុងអង្គការអន្តរជាតិនានា បានមកប្រារព្ធពិធីជួបជុំគ្នា នៅអារញ្ញប្រាថេត តាមកាលកំណត់ លោក អនឌី បានផ្តល់ឱកាសឱ្យភ្ញៀវបានរំលឹកពីជីវិតក្នុងជំរុំជនភៀសខ្លួន ។ ភ្ញៀវទាំងអស់បានបន្តដំណើរទៅណងចាន់ដែលជាផ្នែកនៃដីខ្មែរនៅចំទល់មុខជំរុំភៀសខ្លួន រួចចូលទៅដីថៃសំដៅទៅជំរុំថ្មី ប្ញទ្ធីសែន ក្នុងជំរំសាយធូ នឹងខាវអ៊ីដាង ។ នៅតាមផ្លូវនោះ ភាគីខ្មែរដំណាងដោយឧត្តមសេនីយ ជុំ ឈាង **តទៅទំព័រទី ២៤**

Congratulations,
Bopha Malone!

Enterprise Bank congratulates Bopha Malone on being named the Lowell Sun's 2014 Woman of the Year!

Bopha's tireless work for charitable causes and community betterment are more than worthy of recognition.



**Bopha Malone**
*Branch Relationship Manager, AVP*
910 Andover Street
Tewksbury, MA 01876
978-656-5561

Enterprise Bank
CREATE SUCCESS
EnterpriseBanking.com

Member FDIC

តមកពីទំព័រទី ០៩

## ព្រះអង្គម្ចាស់ធម្មិកោ : សង្គ្រោះជាតិមាន...

បំបួសសង្ឃរាប់រយនាក់នៅក្នុងស្រុកខ្មែរ។ បន្ទាប់មកសង្ឃដែលគេបំបួសអស់ទាំងនេះ គេពង្រាយពេញស្រុកខ្មែរ ដើម្បីឱ្យសង្ឃទាំងអស់នេះ បំបួសសង្ឃដទៃទៀត។ ពួកនេះបានបំបួសសង្ឃរាប់ពាន់អង្គ ដោយខុសច្បាប់សង្ឃខុសច្បាប់វិន័យពុទ្ធសាសនារបស់យើង។ សព្វថ្ងៃចៅអធិការវត្តសុទ្ធតែជាសាវ័ករបស់បក្សប្រជាជនកម្ពុជាមិនមែនសាវ័ករបស់ព្រះទេ។

កាលពីដើមពេលមានសត្វអ្វីរត់ចូលក្នុងវត្ត ដូចជាគោ ជ្រូកមាន់ទា អត់មាននរណាមានសិទ្ធិទៅចាប់សត្វទាំងនោះនៅក្នុងវត្តទេ។ ដូចគ្នាដែរ នរណារងគ្រោះ ពេលចូលក្នុងវត្តអត់មាននរណាមានសិទ្ធិទៅចាប់ ឬធ្វើបាបគាត់បានទេ។ ឥឡូវជនរងគ្រោះដីធ្លី នៅបុរីកីឡា នៅខាងបឹងកក់ និងនៅទីផ្សេងៗ អស់ផ្ទះនៅ អស់ដី សុំជ្រកនៅក្នុងវត្ត វត្តបិទទ្វារចាក់សោរអត់ឱ្យចូល។ ទាំងអស់នេះហើយ ដែលបញ្ជាក់ថាយួនបំផ្លាញសាសនារបស់យើង។

ពេលយើងមានធុរៈ ទៅវត្តពឹងលោកសង្ឃឱ្យស្រោចទឹកឱ្យយើង។ ប៉ុន្តែឥឡូវបាសកបែរជាស្រោចទឹកឱ្យលោកសង្ឃវិញ។ តើយើងគិតយ៉ាងម៉េចនៅពេល ប៊ុន រ៉ានី ស្រោចទឹកឱ្យសម្តេចសង្ឃយើង? តើសាសនាយើងមាននៅសល់អ្វីទៀត?"

តើសង្គមខ្មែរយើងនៅមានសីលធម៌ សច្ចធម៌ និងសុជីវធម៌ដែរឬទេ? ព្រះអង្គបន្តមានបន្ទូលថា: "បងប្អូនអញ្ជើញមើលចរាចរណ៍នៅស្រុកខ្មែរទៅ។ គេលែងគោរពច្បាប់ហើយ។ ច្បាប់សង្គមគឺស្ថិតនៅលើការគោរពគ្នាទៅវិញទៅមក។ ពីដើមព្រះមហាក្សត្រតែងតាំងឧកញ៉ាបួនប្រាំនាក់ប៉ុណ្ណោះ ដែលជាវីរជន ឥស្សរជនជាន់ខ្ពស់ បម្រើជាតិ បម្រើប្រជារាស្ត្រ ដូចជាឧកញ៉ា ស៊ឺន គុយ ដែលជាអ្នកការពារដីកម្ពុជាក្រោមយកជីវិតទៅប្តូរដើម្បីការពារដីកម្ពុជាក្រោមឱ្យព្រះមហាក្សត្រយើង។ ឧកញ៉ាក្រឡាហោមគង់ សុទ្ធតែជាវីរជន ដែលយកជីវិតទៅប្តូរដើម្បីបម្រើជាតិ។ សព្វថ្ងៃឧកញ៉ាមានរាប់មិនអស់។ ឧកញ៉ាទាំងនេះ បម្រើបក្សប្រជាជនកម្ពុជាជាងបម្រើជាតិ។ ឧកញ៉ាយកងារទៅតាបសង្កត់ប្រជារាស្ត្រ។ រហូតដល់យួនក៏មានឧកញ៉ាដែរ ដូចជាឧកញ៉ា ថោង សារ៉ាត់។

កងទ័ពត្រូវតែចំណាយពេលបួនប្រាំឆ្នាំឆ្លងកាត់ការសិក្សា និងប្រឡងមុនឡើងស័ក្តិ។ ឥឡូវកូនចៅមន្ត្រីធំៗគ្រាន់តែចូលកងទ័ពភ្លាមពាក់ផ្កាយមួយ។ សម័យសង្គមរាស្ត្រនិយមក្នុងស្រុកមានឧត្តមសេនីយ៍ប្រាំប្រាំមួយនាក់ក្នុងស្រុក។ កងទ័ពអាមេរិកាំងមានទ័ពពាលាននាក់ មានឧត្តមសេនីយ៍៥០០នាក់។ កងទ័ពយើងមានកម្លាំងទ័ព ១៥ម៉ឺននាក់ មានឧត្តមសេនីយ៍ជាង ៣០០០នាក់។ គ្រាន់តែឧត្តមសេនីយ៍អាចបង្កើតជាកងពលមួយបាន។

មហាក្សត្រក៏រងការតាបសង្កត់។ សម័យឥឡូវក៏មិនខុសគ្នាពីសម័យ ប៉ុល ពត ទេ។ ពេលគេត្រូវការព្រះករុណា សីហមុនី គេបញ្ចេញលោកទៅចែកអំណោយសម្តោចសាលារៀនសម្ពោធមន្ទីរពេទ្យ។ ព្រះអង្គគ្មានសិទ្ធិអំណាចអ្វីទាំងអស់។ ហ៊ុន សែន ជា ស៊ីម ហេង សំរិន សៅ សុខាចេញមកពីខ្មែរក្រហម។ យើងចេះតែភ្លេចថាអ្នកទាំងអស់នោះជាខ្មែរក្រហម។ របប ប៉ុល ពត និងរបបសព្វថ្ងៃអត់ខុសគ្នាទេ។ ប៉ុល ពត ប្រើធមិក្តៅយួនប្រើធមិត្រជាក់បំផ្លាញបន្តិចម្តងៗធ្វើឱ្យ

តទៅលេខក្រោយ


Khmer Owned & Operated

Independence Home Care
Health Services LLC

ថែរក្សាសុខភាពដល់លំនៅដ្ឋានរបស់អ្នកទូទាំងរដ្ឋ

Licensed Home Care Provider / Companion Services

Certified Medicare/Medicaid • Joint Commission Accreditation • Home Nursing Care Provider Licensed by RI Department of Health

**Approved Provider of All State Programs:** Department of Elderly Affairs / Department of Human Services

**Skilled Nursing**
- Registered Nurses
- Home Health Aide
- Physical Therapy
- Occupational Therapy
- Speech Therapy
- Medical Social Worker

**Unskilled Nursing**
- Companionship
- Personal Care
- Bathing
- Dressing
- Safety
- Meal Preparation and Housekeeping
- Medication Reminders
- Errands and Assistance with Transportation

**Employment**
**Nurses & CNAs**
- Helping Over 100 Rhode Island Elderly Southeast Asians
- We Employ Over 50 Southeast Asians
- FREE ASSESMENT



*Let our family, take care of yours.*

CALL US TODAY!
(401) 437-8337
www.independencehs.com
Available 24/7



1179 Elmwood Ave.
Providence, RI 02907

- See our Khmer Video about Home Care at our website -

## តមកពីទំព័រ ០១ លោកស្រី មីស៊ែល អូបាម៉ា បំពេញ...

ប្រទេសកម្ពុជា នៅយប់ថ្ងៃសុក្រ ទី២០ ខែមីនា ឆ្នាំ២០១៥។

**តើលោកជំទាវទី១ របស់សហរដ្ឋអាមេរិក ទៅស្រុកខ្មែរក្នុងគោលបំណងអ្វី?**

គម្រោង "ផ្តល់ឱកាសឱ្យសិស្សស្រីបានចូលរៀននៅសាលា" ជាគម្រោងដែលអនុវត្តដោយទីភ្នាក់ងារអន្តរជាតិអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID)។ ក្នុងគ្រោងនេះ ក្នុងឆ្នាំដំបូងលោកស្រី មីស៊ែល ត្រូវដំណើរទៅកាន់ប្រទេសចំនួន១១ រួមមាន កម្ពុជា អាល់បានី បេនីន ប៊ើគីណាហ្វាសូ ហ្សកហ្ស៊ី ហ្គាណា ម៉ុលដូវ៉ា ម៉ុងហ្គោលី មូហ្សំប៊ិច តូហ្គោ និងអ៊ុយហ្គង់ដា។

នៅទូទាំងពិភពលោកមានកុមារីជាង ៦២ លាននាក់ ដែលមិនបានចូលរៀន។ ដូច្នេះដំណើរទស្សនកិច្ចរបស់លោកស្រី មីស៊ែល គឺដើម្បីជម្រុញឱ្យចំនួនកុមារីបានចូលរៀនច្រើនជាងមុន និងដើម្បីឈានទៅកាត់បន្ថយអត្រាកុមារីមិនបានចូលរៀន។

សេតវិមានបានបញ្ជាក់ថា ការជ្រើសរើសប្រទេសជប៉ុន និងកម្ពុជាសម្រាប់ការធ្វើទស្សនកិច្ចរបស់លោកស្រី មីស៊ែល គឺដោយសារប្រទេសជប៉ុនជាប្រទេសមានជាងគេនៅអាស៊ី និងជាម្ចាស់ជំនួយនៃគម្រោងដែលជប៉ុនគ្រោងនឹងផ្តល់ប្រាក់៣៤០លានដុល្លា ដើម្បីជួយគម្រោងអប់រំកុមារីនេះ។ ចំណែកឯកម្ពុជាជាប្រទេសក្រីក្រជាងគេនៅអាស៊ី។ ម្យ៉ាងវាស្របទៅនឹងគោលនយោបាយសហរដ្ឋអាមេរិក ក្នុងការយកចិត្តទុកដាក់បន្ថែមទៅលើប្រទេសនៅតំបន់អាស៊ីប៉ាស៊ីហ្វិកផងដែរ។

ក្នុងដំណើរទស្សនកិច្ចនៅកម្ពុជា លោកស្រី មីស៊ែល បានចុះទៅជួបសិស្សស្រីវិទ្យាល័យប្រាសាទបាគងក្នុងខេត្តសៀមរាប និងបានស្តាប់ការរៀបរាប់ពីការតស៊ូទុក្ខលំបាកដែលពួកគេកំពុងជួបប្រទះសព្វថ្ងៃ។ សិស្សស្រីទាំងនោះ បានរៀបរាប់ថា ពួកគេត្រូវក្រោកពីព្រលឹម ដើម្បីចម្អិនអាហារសម្រាប់គ្រួសារ និងជួយកិច្ចការស្រែចម្ការមុននឹងធាក់កង់មកសាលាដែលនៅឆ្ងាយពីផ្ទះ។ ពេលយប់ពួកគេត្រូវបន្តមើលមេរៀនហួតដល់យប់ជ្រៅ។

លោកស្រីកោតសរសើរសិស្សស្រីទាំងនោះថា ជាអ្នកគំរូដល់ពិភពលោក។ លោកស្រីមានប្រសាសន៍ទៅកាន់ពួកគេថា ការអប់រំធ្វើឱ្យស្ត្រីមានឥទ្ធិពលខ្លាំង។ លោកស្រីទទូចសុំឱ្យសិស្សានុសិស្សខ្មែរប្រឹងរៀនសូត្រហួតដល់ចប់ចុងចប់ដើម ដើម្បីពួកគេអាចទាមទារសិទ្ធិសេរីភាព ឱកាសទទួលបានការយកចិត្តទុកដាក់ស្មើគ្នា និងធ្វើឱ្យសុបិនរបស់ខ្លួនក្លាយជាការពិត។

ទោះបីជាសិស្សស្រីមួយចំនួននៅសាលាវិទ្យាល័យប្រាសាទបាគង ដែលត្រូវបានសម្រាំងដើម្បីជួបលោកស្រី មីស៊ែល មានការអប់រំល្អប្រសើរ និងចេះនិយាយភាសាអង់គ្លេសបានគ្រាន់បើយ៉ាងណាក្តីក៏សិស្សស្រីជាទូទៅនៅទូទាំងប្រទេសកម្ពុជាជួបបញ្ហាលំបាកជាច្រើនក្នុងការសិក្សា។ បើតាមរបាយការណ៍រដ្ឋាភិបាលខ្មែរក្នុងឆ្នាំ២០១៤ កុមារបោះបង់សាលារៀននៅមានចំនួនច្រើន។ ទោះបីកុមារ ៩៥ភាគរយបានចូលរៀនថ្នាក់បឋមសិក្សាក៏ដោយ មានតែ២០%ប៉ុណ្ណោះបានរៀនចប់ថ្នាក់វិទ្យាល័យ។ យោងតាមអង្គការ UNICEF ភាពក្រីក្រនៅទីជនបទ គឺជាកត្តាចម្បងនៃការបោះបង់ការសិក្សារបស់កុមារ ត្បិតពួកគេត្រូវឪពុកម្តាយឱ្យឈប់រៀន ដើម្បីជួយរកប្រាក់ចិញ្ចឹមគ្រួសារ។ ប្រទេសកម្ពុជានៅតែមានបញ្ហាបេស្យាចារកុមារ និងការជួញដូរមនុស្ស។ បញ្ហាទាំងនេះក៏ជាឧបសគ្គមួយដែលរារាំងមិនឱ្យកុមារីបានទៅសាលារៀនផងដែរ។

គេមើលឃើញជាទូទៅថា បញ្ហាជីវភាពគ្រូបង្រៀនដែលមានប្រាក់ខែតិចតួច និងអំពើពុករលួយ ក៏ជាកត្តានាំឱ្យមានការយកចិត្តទុកដាក់តិចដល់ការសិក្សាអប់រំជាទូទៅ។

ថ្លែងក្នុងកម្មវិធីក្រុមអ្នកស្ម័គ្រចិត្តអាមេរិក Peace Corps នៅខេត្តសៀមរាប លោកស្រី មីស៊ែល លើកឡើងថា "កាលណាក្មេងស្រីបានរៀនសូត្រចេះដឹង កាលណាពួកគេចេះអាន ចេះសរសេរ និងចេះវិភាគរិះគន់ពេលនោះពួកគេពិតជាមានមធ្យោបាយក្នុងការបញ្ចេញគំនិតតវ៉ាប្រឆាំងនឹងភាពអយុត្តិធម៌ និងទាមទារសិទ្ធិទទួលបានការយកចិត្តទុកដាក់ស្មើគ្នា។ មិនតែប៉ុណ្ណោះ ចំណេះវិជ្ជាទាំងនេះ អាចជួយឱ្យពួកគេចូលរួមក្នុងជីវភាពនយោបាយប្រទេសជាតិ និងមានឥទ្ធិពលធ្វើឱ្យមេដឹកនាំចេះទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន និងចេះតវ៉ាឱ្យមានការផ្លាស់ប្តូរដើម្បីបំពេញទៅតាមសេចក្តីត្រូវការចាំបាច់របស់ពួកគេ។

នៅទូទាំងប្រទេសកម្ពុជាមានសិស្សទាំងអស់២.៩លាននាក់។ ក្នុងចំណោមនោះ សិស្សស្រីមានតិចជាងពាក់កណ្តាល។ គម្រោង "ផ្តល់ឱកាសឱ្យសិស្សស្រីបានចូលរៀននៅសាលា" មិនត្រឹមតែមានបំណងបំបែកឧបសគ្គដែលរារាំងមិនឱ្យកុមារីបានចូលរៀនប៉ុណ្ណោះទេ។ គម្រោងនេះនឹងសហការជាមួយសហគមន៍ ដើម្បីទប់ស្កាត់ការបោះបង់ការសិក្សារបស់សិស្សស្រី និងផ្តល់ឱកាសអប់រំស្មើគ្នាដល់សិស្សស្រី ក៏ដូចជាលើកកម្ពស់សិស្សស្រី។



-មីស៊ែល អូបាម៉ា ប្រជុំតុមូលនៅ "Peace Corps "ស្តីអំពីវិស័យអប់រំកុមារី ក្នុងអង្គប្រជុំនោះក៏មានលោកឯកអគ្គរាជទូត វីលាមថដ និងអ្នកស្រីបណ្ឌិត ពុង ឈីវ គេក

លោក Alfonso Lenhardt ប្រធានរដ្ឋបាលស្តីទីរបស់ USAID បានគូសបញ្ជាក់នៅសេចក្តីថ្លែងប្រកាសបើកគម្រោងនេះថា "កាលណាយើងជ្រោមជ្រែងឱកាស ដើម្បីឱ្យស្ត្រីទទួលបានអំណោយជាចំណេះវិជ្ជា តាមរយៈគម្រោងឱ្យកុមារីបានសិក្សានេះ គឺដូចជាយើងបណ្តុះឱ្យមានគ្រូពេទ្យ វិស្វករ និងអ្នកអប់រំដែលអាចប្រែក្លាយសហគមន៍ដែលងាយរងគ្រោះឱ្យទៅជាសហគមន៍រឹងមាំ និងស្វាហាប់បាន"។

តាមការសិក្សាបង្ហាញថា ស្ត្រីដែលពុំបានទទួលការអប់រំនៅសាលាច្រើនតែមានជីវភាពលំបាក។ ចំណែកស្ត្រីដែលបានទទួលការអប់រំច្រើនជាស្ត្រីដែលមានជីវភាពគ្រាន់បើ។

លោកស្រី មីស៊ែល គឺជាស្ត្រីម្នាក់ដែលរៀនចប់នៅសាលាសាកលវិទ្យាល័យ Harvard ផ្នែកមេធាវី។ លោកស្រីមានប្រសាសន៍ថា លោកស្រីកើតក្នុងត្រកូលគ្រួសារខ្វះខាត។ ប៉ុន្តែលោកស្រីខិតខំតស៊ូរៀនសូត្រនៅសាលា។ ដោយសារបានទទួលការអប់រំច្រើនពីសាលា ទើបជីវិតលោកស្រីមានការផ្លាស់ប្តូរគួរជាទីមោទនៈ។ លោកស្រីថា ការអប់រំគឺជាចំណុចចាប់ផ្តើមនៃឱកាសជាច្រើនក្នុងឆាកជីវិតរបស់លោកស្រី។ លោកស្រីសង្ឃឹមថា ការចែករំលែកអំពីបទពិសោធន៍នៃការអប់រំរបស់លោកស្រីនឹងធ្វើឱ្យកុមារីក្នុងលោកយកគម្រាប់តាម។

កាលពីថ្ងៃអង្គារ បីថ្ងៃមុនលោកស្រី មីស៊ែល អូបាម៉ា ធ្វើដំណើរដល់ប្រទេសកម្ពុជាអ្នកភូមិបឹងកក់ និង សកម្មជនសិទ្ធិជីធ្លីប្រហែល៨០នាក់បានប្រមូលផ្តុំគ្នានៅមុខស្ថានទូតអាមេរិកក្នុងទីក្រុងភ្នំពេញ ដើម្បីអំពាវនាវសុំឱ្យលោកស្រីធ្វើអន្តរាគមន៍ដោះលែងអ្នកភូមិបឹងកក់ និងព្រះសង្ឃពីរអង្គដែលកំពុងជាប់ឃុំនៅគុកព្រៃសរ។

នៅថ្ងៃសុក្រ ទី២១ ខែមីនា ឆ្នាំ២០១៥ សកម្មជនដីធ្លីមកពី៨សហគមន៍បានធ្វើបាតុកម្មនៅមុខស្ថានទូតអាមេរិកប្រចាំនៅប្រទេសកម្ពុជាម្តងទៀត ដើម្បីសុំឱ្យលោកស្រី មីស៊ែល អន្តរាគមន៍ឱ្យរដ្ឋាភិបាលខ្មែរដោះលែងស្ត្រីបឹងកក់ដែលជាប់ឃុំទាំង១១នាក់។

១២ថ្ងៃមុនដំណើរទស្សនកិច្ចលោកស្រី មីស៊ែល រដ្ឋាបាលលោក ហ៊ុន សែន បានដោះលែងអ្នកទោសស្ត្រី២២នាក់ ដែលកំពុងមានផ្ទៃពោះ ឬមានកូនតូចមកតាមនៅក្នុងគុក។ ក្នុងចំណោមស្ត្រីអ្នកទោសដែលត្រូវបានដោះលែងនោះមានស្ត្រីម្នាក់ជាប់ទោសពីបទប៉ុនប៉ងមនុស្សឃាតដោយការចាក់ទឹកអាស៊ីតផងដែរ។ ប៉ុន្តែគ្មានស្ត្រីអ្នកភូមិបឹងកក់ណាម្នាក់ស្ថិតក្នុងចំណោមអ្នកដែលត្រូវដោះលែងទាំងនោះ នោះឡើយ។

ដូចការគ្រោងទុកលោកស្រី មីស៊ែល មិនជួបលោក ហ៊ុន សែន ទេ។ ប៉ុន្តែលោកស្រី ប៊ុន រ៉ានី ដែលជាភរិយាលោក ហ៊ុន សែន បានទៅទទួលលោកស្រី មីស៊ែល នៅព្រលានយន្តហោះអន្តរជាតិខេត្តសៀមរាប។



បាតុករដីធ្លីសូមឱ្យលោកស្រី មីស៊ែល អូបាម៉ា ជួយអន្តរាគមនៅមុខស្ថានទូតអាមេរិក

តទៅទំព័រទី ២៦

# វត្តត្រៃរតនារាមនឹងបោះឆ្នោត

**ខ្មែរផុសស.រ.អា.**

នៅមួយសប្ដាហ៍មុនការបោះឆ្នោតដែលថាបង្រួបបង្រួមវត្តត្រៃរតនារាមយើងបានធ្វើការសាកសួរដូចតទៅ:

**លោក ជា តែម** ដែលបានក្លាយជាគណកម្មការរៀបចំការបោះឆ្នោតម្នាក់ក្នុងចំណោម៥ បាននិយាយថា "ខ្ញុំកំពុងរៀបឱ្យមានការបោះឆ្នោតនៅវត្តជ្រើសរើសឱ្យមានប្រធានវត្តថ្មីម្នាក់នៅថ្ងៃទី២៩មីនាខាងមុខ ដើម្បីឱ្យប្រធានថ្មីនោះជ្រើសរើសសមាជិកឯទៀតៗរបស់ខ្លួននៅ១០ថ្ងៃបន្ទាប់មក... ឈ្មោះបេក្ខជនប្រធានវត្តមិនទាន់អាចឱ្យដឹងបាននៅ២-៣ថ្ងៃមុនថ្ងៃបោះឆ្នោតតែប៉ុណ្ណោះ... នេះជាន័យនៃលក្ខខិកៈដែលខ្ញុំមានយកមកអនុវត្ត"នៅពេលសួរថា តើគណកម្មការខាងក្រោមមានបានត្រូវទាក់ទងហើយឬនៅ? លោក ជា តែម បានឆ្លើយថា "នេះជាសិទ្ធរបស់គេខ្ញុំបានធ្វើការផ្សព្វផ្សាយទូលំទូលាយអស់ ហើយមានទាំងតាមទូរទស្សន៍ផង បើគេចង់មកអាចមកបាន!" ។

**លោក ប្រាហ៊ឹម កែ** ប្រធានវត្តលើ បាននិយាយថា "តុលាការបានចេញបញ្ជាឱ្យធ្វើការបោះឆ្នោត ដូច្នេះយើងនឹងរៀបចំការបោះឆ្នោតនោះ... មានព្រះសង្ឃមានយាយតានឹងអ្នកជើងវត្តបានមូលមាត់គ្នាតែងតាំងគណកម្មការបោះឆ្នោតមួយរួចហើយ នៅថ្ងៃ២៩យើងធ្វើបុណ្យផ្កានៅពេលព្រឹកពេលល្ងាចយើងបោះឆ្នោត...ខ្ញុំនឹងមិនឈរជាប្រធានទៀតទេ" ។

**លោក សាន ប៊ិន** ប្រធានវត្តក្រោមបានឱ្យដឹងថា "ខ្ញុំមិនបានចូលរួមក្នុងការបោះឆ្នោតនោះទេ ពីព្រោះគេមិនបានពិគ្រោះជាមួយយើងទេ លិខិតបញ្ជាឱ្យបោះឆ្នោត ក៏ខ្ញុំមិនទាន់បានទទួលដែរ តែមេធាវីខ្ញុំបានធ្វើការទាក់ទងទៅចៅក្រមរកការពន្យល់រួចហើយ យើងរង់ចាំចម្លើយជាពិសេសលើករណីអ្នកដែលទៅលួចខ្ទាស់គន្លឹះទ្វារពីខាងក្នុងមិនឱ្យយើងចូលទៅបើកទ្វារបាន... យើងជាគណកម្មការដែលគេទទួលស្គាល់តាមផ្លូវច្បាប់មិនអាចឱ្យមានការរំលោភមកលើយើងបានទេ..." ។



វត្តត្រៃរតនារាមត្រូវគេខ្ទាស់ទ្វារពីខាងក្នុង ក្រុមវត្តក្រោមចូលក្នុងមិនបាន

នៅពេលសួរថា តើការបោះឆ្នោតឱ្យចេញបានជាវត្តតែមួយនោះវាទៅជាយ៉ាងណាដែរ? លោក សាន ប៊ិន ឆ្លើយថា "ចង់ធ្វើវត្តត្រៃរតនារាមឱ្យទៅជាតែមួយក៏ជាបំណងរបស់យើងដែរ តែត្រូវមានការពិគ្រោះគ្នាស្វែងរកគោរពក្បួនច្បាប់ឱ្យបានត្រឹមត្រូវ...ខាងលើគេធ្លាប់ធ្វើការបោះឆ្នោតរបៀបនេះរួចហើយទេតើ? មិនមែនតែម្ដងនេះទេ!... ឥឡូវនេះខ្ញុំកំពុងរង់ចាំចម្លើយពីមេធាវីយើង!!!"

គណកម្មការបោះឆ្នោតមាន: លោក ជា តែម - ម៉ម សំណាង - ប្រាក់ សារី - ជា ថាង - ឱ ស៊ីវុត្ថា ៕

## តមកពីទំព័រទី ០៣ "ប្រេសក្លឹប"ជាអ្វី?

"គេបានសម្រេចរួចហើយពុំមានការសួរយោបល់អ្វីទៀតទេ ហើយថវិកាសម្រាប់សង់នោះជាអំណោយរបស់ឧត្ដមសេនីយទោ ហ៊ុន ម៉ាណែត នៅកម្ពុជា" ។ នៅពេលជាដែលនោះ មានគម្រោងមួយទៀត របស់សាលាក្រុងឡូវែលចង់ឱ្យមានរូបសំណាកវប្បធម៌ខ្មែរ ដាក់នៅមុខសាលាក្រុងដែរ តើនរណាចង់សង់អ្វីខ្លះ? នៅត្រង់ណា?

ខ្មែរផុសស.រ.អា.បានបង្កើតវេទិកាសេរីមួយថ្មីទៀត មានឈ្មោះថា "ប្រេសក្លឹប" នៅថ្ងៃទី៩ មេសាខាងមុខវេលាម៉ោង១២ថ្ងៃត្រង់ដល់ម៉ោង២រសៀលនៅ LTC ១-សម្រាប់ជូនដំណឹង ឬឃោសនាពីទ្រង់ទ្រាយនៃគម្រោងសាងសង់រូបព្រហ្មបាយ័នមួយដែលនឹងកើតឡើងនៅក្រុងខ្មែរនឹងគម្រោងមួយទៀតស្ដីពីរូបសំណាក់លក្ខណៈខ្មែរនឹងដែលដាក់មុខសាលាក្រុង ២-សម្រាប់សាធារណជនមូលដ្ឋានមកបញ្ចេញការចាប់អារម្មណ៍ពីការកសាងសម្មិទ្ធទាំងនោះ ហើយ៣-ព័ត៌មានទាំងឡាយដែលប្រមូលបានពីក្នុង"ប្រេសក្លឹប"នោះ នឹងត្រូវផ្សព្វផ្សាយយ៉ាងទូលំទូលាយតាមកាសែតខ្មែរផុស ឬកាសែតដ៏ទៃឱ្យអ្នកឯទៀតដែលមិនបានមកចូលរួមបានដឹងដែរទៀតផង ។ ដូច្នេះការដឹងច្បាស់លាស់នឹងទូលំទូលាយរបស់សាធារណជនពីគម្រោងរបស់ក្រុងខ្មែរនឹងរបស់សាលាក្រុង គេអាចនឹងបង្កើតបាននូវសម្មិទ្ធិដ៏ល្អមួយប្រកបដោយមោទនភាពនឹងភាពចុះសម្រុងគ្នាបាន ។ ផ្ទុយទៅវិញ បើមានការលបធ្វើអ្វីដោយស្ងាត់កំបាំង ឬក៏ផ្សព្វផ្សាយមិនគ្រប់គ្រាន់លើគម្រោងសាធារណ គឺជាការរំលោភឆន្ទៈសាធារណជន គឺជាការបង្កើតជម្ងឺសង្គមដែលថ្នាក់ដឹកនាំគួរតែចៀសវាង ។

ខ្មែរផុសស.រ.អា.នៅពេលបង្កើតឱកាស "ប្រេសក្លឹប"នេះឡើង គឺប្រាថ្នាផ្ដល់ជូនសហគមន៍ខ្មែរនៅឡូវែលដែលបែកបាក់ខ្ទេចខ្ទាំទន់ខ្សោយនឹងកំពុងបន្តរជំងឺកាន់តែខ្លាំងទៅៗនោះ នូវមធ្យោបាយដោះស្រាយសង្គមមួយដែលត្រូវបើកចំហរទទួលយកនូវការព្យាបាលដោយប្រើ"មតិសាធារណជនមូលដ្ឋាន"ដោយថ្នាំមានឈ្មោះថា "តម្លាភាព"របស់សង្គម ៕

Continued from page 03

## What is Press Club?

No further opinion needs to be sought. The budget for the monument is a gift from Major General Hun Manet of Cambodia. Period. At the same time another project by the City of Lowell to erect another cultural monument in the front area of the City Hall is in a pipe line. Who wants to build what? At which place?

The Khmer Post USA has launched a Public Forum called "Press Club" to be held on April 9, 2015 from 12-2 pm at the LTC. The main purposes of the event are as follows:

1) To inform or raise awareness to the public of the Prum Bayon monument which is slated to erect in Cambodia town and another project to build a Khmer monument at the City Hall;

2) To offer the space for local people to express their opinions concerning the projects and

3) To publicize the information collected during the Press Club in the Khmer Post or other news media so that the public is well informed.

Public awareness and inclusion in the projects by the Cambodia Town and the City of Lowell will not only make the projects meaningful but it also makes the community feel proud, consent and harmonized. On the contrary if a public project is viewed as having been implemented discretely or lack publicity it is hard not to betray the will of the public. It therefore will eventually create a social misconduct which each leader shall refrain from committing.


ជួបជុំ"ប្រេសក្លឹប" ពីឆ្នាំមុន
មើលសេចក្ដីរាយការណ៍តាមវីដេអូ

When creating the Press Club, the Khmer Post wanted nothing but to lend a hand as a tool for the Khmer community of Lowell which is very divided, weak and vulnerable so that it could bebrought back together and to make them stronger and harmonized. This can be done through a fair access to information, openness and respect of public opinion. "Transparency" is the best medicine to bring the society together.

# អំពីទីក្រុងនៅតំបន់ Greater Merrimack Valley


Deb Belanger

**ដោយ** Deb Belanger
**ប្រែសំរួលដោយ**
**ថាច់ វណ្ណា**

ឥឡូវរដូវកាលផ្ការីកឈានចូលមកដល់ហើយ។ អារម្មណ៍របស់យើងក៏ចាប់ផ្តើមស្រស់ស្រាយ រីឯរដូវដាំដំណាំក៏ចាប់ផ្តើម។ សូមអញ្ជើញចូលរួម និងជួប Steve Verrill នៅថ្ងៃសៅរ៍ ទី២៨ ខែមីនា ពីម៉ោង១០ដល់ថ្ងៃត្រង់ នៅចម្ការ **Verrill Farm នៅអាសយដ្ឋាន១១ Wheeler Rd. Concord MA**។ ចម្ការ Verrill Farm ជាចម្ការលក្ខណៈគ្រួសារតាំងពីឆ្នាំ១៩២២ មានផ្ទៃដីប្រមាណ២០០អា។ លោក Steve នឹងផ្តល់ដំបូន្មាន និងឆ្លើយសំណួរលោកអ្នកមុននឹងលោកអ្នកចាប់ផ្តើមដាំដំណាំ! អ្នកចូលរួមត្រូវបង់ថ្លៃ១០ដុល្លារ ម្នាក់ ដោយមានបន្ថែមកាហ្វេ និងនំ muffins ទើបចំហុយថ្មីៗជូនពិសា។ សូមទាក់ទងទូរស័ព្ទលេខ៩៧៨-៣៦៩-៤៤៩៤ ដើម្បីកក់កន្លែងទុកមុន។ www.verrillfarm.com

កុំឱ្យឱកាសនេះរម្លងផុតឱ្យសោះ! សូមចូលរួមទស្សនាការតាំងពិព័រណ៍របស់**សារមន្ទីរប្រវត្តិសាស្ត្រវាយនភណ្ឌអាមេរិក** ដែលតាំងបង្ហាញស្នាដៃរបស់ "វិចិត្រករផ្នែកវាយនភណ្ឌៈ Picasso to Warhol" និងដាក់បង្ហាញពេញមួយថ្ងៃអាទិត្យ ទី២៩ ខែមីនា។ នេះជាកម្មវិធីចាប់ផ្តើមសម្ពោធដាក់តាំងស្នាដៃសិល្បៈកម្រជាង២០០ផ្ទាំងដែលសាធារណជនមិនដែលធ្លាប់បានឃើញពីមុន។ ស្នាដៃទាំងនេះគឺជាស្នាដៃវិចិត្រក្នុងសហសម័យ នាសតវត្សទី២០ ដែលឆ្លុះបញ្ចាំងឱ្យឃើញការប្រឹងប្រែងរបស់វិចិត្រករក្នុងការធ្វើឱ្យស្នាដៃសិល្បៈរបស់ខ្លួនមានភាពរស់រវើក និងពាក់ព័ន្ធខ្លាំងទៅនឹងជីវភាពប្រចាំថ្ងៃរបស់មនុស្សទូទៅ។

ផ្ទាំងពិពណ៌ទាំងនោះ មិនគ្រាន់តែសម្រាប់ព្យួរតាមជញ្ជាំងប៉ុណ្ណោះទេប៉ុន្តែ គេអាចយកមកពាក់ និងក្រាលជាកម្រាល និងទ្រាប់អង្គុយបានផងដែរ។ របស់ដាក់តាំងបង្ហាញមានតាំងពីសម្លៀកបំពាក់របស់ Pablo Piscasso និងក្រវ៉ាត់ករបស់ Salvador Dali រហូតដល់កន្ទេល Ben Nicholson និងកម្រាលពូក Saul Steinberg។

Picasso to Warhol ចាប់អារម្មណ៍លើប្រវត្តិសាស្ត្រនៃសិល្បៈក្នុងវិស័យវាយនភណ្ឌនាសតវត្សទី២០។ ស្នាដៃទាំងនោះ រួមមានស្នាដៃរបស់ Georges Braque, Alexander Calder, Marc Chagall, Salvador Dalí, Sonia Delaunay, Raoul Dufy, Barbara Hepworth, Fernand Léger, Henri Matisse, Joan Miró, Henry Moore, Pablo Picasso, Ben Nicholson និង Andy Warhol. www.athm.org

**សូមអបអរសាទរដល់ Stonehedge Inn និង Spa មានទីតាំងនៅ១៦០ Pawtucket Blvd in Tyngsboro** ដែលបានទទួលរង្វាន់ធ្វើម្ហូបឆ្ងាញ់ "Culinary Award" ឆ្នាំ២០១៥ ក្នុងការប្រជែងធ្វើម្ហូប North Bowl Soup Competition កាលក្នុងពិធីបុណ្យរដូវត្រជាក់កន្លងមក។ មុខម្ហូបដែលពួកគេឈ្នះរង្វាន់ គឺអាហារ Tuscan សណ្តែកស និងសាច់ក្រក រួមជាមួយ ស៊ុបស្ពៃ! ក្រុមចុងភៅរបស់ពួក គេបង្កើតមុខម្ហូបប្រចាំរដូវ និងមុខម្ហូបថ្ងៃត្រង់ប្រចាំពីរសប្តាហ៍ម្តងដែលអាចកុម្ម៉ង់មុនផ្សំគ្រឿងថ្មីស្រស់ផ្គាប់ចិត្តអ្នកក្រុង។ រាល់រាត្រីថ្ងៃព្រហស្បតិ៍នៅចាប់ពីម៉ោង៧យប់តទៅ សូមរីករាយកំសាន្តតន្ត្រីប្រគុំផ្ទាល់ដោយតន្ត្រីករល្បីៗប្រចាំទីក្រុងដែលសំដែងនៅបារ៍ទើបកែលម្អថ្មីរបស់ពួកគេ។ រាល់ថ្ងៃអាទិត្យចាប់ពីម៉ោង១០ព្រឹកដល់ម៉ោង២រសៀល Stonehedgeman ក្រុមតន្ត្រី Jazz ប្រគុំផ្ទាល់ និងអាហារប៊ូហ្វេឆ្ងាញ់ពិសារួមនឹងស្រាក្រឡុក៕

www.stonehedgeinnandspa.com



# About Town in the Greater Merrimack Valley

**By Deb Belanger**

With Spring officially upon us, now is the time to get in the mood to get out and garden. Join Steve Verrill on Saturday, March 28, from 10 am - noon at **Verrill Farm, 11 Wheeler Rd in Concord, MA.** Verrill Farm has been a family farm since 1922 and consists of about 200 acres. Steve will give tips & answer your questions before your planting begins! Fee is $10.00 per person and includes coffee & freshly baked muffins from the farm stand kitchen. Please call 978.369 .4494 for reservations. www.verrill-farm.com



**Don't miss the American Textile History Museum's exhibit** "Artist Textiles: Picasso to Warhol" on display through Sunday, March 29th. This groundbreaking exhibition with over 200 rare pieces, many never before seen on public display, from the masters of 20th century modern art reflects the effort of artists to make their work less elitist and more relevant to the lives of ordinary people. Not merely to be hung on a wall, these pieces were to be worn and walked upon and sat upon, from a Pablo Picasso dress and a Salvador Dalí tie to a Ben Nicholson rug and Saul Steinberg bed sheet. Picasso to Warhol traces the history of 20th century art in textiles. Highlights include work by Georges Braque, Alexander Calder, Marc Chagall, Salvador Dalí, Sonia Delaunay, Raoul Dufy, Barbara Hepworth, Fernand Léger, Henri Matisse, Joan Miró, Henry Moore, Pablo Picasso, Ben Nicholson and Andy Warhol. www.athm.org

**Congratulations to the Stonehedge Inn and Spa, located at 160 Pawtucket Blvd in Tyngsboro,** for taking home the "Culinary Award" at the 2015 North Bowl Soup Competition during Lowell Winterfest with their Tuscan White Bean with Sausage & Kale soup! Their culinary team creates seasonal menus as well as a bi-weekly pre-fixe lunch menu with fresh, local ingredients that are sure to please your taste buds. Every Thursday Night from 7pm onwards enjoy live music by great local musicians in their newly renovated bar. Also, every Sunday from 10:30am -2:00pm the Stonehedge offers a Jazz Brunch with live jazz music, a delicious buffet spread and exciting cocktails.

www.stonehedgeinnandspa.com

adventures await

Greater Merrimack Valley
Convention & Visitors Bureau

For more fun things to see & do
and great places to eat & stay, visit...
www.merrimackvalley.org

**Continued from page 15**

# Kem Sokha Was Unhappy With...

legitimization of the CPP's election victory, the ruling party agreed to relinquish control over the National Election Committee to allow for equal representation by the CNRP on the body before the next elections in 2017 and 2018.

Mr. Sokha appeared unimpressed with the deal on the day of its signing, standing outside the Senate with a pronounced grimace as Mr. Rainsy and other opposition officials grinned and shook hands with Mr. Hun Sen and other members of the CPP delegation.

The deputy opposition leader suggested Friday that he felt at the time that the agreement gave Mr. Hun Sen too much leverage over the opposition—a prediction that came true in later negotiations—but said that splitting with Mr. Rainsy could have led the opposition back to a time when the two leaders led their own warring parties.

"I knew in advance that when we joined the National Assembly, everything would be in his hands," he said of Mr. Hun Sen. "Without the unity between the Sam Rainsy Party and the Human Rights Party, there would not have been that [election] day when people stood up across the nation."

"What the ruling party is most scared of is unity, and if we have different views on policies and break up due to this, we are losing before we even fight," Mr. Sokha said. "We are patient, and we swallow gravel and rocks in order to continue to make our unity stronger and not be tricked by the dictatorial ruling party."

Mr. Sokha said compromises are necessary in politics if leaders want to avoid the bloodshed and disunity of bloody revolutions.

"Our intention was to change things completely but we know that developments in politics do not always go as we wish," he said. "Sometimes we cannot implement [changes] 100 percent, because we are not making a revolution.

"We know and have experienced that when there is a revolution, the Khmer always lose. Each Khmer side loses and dies, and neighboring countries take advantage."

Contacted by phone Monday, opposition leader Sam Rainsy acknowledged that Mr. Sokha opposed the deal with the CPP when first presented with it, but said the CNRP vice president later came to recognize its necessity.

"What is important is, in the end, we came to the same conclusion and agreed to move forward, and this is the most important thing in any organization," Mr. Rainsy said.

"Between several people, there are always some points where we disagree, but we have to make sure that we agree from the very beginning that if we have some divergences, in the end we came to the same conclusion."

The key provisions of the deal signed on July 22 by Mr. Hun Sen and Mr. Rainsy were first floated in April after a phone conversation between the leaders. However, Mr. Sokha—who was also visiting the U.S. at that time—appeared to veto the agreement.

"Our party has a democratic core, so when we want to do anything, there must be the signature of Kem Sokha, the vice president, and me, the president," Mr. Rainsy said on April 11 after the agreement fell through. "If we consider our heart, Kem Sokha and I are only one person."

Asked on Monday what led Mr. Sokha to agree to the deal three months later on July 22—exactly a week after the high-profile arrest of seven opposition lawmakers-elect—Mr. Rainsy said Mr. Sokha's views on the utility of the deal had changed.

"It was a matter of weighing the pros and cons, and then you come yourself to the conclusion that the pros outweigh the cons," Mr. Rainsy said. "Sometimes it is me who is reluctant to do something, but in the end I am convinced to join the opinion of the majority."

The opposition leader said that he and Mr. Sokha are now on the same page about the deal, and are focused on winning the next national election in February 2018.

"Now, Kem Sokha and I fully agree that it was worth playing the game," Mr. Rainsy said.

"The risk was worth taking, and now…we are realistic and we believe we can reach a position that is on the whole satisfactory."


ហ្វេយ៍មីកខេប ផ្ទះសម្រាប់ពិធីបុណ្យសព

**Fay McCabe Funeral Home**

105 Moore Street. Lowell, MA 01852

**978-459-9222**

បម្រើសហគមន៍ខ្មែរដោយការយកចិត្តទុកដាក់ កិត្តិយស
និងការគោរពជាង៣០ឆ្នាំមកហើយ

- Serving All Faiths បម្រើសេវាកម្មគ្រប់ជំនឿ
- Traditional Funerals កម្មវិធីបុណ្យសពជាលក្ខណៈប្រពៃណី
- Cremation Services មានផ្តល់សេវាបូជាសព
- Pre Arranged Funerals រៀបចំរោងមុនកម្មវិធីបុណ្យសព



Locates 1 mile from Glory Buddhist Temple, between Gorham St. & Lawrence St.

ទីកន្លែងនៅចំងាយ១ម៉ាយពីវត្តពន្លឺពុទ្ធចក្ក
ចន្លោះផ្លូវ Gorham St. & Lawrence St.

លោកអ្នកនឹងក្រុមគ្រួសារទទួលបាននូវការយកចិត្តទុកដាក់
និងការបម្រើល្អប្រពៃពីទីនេះ ។

www.faymccabe.com

មានបុគ្គលិកនិយាយភាសាខ្មែរ

តមកពីទំព័រទី ១៥

## លោក កឹម សុខា មិនពេញចិត្តនឹងកិច្ចព្រម...

លោកបានមានប្រសាសន៍បន្ថែមថា "យើងមានកិច្ចព្រមព្រៀងមួយក្នុងរយៈពេលខ្លីណាស់ ហើយវាមិនច្បាស់លាស់ឬក៏លម្អិតឡើយ ហេតុដូច្នេះកិច្ចព្រមព្រៀងនេះអាចបកស្រាយបានច្រើនយ៉ាង ប៉ុន្តែវាក៏ជាមូលដ្ឋានដើម្បីធ្វើការលើរឿងផ្សេងៗផងដែរ។ វាមិនមែនអាក្រក់ទាំងអស់នោះទេ ប៉ុន្តែវាមិនបានធ្វើឱ្យយើងពេញចិត្តទាំងស្រុងឡើយ"។

កិច្ចព្រមព្រៀងកាលពីថ្ងៃទី២២ ខែកក្កដា ដែលបានឯកភាពគ្នាអំឡុងកិច្ចប្រជុំមួយដែលដឹកនាំដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងលោក សម រង្ស៊ី នៅក្នុងព្រឹទ្ធសភាបានបញ្ចប់ការធ្វើពហិការមិនចូលសភារបស់គណបក្សសង្គ្រោះជាតិក្រោយការបោះឆ្នោតជាតិកាលពីឆ្នាំ២០១៣ ដែលមានភាពចម្រូងចម្រាសនោះ។

ដើម្បីជាថ្នូរនឹងការឱ្យគណបក្សប្រឆាំងទទួលស្គាល់ជ័យជម្នះនៃការបោះឆ្នោតរបស់គណបក្សប្រជាជនជាផ្លូវការគណបក្សកាន់អំណាចបានយល់ព្រមបោះបង់ចោលការគ្រប់គ្រងលើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីអនុញ្ញាតឱ្យគណបក្សសង្គ្រោះជាតិមានតំណាងស្មើគ្នានឹងគណបក្សប្រជាជនកម្ពុជានៅក្នុងស្ថាប័ននេះមុនការបោះឆ្នោតលើកក្រោយក្នុងឆ្នាំ២០១៧និងឆ្នាំ២០១៨។

លោក កឹម សុខា ទំនងជាមិនចាប់អារម្មណ៍លើកិច្ចព្រមព្រៀងឡើយក្នុងថ្ងៃមានការចុះហត្ថលេខាដោយលោកបានឈរនៅខាងក្រៅព្រឹទ្ធសភាសម្តែងកាយវិការមិនពេញចិត្ត ខណៈលោក សម រង្ស៊ី និងមន្ត្រីផ្សេងៗទៀតមកពីគណបក្សប្រឆាំងមានភាពរីករាយ និងចាប់ដៃគ្នាជាមួយលោក ហ៊ុន សែន និងសមាជិកផ្សេងៗទៀតរបស់គណបក្សប្រជាជនកម្ពុជា។

អនុប្រធានគណបក្សប្រឆាំងរូបនេះ បានលើកឡើងកាលពីថ្ងៃសុក្រថា លោកមានអារម្មណ៍នៅពេលនោះថា កិច្ចព្រមព្រៀងនេះ បានផ្តល់ឱ្យលោក ហ៊ុន សែន នូវឥទ្ធិពលយ៉ាងច្រើនលើគណបក្សប្រឆាំង ប៉ុន្តែថា ការបែកបាក់គ្នាជាមួយលោក សម រង្ស៊ី អាចធ្វើឱ្យគណបក្សប្រឆាំងត្រឡប់ទៅរកពេលមួយនៅពេលមេដឹកនាំពីររូបដឹកនាំគណបក្សប្រឆាំងរៀងៗខ្លួននោះ។

លោក កឹម សុខា បានមានប្រសាសន៍ទាក់ទិននឹងលោក ហ៊ុន សែន ថា "ខ្ញុំដឹងជាមុនរួចស្រេចហើយថា នៅពេលយើងចូលរួមនៅក្នុងរដ្ឋសភាអ្វីៗនឹងស្ថិតនៅក្នុងកណ្តាប់ដៃរបស់លោក។ ប្រសិនបើគ្មានការរួបរួមគ្នារវាងគណបក្ស សម រង្ស៊ី និងគណបក្សសិទ្ធិមនុស្សទេនោះ គ្មានថ្ងៃប្រជាពលរដ្ឋក្រោកឈរឡើងទូទាំងប្រទេសដូចថ្ងៃឱ្យបោះឆ្នោតនោះឡើយ"។

លោក កឹម សុខា បានមានប្រសាសន៍បន្ថែមទៀតថា "អ្វីដែលគណបក្សកាន់អំណាចខ្លាចបំផុតនោះគឺការរួបរួមគ្នា ហើយប្រសិនបើយើងមានទស្សនៈខ្វែងគ្នាលើគោលនយោបាយ ហើយបែកបាក់គ្នាដោយសារតែបញ្ហានេះ យើងនឹងចាញ់មុនការប្រកួត។ យើងអត់ទ្រាំ ហើយស៊ូលេបគ្រួសលេបថ្ម ដើម្បីបន្តធ្វើឱ្យការរួបរួមគ្នារបស់យើងកាន់តែមានភាពខ្លាំងឡើង ហើយមិនចាញ់ល្បិចកលរបស់គណបក្សកាន់អំណាចផ្តាច់ការ"។

លោក កឹម សុខា បានលើកឡើងទៀតថា ការសម្របសម្រួលគ្នាគឺមានសារៈសំខាន់ណាស់នៅក្នុងឆាកនយោបាយ ប្រសិនបើមេដឹកនាំចង់កុំឱ្យកើតមានការធ្វើបដិវត្តដ៏បង្ហូរឈាមនោះ។

លោកបានមានប្រសាសន៍ថា "គោលបំណងរបស់យើង គឺដើម្បីផ្លាស់ប្តូរអ្វីទាំងស្រុង ប៉ុន្តែយើងដឹងហើយថា ការអភិវឌ្ឍនៅក្នុងឆាកនយោបាយមិនមែនចេះតែអាចទៅរួចតាមអ្វីដែលយើងប្រាថ្នានោះឡើយ។ ជួនកាលយើងមិនអាចធ្វើឱ្យមានការផ្លាស់ប្តូរ១០០ភាគរយបានឡើយ ព្រោះយើងមិនមែនកំពុងធ្វើបដិវត្តនោះទេ"។

លោកបានមានប្រសាសន៍បន្ថែមថា "យើងដឹងហើយធ្លាប់មានបទពិសោធន៍ថា នៅពេលមានការធ្វើបដិវត្តខ្មែរតែងតែខាតបង់។ ភាគីខ្មែរនីមួយៗខាតបង់ និងស្លាប់ ហើយប្រទេសជិតខាងទទួលបានផលប្រយោជន៍"។

នៅពេលទាក់ទងតាមទូរស័ព្ទកាលពីម្សិលមិញ លោក សម រង្ស៊ី មេដឹកនាំគណបក្សប្រឆាំងបានទទួលស្គាល់ថា លោក កឹម សុខា ពិតជាប្រឆាំងនឹងកិច្ចព្រមព្រៀងជាមួយគណបក្សប្រជាជនកម្ពុជាមែននៅពេលដំបូង ប៉ុន្តែថា ក្រោយមកអនុប្រធានគណបក្សសង្គ្រោះជាតិរូបនេះបានទទួលស្គាល់នូវសារប្រយោជន៍នៃកិច្ចព្រមព្រៀងនេះវិញ។

លោក សម រង្ស៊ី បានមានប្រសាសន៍ថា "អ្វីដែលជារឿងសំខាន់នោះគឺនៅទីបញ្ចប់យើងឆ្ពោះទៅកាន់គោលដៅតែមួយ ហើយយល់ព្រមធ្វើដំណើរឆ្ពោះទៅមុខ ហើយនេះគឺជារឿងសំខាន់បំផុតនៅក្នុងស្ថាប័នមួយ"។

លោកបានមានប្រសាសន៍បន្ថែមថា "រវាងមនុស្សនីមួយៗតែងតែមានទស្សនៈផ្សេងៗគ្នា ប៉ុន្តែយើងត្រូវតែប្រាកដថា យើងបានព្រមព្រៀងគ្នាចាប់តាំងពីដើមទីមកម្ល៉េះថា ប្រសិនបើយើងមានការខ្វែងគំនិតគ្នាមួយចំនួនតែទីបញ្ចប់យើងត្រូវតែមានគោលដៅរួមមួយ"។

បទប្បញ្ញត្តិសំខាន់ៗនៃកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខាកាលពីថ្ងៃទី២២ ខែកក្កដា ដោយលោក ហ៊ុន សែន និងលោក សម រង្ស៊ី ត្រូវបានស្នើឡើងជាលើកដំបូងកាលពីខែមេសា បន្ទាប់ពីមានការសន្ទនាគ្នាតាមទូរស័ព្ទរវាងមេដឹកនាំទាំងពីរ។ តែទោះជាយ៉ាងណា លោក កឹម សុខា ដែលក៏បានទៅបំពេញទស្សនកិច្ចនៅសហរដ្ឋអាមេរិកអំឡុងពេលនោះដែរនោះ ទំនងជាជំទាស់ទៅនឹងកិច្ចព្រមព្រៀងនេះ។

លោក សម រង្ស៊ី បានមានប្រសាសន៍ កាលពីថ្ងៃទី១១ ខែមេសា បន្ទាប់ពីកិច្ចព្រមព្រៀងបរាជ័យ "គណបក្សរបស់យើងមានស្ទូលប្រជាធិបតេយ្យ ហេតុដូច្នេះនៅពេលយើងចង់ធ្វើអ្វីមួយដាច់ខាតត្រូវតែមានហត្ថលេខារបស់លោក កឹម សុខា អនុប្រធានគណបក្ស និងខ្ញុំជាប្រធាន។ ប្រសិនបើយើងនិយាយទាក់ទងនឹងបេះដូងវិញ លោក កឹម សុខា ហើយនឹងខ្ញុំគឺជាមនុស្សតែមួយទៅហើយ"។

នៅពេលសួរកាលពីម្សិលមិញថា តើអ្វីទៅដែលជំរុញឱ្យលោក កឹម សុខា យល់ស្របនឹងកិច្ចព្រមព្រៀងបីខែក្រោយ ពោលគឺនៅថ្ងៃទី២២ ខែកក្កដា មួយសប្តាហ៍គត់បន្ទាប់ពីមានការចាប់ខ្លួនសមាជិកសភាជាប់ឆ្នោតមកពីគណបក្សសង្គ្រោះជាតិចំនួនប្រាំពីររូបនោះ លោក សម រង្ស៊ី បានលើកឡើងថា ទស្សនៈរបស់លោក កឹម សុខា លើសារប្រយោជន៍នៃកិច្ចព្រមព្រៀងនេះបានផ្លាស់ប្តូរ។

លោក សម រង្ស៊ី បានមានប្រសាសន៍ថា "វាគឺជាបញ្ហាដែលស្ថិតនៅត្រង់ការថ្លឹងថ្លែងគុណសម្បត្តិ និងគុណវិបត្តិ ហើយបន្ទាប់មកយើងត្រូវតែថ្លឹងថ្លែងថា គុណសម្បត្តិមានច្រើនជាងគុណវិបត្តិ។ ជួនកាលគឺរូបខ្ញុំទេ ដែលស្ទាក់ស្ទើរក្នុងការធ្វើអ្វីមួយ ប៉ុន្តែទីបញ្ចប់ខ្ញុំបានសម្រេចចូលរួមធ្វើតាមមតិភាគច្រើន"។

មេដឹកនាំគណបក្សប្រឆាំងរូបនេះបានលើកឡើងទៀតថា លោកនិងលោក កឹម សុខា ឥឡូវនេះកំពុងមានគំនិតដូចអំពីកិច្ចព្រមព្រៀងនេះ ហើយកំពុងតែផ្តោតលើការយកឈ្នះក្នុងការបោះឆ្នោតជាតិលើកក្រោយនៅខែកុម្ភៈ ឆ្នាំ២០១៨។

លោក សម រង្ស៊ី បានមានប្រសាសន៍បន្ថែមទៀតថា "ឥឡូវនេះ លោក កឹម សុខា ហើយនឹងខ្ញុំយល់ស្របទាំងស្រុងថា សមនឹងលេងហ្គេមនេះ។ វាសមនឹងប្រថុយ ហើយឥឡូវយើងប្រាកដនិយម និងជឿជាក់ថា យើងអាចឈានទៅដល់គោលដៅមួយដែលមានការពេញចិត្តទាំងស្រុង"៕

**ស៊ុយឈាង**



តមកពីទំព័រទី ១៧
## ព្រឹត្តិការណ៍សំខាន់នៅខាវអ៊ីដង...

បានថ្លែងសុន្ទរកថា អរគុណដល់បុគ្គលិកអង្គការទាំងអស់ដែលបានជួយខ្មែរក្នុងអតីតកាល ។ នៅថ្ងៃ១១មករា នាំគ្នាត្រឡប់មកណងចាន់វិញ ដើម្បីធ្វើបុណ្យបាំងស្កូលជូនកុសលដល់មនុស្សជាច្រើនដែលបានបាត់បង់ជីវិតនៅតាមផ្លូវសម្រុកចូលជំរុំភៀសខ្លួននឹងបានចែកអំណោយដល់ក្រុមគ្រួសារនឹងចាស់ទុំ កុមារា កុមារី នៅទីនោះ ។ លោកអភិបាលក្រុងឡូវែល ក៏គ្រោងនឹងចូលរួមពិធីបុណ្យណងចាន់នោះដែរ តែដោយអ្នកបើករថយន្តវង្វេងផ្លូវត្រូវខកខានគួរឱ្យស្តាយ។ បច្ច័យដែលចំណាយចាត់ចែងក្នុងពីធីបុណ្យប្រកបដោយជោគជ័យនោះ លោក ស៊ុម ប៊ូរីត និយាយថាបានមកពិពីធីបុណ្យផ្កា នៅវត្តពន្លឺពុទ្ធចក្រឡូវែល ដែលអ្នកប្តើមបុណ្យខ្មែរទាំងអស់ សូមថ្លែងអំណរគុណដល់ព្រះសង្ឃគណកម្មការវត្តនឹងពុទ្ធបរិស័ទជើងវត្តពន្លឺពុទ្ធចក្រយ៉ាងជ្រាលជ្រៅ។

ត្រឡប់មកវិញ ពោពេញដោយអារម្មណ៍ជ្រះថ្លា អ្នកដំណើរពីសហរដ្ឋគេនាំគ្នាប្រាថ្នាឱ្យមានព្រឹត្តិការណ៍ជួបជុំគ្នាដូចនេះម្តងទៀត នៅឆ្នាំ២០១៧ ដើម្បីត្រឡប់ទៅជួយក្រុមគ្រួសារខ្មែរតាមព្រំប្រទល់ភាគខាងលិចដែលនៅក្រីក្រខ្លាំងណាស់នៅឡើយ ៕





SAVINGS WITH MASS APPEAL

DRIVERS WHO SWITCHED SAVED

$498

NATIONAL ANNUAL AVERAGE

**Want to save on car insurance? Call me first.**

It's time Massachusetts drivers had a better car insurance experience. I'll help you get the coverage that's right for you and the discounts you deserve. Call me today.



**Vanessa Dinh**
**781-547-6522**
665 Main Street
Waltham
vanessadinh@allstate.com

Allstate. You're in good hands.

Savings based on national customer-reported data for new policies in 2012. Actual savings vary. Allstate Insurance Co. Northbrook, IL. © 2013 Allstate Insurance Co.



AccuCare Home Care Agency
Group Adults Foster Care Program

# Homecare Agency

Group Adult Foster Care Program (GAFC)
MassHealth

# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្តានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ



*Compassionate Care & Reliable*
*Professional & Cultural Sensitive*
*Management & Staffs speak Khmer*

*កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើង ដែលមានប ញ្ហារាំរ៉ៃផ្នែកសុខភាព ឬជរាហើយមិនចង់ ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្តល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។*

*Accucare Homecare Agency is the perfect solution for seniors and others who are not ready to leave their home for an institutional setting or live with reltives because of illness or chronic conditions. We improve your life by providing one-on-one compassionate senior care in the comfort of your own home.*

**ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :**

*To be eligibled for GAFC you must:*

- រស់នៅផ្ទះរដ្ឋ (live in subsidized or public housing)
- អាយុ ២២ ឆ្នាំឡើងទៅ (age 22 years and older)
- មាសហែលស្តង់ដា (eligible for Masshealth Standard)
- ត្រូវការជំនួយក្នុងការរស់នៅប្រចាំថ្ងៃយ៉ាងហោចណាស់មួយដូចជា មុជទឹក ស្លៀកពាក់ ពេលប្រើបន្ទប់ទឹក ចំអិនអាហារ ឬ ពេលដើរ (need daily assistance with one or more personal care tasks such as bathing, dressing, toileting, meal preparation and/or moving)
- មានការអនុញ្ញាតពីគ្រូពេទ្យផ្ទាល់ខ្លួនអ្នក (have physician statement of your condition)
- ត្រូវបានវាយតំលៃផ្នែកសុខភាព នឹងការអនុម័តយល់ព្រមពីកម្មវិធី (be screened and approved for the program )

**ផលប្រយោជន៍ទទួលបាន :**

*Benefits you will get:*

- ការថែទាំផ្ទាល់ខ្លួនមួយទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ (personal care service in your home, up to one hour of service each day)
- ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក (Medication Managemant)
- ផែនការថែទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីជើ (an individual care plan developed by a registered nurse and case manager)
- វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់ (ongoing monitoring of needs)
- សមាជិកអាចទាក់ទងមក ២៤ម៉ោង (24-hour access to services)

**ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed for Lowell, Lynn, Revere, and Boston**

**ដើម្បីចុះឈ្មោះសូមទាក់ទងមក**
To register, please contact:

ឱក តុលាយុត្តិ ឡូវែល
Tolayuth Ok: Lowell
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

## តមកទំព័រទី ១៤ កូនប្រុសមន្ត្រីគយជាប់សង្ស័យក្នុងការបាញ់...

ពីហេតុការណ៍នេះក្តីតែនគរបាលជាតិបានចុះផ្សាយនៅលើគេហទំព័ររបស់ខ្លួនថា កូនប្រុសរបស់លោក កែវ សុខឃាង ដែលជាប្រធានផ្នែកត្រួតពិនិត្យចល័តនៅក្នុងនាយកដ្ឋានគយ និងរដ្ឋាករនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺស្ថិតនៅក្នុងចំណោមក្រុមដែលធ្វើការបាញ់បោះនេះ។

ការចុះផ្សាយនៅលើគេហទំព័ររបស់នគរបាលជាតិបានលើកឡើងថា បងប្អូនប្រុសម្នាក់របស់ភរិយាលោក សុខឃាង និងអង្គរក្សម្នាក់ក៏ស្ថិតនៅក្នុងក្រុមនេះដែរ ប៉ុន្តែមិនបានបញ្ជាក់ថា តើនរណាជាអ្នកបាញ់បោះ ឬក៏ថាតើបាញ់អស់ប៉ុន្មានគ្រាប់នោះឡើយ។

លោក ហៀង ថារ៉េត អធិការរងនគរបាលខណ្ឌនេះបានលើកឡើងថា ការបាញ់បោះបានកើតឡើងនៅវេលារំលងអធ្រាត្រឈានចូលព្រឹកម្សិលមិញ។

លោកបានមានប្រសាសន៍ថា "ការបាញ់បោះនេះកើតឡើងនៅក្នុងមជ្ឈមណ្ឌលកម្សាន្តរ៉ុកនៅវេលាម៉ោង២និង១០នាទីរំលងអធ្រាតឈានចូលព្រឹកនេះដោយក្រុមរបស់កូនប្រុសប្រធានគយ ហើយបណ្តាលឱ្យបុរសយ៉ាងតិចម្នាក់រងរបួស"។

លោក រ័ត្ន ស្រ៊ាង មេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញបានលើកឡើងថា រថយន្តម៉ាកលុចស៊ីសមួយគ្រឿង និងកាំភ្លើងអាកា៤៧មួយដើមត្រូវបានរឹបអូសពីផ្ទះរបស់លោក សុខឃាង នៅក្នុងថ្ងៃដដែល ប៉ុន្តែលោកបានបដិសេធមិននិយាយច្រើននោះឡើយ ព្រោះករណីនេះត្រូវបានប្រគល់ទៅឱ្យនគរបាលរាជធានី ដើម្បីស្វែងរកជនសង្ស័យ។

គេមិនអាចទាក់ទងលោក ជួន សុវណ្ណ ស្នងការនគរបាលរាជធានីភ្នំពេញបានឡើយ។

សន្តិសុខយាមនៅច្រកចូលបុរីមួយក្នុងខណ្ឌសែនសុខ ជាទីដែលលោក សុខឃាង រស់នៅបានបញ្ជាក់ដោយនិយាយក្នុងលក្ខខណ្ឌអនាមិក ព្រោះព្រួយបារម្ភពីសុវត្ថិភាពផ្ទាល់ខ្លួនថា ពិតជាមានរថយន្តស៊េរីទំនើបមួយគ្រឿងត្រូវបានរឹបអូសមែន។ សន្តិសុខរូបនេះបានបន្ថែមថា ខ្លួនមិនបានឃើញនគរបាលចាប់នរណាម្នាក់បញ្ជូនទៅពន្ធនាគារឡើយនៅពេលនោះ។

សន្តិសុខរូបនេះបាននិយាយថា "ពួកគេគ្រាន់តែរឹបអូសរថយន្តប៉ុណ្ណោះ។ ខ្ញុំមិនបានឃើញនគរបាលចាប់ខ្លួនម្ចាស់រថយន្តឡើយ"។ សន្តិសុខរូបនេះបានបន្ថែមទៀតថា ខ្លួនបានឮនគរបាលនិយាយថា មានការបាញ់បោះប្រហែល៣០គ្រាប់នៅក្នុងមជ្ឈមណ្ឌលកម្សាន្តរ៉ុក។

ទាំងនគរបាល និងគេហទំព័ររបស់នគរបាលជាតិសុទ្ធតែមិនបានផ្តល់ព័ត៌មានទាក់ទិននឹងគោលបំណងនៃការបាញ់ប្រហារ ឬអត្តសញ្ញាណ ឬក៏ស្ថានភាពរបស់ជនរងគ្រោះនោះឡើយ។

ស្ថានីយទូរទស្សន៍ BTV ដែលគ្រប់គ្រងដោយលោកស្រី ហ៊ុន ម៉ាណា កូនស្រីរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបញ្ជាក់អត្តសញ្ញាណរបស់កូនប្រុសលោក សុខឃាង ថា មានឈ្មោះ កែវ វិទូ អាយុ២៤ឆ្នាំ៕ **ស៊ុយឈាង**


**KhmerPost USA, LLC**
សារពត៌មានខ្មែរផុសសហរដ្ឋអាមេរិក
អាស័យដ្ឋាន 45 Merrimack St. Suite 218A. Lowell, MA 01852
លេខទូរស័ព្ទ Phone: 978 677-7163 | Fax: (978) 677-7092
អ៊ីម៉ែល info@khmerpost.us
អានកាសែតនៅគេហទំព័រ www.khmerpost.us
តាមដានយើងនៅទំព័រហ្វេសប៊ុក Like us at: www.facebook.com/KhmerPostUSA
ផ្សាយពាណិជ្ជកម្ម Advertising
អគ្គនាយកទីផ្សារ និងគ្រប់គ្រង សុបិន្ត ពិន Soben Pin, *Managing Partner*
លេខទូរស័ព្ទ 978 - 656 - 8141 (Mobile) 978 677-7163 (Office)
អ៊ីម៉ែលsobenpin@khmerpost.us
អ្នកនិពន្ធ Editorials
និពន្ធនាយក ពិន សំខុន Roger Samkhon Pin, *Publisher & Editor-in-Chief*
(978) 942 - 1641 | rogerpin@khmerpost.us
អ្នកនិពន្ធកិត្តិយស **Contributed Writers:**
Kim Phien, Richard Howe,Jr.
ផ្នែកសោភ័ណភាពកាសែត **Design Artist**
Heng Chhunleng
នាយកដ្ឋបាល Office Manager **978-677-7163**
Thach Vanna ថាច់ វណ្ណា

KhmerPost USA, LLC is an independent newspaper that aims to facilitate mass communication among the Cambodian communities, their neighboring communities, and families. We aim to address local community, and national news; and give an insight into Cambodian & global news. We also strive to bridge the language and cultural gaps and reduce social isolation by publishing in Khmer & English. It published twice a month in Massachusetts serving Greater Lowell, Lynn, Revere, MA, Providence, RI, CT, NY, NJ, and Philadelphia, PA.

Mail subscription is available within the U.S. & Canada at 100.00 or 120 Euros in Europe per year.

The KhmerPost USA has full authorization from Bernard Krisher, the publisher of the Cambodia Daily to reproduce all the articles that are produced by the Cambodia Daily free of charge effective date: 6/19/2009




ហាងខ្មែរជួសជុលរថយន្ត
បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ
**Rathe's Auto Service**

State and Emission Inspaction General Repairs and Maintenance

MON-SAT, 8:30AM-5:30PM
SUN. EMERGENCY ONLY




- ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
- មានដូរប្រេង ដូរហ្វ្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
- មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ
- មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨ ទៅ : - ដូរប្រេងក៏រិត ៥ ក្វាត $22
- INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ តាក់ -មានជូនប័ណ្ណពិសេសសំរាប់ដូរប្រេងចុះថ្លៃពាក់កណ្តាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
- តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត ។
- ប្តេជាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ។ ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអរគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL : (215) 329-2418
Fax : (215) 329-2419. Rath CELL : (215) 431-6376

**ANGKOR AUTO SERVICE,INC.**
ហាងជួសជុលរថយន្ត "អង្គរ"

Free Estimate

Auto Body and Maintenance

BODY WORKS
Auto glass and windshields
Auto Frame Straightening and Painting



មានបទពិសោធន៏២០ឆ្នាំ ជាជាងរថយន្តមានសញ្ញាប័ត្រវាយតម្លៃការងារដោយឥតយកថ្លៃ ហើយយើងជួយសន្សំប្រាក់តម្លៃបន្ថយរបស់អិនស្វ៊ិនបានផង យើងផ្តល់សេវាគ្រប់យ៉ាង :

ENGINE AND TRANSIMISSION SERVICES
State Inspection
Check Engine Light Diagnostic
Timing Belt Services
Complete Tune Up:
-Brake -Muffler -Struts
-Water Pump -A/C
-Bearing Services



From the moment you get into car accident, we will take care of you from towing to calling your insurance, and to get a rental car for you. With Angkor Auto, you can be worried free.

4835 N. 16th Street. Philadelphia, PA 19141
Tel : (215) 455-7810 / Ricky : (215) 485-1425

ទស្សនៈអ្នកអាន

# គ.ជ.ប នៅក្រោមគំនាបសភា


លីម គិមយ៉ា

●●●ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្របានព្រាងរួចចំសព្វគ្រប់អស់ហើយ ដោយគណបក្សទាំងពីរ ដែលមានអាសនៈនៅសភា គឺគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ។ សេចក្តីព្រៀងនេះធ្វើហើយកាលពីថ្ងៃសុក្រទី ៦មិនា ២០១៥ ធ្វើសិក្ខាសាលានៅថ្ងៃចន្ទ័ទី៩ មិនា ២០១៥ ដោយមិនទុកឱ្យអ្នកចូលរួមដូចជាពួកអង្គការសង្គមស៊ីវិលមានពេលគ្រប់គ្រាន់សិក្សាពិចារណានោះទេ ដោយច្បាប់ទី១ មាន ៦៦ មាត្រានិង ២៣ទំព័រ និងច្បាប់ទី២ មាន១៧១ មាត្រានិង៧៣ទំព័រ ។

ច្បាប់ទាំងពីរនេះមានភាពចម្រូងចម្រាស់គ្នាក្នុងមាត្រាខ្លះ ហើយបិទសេរីភាពចំពោះបេក្ខជនក្នុងការឃោសនាសកម្មភាព និងពេលវេលាពី៣០ថ្ងៃ មកតែ២១ ដោយគ្មានមូលហេតុច្បាស់លាស់ និងចំនួនហែរក្បួនឃោសនាតែបួនដងក្នុងក្រុងស្រុក ខណ្ឌតែប៉ុណ្ណោះ ។

ចំពោះមាត្រា ៨៤ និង ១៤៨ ក្នុងច្បាប់ស្តីពីការបោះឆ្នោត ដូចជាមានការគាបសង្កត់ទៅលើសង្គមស៊ីវិលនេះជាលទ្ធផលនៃការចរចាកាលពីទី១៧ មិនា ២០១៤ ដោយតំរូវឱ្យមានអព្យាក្រឹត្យភាពនិងសុចរិតភាពនៃអង្គការសង្គមស៊ីវិល ។ ហេតុដូច្នេះហើយបានជាសង្គមស៊ីវិលជាង៦០ មិនគាំទ្រនឹងមិនធ្វើសិក្ខាសាលាទៀតផង ។

ក៏ប៉ុន្តែចំណុចទាំងនេះ ទោះជាអង្គការសង្គមស៊ីវិលជាង៦០ស្ថាប័នដែលធ្វើការទាក់ទងការបោះឆ្នោតមិនគាំទ្រ និងស្នើឱ្យដកចេញក៏ដោយ នៅទីបំផុតសេចក្តីព្រាងច្បាប់ទាំងពីរនេះនៅតែក្រុមការងារគណបក្សទាំងពីរបញ្ជូនឱ្យគណៈកម្មការសភាដើម្បីពិនិត្យ ។ រីឯការស្នើសុំរបស់សង្គមស៊ីវិលឱ្យយកច្បាប់នេះមកពិគ្រោះយោបល់ទៀតនោះ មិនត្រូវបានគណបក្សទាំងពីរយល់ព្រមនោះឡើយ ។

ប្រធានគណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរីនិងយុត្តិធម៌នៅកម្ពុជា ខុមហ្វ្រែល (Comfrel) លោក គល់ បញ្ញានិងជាតំណាងសម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត ហៅថា អ៊ីរ៉ា (ERA) មានប្រសាសន៍ថា បើសិនជាក្រុមការងារគណបក្សទាំងពីរមិនយកអនុសាសន៍ឬការស្នើសុំរបស់សង្គមស៊ីវិលទេនោះនឹងធ្វើឱ្យការបោះឆ្នោតនៅពេលខាងមុខប៉ះពាល់ដល់សិទ្ធិរបស់សង្គមស៊ីវិល កាត់បន្ថយគុណភាពបន្ថយការចូលរួមអ្នកសង្កេតការណ៍ស្ម័គ្រចិត្តប៉ះពាល់ដល់គណបក្សនយោបាយចូលរួមប្រកួតប្រជែងនៅពេលឃោសនាបោះឆ្នោត : (ហេតុផលដែលយើងចង់ឱ្យមានការកែប្រែហ្នឹងយើងនឹងបញ្ជូនឱ្យទៀតដើម្បីឱ្យដឹងពីអ្វីជាអាទិភាព ហើយអង្គការសង្គមស៊ីវិលនឹងជំរុញឱ្យដៃគូអភិវឌ្ឍន៍ និងដៃគូពាក់ព័ន្ធដទៃទៀតដើម្បីឱ្យដឹងពីច្បាប់នេះរឹតត្បិតសិទ្ធិសេរីភាព) ។

ការបញ្ជូនសេចក្តីព្រាងច្បាប់ទាំងពីរនេះទៅឱ្យគណៈកម្មការអចិន្ត្រៃយ៍រដ្ឋសភា និងបញ្ជូនឱ្យគណៈកម្មការនីតិកម្មនិងយុត្តិធម៌នៃរដ្ឋសភាពិនិត្យនេះហាក់ដូចជាធ្វើទៅតាមទំនោរចង់បានរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែល លោក ហ៊ុន សែន បានប្រកាសថា លោកមិនខ្វល់ពីការស្នើសុំរបស់អង្គការសង្គមស៊ីវិលមួយចំនួននោះឡើយ ។

ទោះជាយ៉ាងនេះក្តី លោក គល់ បញ្ញា អះអាងថា ក្រុមអង្គការសង្គមស៊ីវិលនឹងស្វែងរកអនុសាសន៍បន្ថែមនិងផ្ញើជូនក្រុមការងារគណបក្សទាំងពីរនៅមុនពេលសភាអនុម័តជាផ្លូវការ ។ លោកបន្ថែមថា អង្គការសង្គមស៊ីវិល នឹងធ្វើយុទ្ធនាការជាច្រើនទៀតដើម្បីឱ្យគណបក្សទាំងពីរទទួលយកអនុសាសន៍ទាំងនោះ ។

បើយើងមើលឱ្យលំអិតទៅលើច្បាប់នេះដូចជាមានមាត្រាខ្លះមិនស្របស្មារតីគ្នា ដូចជា: មាត្រា៦ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ចែងថា "សមាសភាពទាំង០៩ រូបនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវជ្រើសរើសដោយ:

០៤ រូបជ្រើសរើសដោយគណបក្សដឹកនាំរាជរដ្ឋាភិបាល

០៤ រូបជ្រើសរើសដោយគណបក្សមានអាសនៈក្នុងរដ្ឋសភាដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាល និង

០១ រូបទៀតជ្រើសរើសដោយមានការព្រមព្រៀងគ្នារវាងគណបក្សទាំងអស់ដែលមានអាសនៈក្នុងរដ្ឋសភា ។

....បែបបទ និងនីតិវិធីនៃការជ្រើសរើសបេក្ខជនសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវកំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា ។

ផ្អែកលើសមាសភាពដែលបានជ្រើសរើសខាងលើនេះ គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភាត្រូវរៀបចំបញ្ជីសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដាក់ជូនរដ្ឋសភា ដើម្បីបោះឆ្នោតទុកចិត្តតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល...។

ត្រង់នេះ បើបក្សដែលមានសំឡេងច្រើនក្នុងសភានឹងអាចធ្វើឱ្យមានទំនាស់ជៀសមិនរួច ។

មាត្រា១០ នៃច្បាប់ដដែលចែងថា "ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវមានគណនេយ្យភាពចំពោះមុខរដ្ឋសភា ។

ការសំរេចបណ្តេញចេញពីប្រធានអនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជាសមត្ថកិច្ចរបស់រដ្ឋសភា ។ ត្រង់នេះបញ្ជាក់យ៉ាងច្បាស់ថា បក្សដែលមានសំឡេងច្រើនក្នុងសភាអាចកៀបសង្កត់លើសមាជិកគ.ជ.បគ្រប់ពេលវេលា ។

ឯចំណែកច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រមានមាត្រាជាច្រើន ដែលមិនស្របស្មារតីសេរីភាពក្នុងការឃោសនា ដូចសង្គមស៊ីវិលបានលើកមកហើយ ។ ប៉ុន្តែមានមាត្រាខ្លះ ដូចជាក្រុមការងារព្រាងច្បាប់នៃគណបក្សទាំងពីរមិនបានគិតដល់ផលវិបាកនៃអ្នកមកបោះឆ្នោតនោះទេ ដែលយើងមានឧទាហរណ៍មកហើយតែយើងមិនព្រមយកមកធ្វើជាមេរៀនសោះ ។ ដូចជាមាត្រា១៦៩នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដែលអនុញ្ញាតឱ្យអាជ្ញាធរអាចចេញក្រដាសបញ្ជាក់អត្តញ្ញាណដើម្បីបោះឆ្នោតដែលពីដើមហៅថា ក្រដាស១០១៨ហើយ ក្រោយមកទៀត ហៅ១០១៩ ដែលកាលពីមុនគណបក្សជំទាស់តែងតែទាមទារឱ្យលុបចោល ។ តែមិនដឹងយ៉ាងដូចម្តេចក៏សុខចិត្តព្រមទៅវិញ ។

មតិមហាជននឹងចោទសួរ បើយ៉ាងដូច្នេះហេតុដូចម្តេចក៏គណបក្សសង្គ្រោះជាតិក៏សុខចិត្តជាមួយគណបក្សប្រជាជនកម្ពុជា បើច្បាប់ទាំងពីរមានភាពមិនប្រសើរនោះ ។ ចម្លើយគឺគណបក្សសង្គ្រោះជាតិមានបំណងធំ គឺទាមទាឱ្យដូរ គ.ជ.ប .គ.ជ.ប ដូរហើយ បានដូចបំណងមែន ។ តែទម្ងន់ពាក្យពេចន៍ខ្លះនៅក្នុងច្បាប់ទាំងពីរក្រុមការងារព្រាងច្បាប់របស់គណបក្សសង្គ្រោះជាតិដូចជាយល់មិនច្បាស់នៃផលវិបាកឬ មានគំនិត ដែលអាចធ្វើឱ្យមានផលវិបាកទៅអនាគតដល់គណបក្សសង្គ្រោះជាតិជាពុំខាន ។

**លិម គិម យ៉ា**
**តំណាងរាស្ត្រមណ្ឌលកំពង់ធំ**
**សមាជិកគណៈកម្មការសេដ្ឋកិច្ចហិរញ្ញវត្ថុធនាគារ និងសវនកម្មនៃរដ្ឋសភា**

តមកពីទំព័រទី ១៩ **លោកស្រី មីស្សែល អូបាម៉ា បំពេញ...**

ដំណើរទស្សនកិច្ចរបស់លោកស្រី មីស្សែល ជាលើកទីមួយដែលលោកជំទាវទីមួយរបស់អាមេរិកធ្វើដំណើរមកកាន់ប្រទេសកម្ពុជាក្នុងរយៈពេល៤៨ឆ្នាំ ។ កាលពីឆ្នាំ១៩៦៧ក្នុងសម័យសង្គមរាស្ត្រនិយមក្រោមរជ្ជកាលសម្តេច សីហនុ លោកស្រី Jacqueline KENNEDY ជំទាវទីមួយរបស់អាមេរិក និងជាភរិយារបស់លោកប្រធានាធិបតី John F. Kennedy បានមកធ្វើទស្សនកិច្ចរយៈពេល៦ថ្ងៃនៅកម្ពុជា ។ លោកស្រី មីស្សែល បានចាកចេញពីប្រទេសកម្ពុជានៅថ្ងៃអាទិត្យទី២២ ខែមីនា ឆ្នាំ២០១៥ ។

កាលពីចុងឆ្នាំ២០១២ លោកប្រធានាធិបតី បារ៉ាក់ អូបាម៉ា បានធ្វើទស្សនកិច្ចទៅប្រទេសកម្ពុជា ។ ប៉ុន្តែមន្ត្រីសេតវិមានបានអះអាងថា ការដែលលោក អូបាម៉ា ទៅទស្សនកិច្ចប្រទេសកម្ពុជា គឺដោយសារតែប្រទេសកម្ពុជាជាម្ចាស់ផ្ទះនៃជំនួបកំពូលប្រចាំតំបន់ដែលធ្វើប្រចាំឆ្នាំ ហើយថាគាត់ទៅកម្ពុជាដោយសារតែគោលនយោបាយអាមេរិកផ្តោតលើប្រទេសអាស៊ី ។ លោក អូបាម៉ា នៅពេលនោះហាក់មិនបង្ហាញទឹកមុខស្រស់ស្រាយបន្តិចសោះឡើយ ៕


មីស្សែល អូបាម៉ា ថតនៅមុខអង្គរវត្តជាមួយអ្នកនាំផ្លូវ

# CLASSIFIED ADS

**CALL: 978.677.7163**

EMAIL: SOBENPIN@KHMERPOST.US

## PICONICS..Inc

### ត្រូវការអ្នកជំនួយការទូទៅ

ក្រុមហ៊ុនផលិតកម្ម ឧបករណ៍អគ្គីសនី កំពុងត្រូវការអ្នកប៉ិនប្រសប់ជំរុញសមិទ្ធិផលឱ្យប្រសើរឡើង, ជាជំនួយការដល់ផ្នែកផលិតផលមានដំណើរការទៅមុខ, អ្នកដាក់ពាក្យសុំធ្វើការតម្រូវឱ្យមានសមត្ថភាពចេះអាន និងសរសេរភាសាអង់គ្លេស មានការស្ទាត់ជំនាញផ្នែកគ្រឿងម៉ាស៊ីន, ដៃ និងភ្នែកមានភាពសម្របគ្នា, អាច និងធ្វើការជាមួយអតិសុខុមទស្សន៍ បានរយៈពេលយូរ, អ្នកដាក់ពាក្យតម្រូវឱ្យមានសមត្ថភាពអាចធ្វើតាមពាក្យ ជាកិរិយាស័ព្ទធ្វើការណែនាំ, ដែលបានសរសេរ, មានការដកពិសោធន៍ក្នុងការដំឡើងឧបករណ៍អគ្គីសនីរយៈពេល២ ឬ៣ ឆ្នាំ, អាចប្រើដៃធ្វើការជាមួយដង្កាប់,ដង្កៀប ឬប្រដាប់ផ្សេងទៀត។

ក្រុមហ៊ុន Piconics, Inc ជាក្រុមហ៊ុនមួយផ្តល់ឱកាសស្មើភាពគ្នាដល់អ្នករកការធ្វើ និងផ្តល់គម្រោងសុខភាពយ៉ាងល្អប្រសើរ, មានឱកាសចូល៤០១ ឃេ(401K)

មានវិស្សមកាល និងម៉ោងឈប់សម្រាប់មានជម្ងឺ, និងរង្វាន់ផ្ទាល់ខ្លួនផ្សេងទៀត។

លោកអ្នកអាចផ្ញើជីវៈប្រវត្តិសង្ខេបតាមរយៈអ៊ីម៉ែល: jobs@piconics.com ឬដាក់លិខិតស្នើសុំនៅលេខ: ២៦ Cummings Road Tyngsboro, MA. 01879-1405

សូមកុំទូរស័ព្ទមករកយើងខ្ញុំ។

---

monroe STAFFING

1 OF STAFFING 360 SOLUTIONS

## ក្រុមហ៊ុនរកការងារ Monroe

**បានប្តូរមកនៅក្រុងឡូវែល សម្រាប់រកការងារជូនដល់លោកអ្នក ជាពិសេសផ្នែកឧស្សាហកម្មធុនស្រាល និងរោងចក្រផលិតកម្មក្នុងតំបន់ និងជុំវិញក្រុងឡូវែល -ម៉ូនរ៉ូ នឹងជួយផ្តល់ការងារ ផ្នែកប្រើម៉ាស៊ីន, ឈរជួរផលិត, ឃ្លាំងទំនិញ និងដំឡើងសង្វាក់ផលិតកម្មជាដើម។ សូមអញ្ជើញមកការិយាល័យយើងខ្ញុំនៅ លេខ៤០ Central St. Lowell, MA 01852, ដើម្បីធ្វើបែបបទ និងមានឱកាសជាច្រើនសម្រាប់រកការងារធ្វើ ៕**

---

**Your classify ad is here for only $50 per month**

ពាណិជ្ជកម្មរបស់អ្នកនៅទីនេះ

ចំណាយចំណាយត្រឹមតែ

**$50** ក្នុង១ខែ

*CALL:*

*978.677.7163*

*EMAIL:* SOBENPIN@KHMERPOST.US

---

## សិក្សាពីឥស្លាម

**សួរ :** មានចម្ងល់អ្វីទេពីឥស្លាម?

**ឆ្លើយ :** សូមទៅមើលគេហទំព័រ www.peacetv.tv ឬគេហទំព័រមួយទៀត www.gainpeace.com.

Q) Any Questions on Islam?

A)watch www.peacetv.tv visit www.gainpeace.com.

---

## ដំណឹងសាធារណៈ: អង្គការឡូវែលវ៉ូតស៍

អង្គការឡូវែលវ៉ូតស៍ជាអង្គការថ្មីមួយទើបបង្កើតឡើង ដើម្បីជម្រុញអ្នកចេញទៅបោះឆ្នោតឱ្យបានចំនួនច្រើនជាងមុន ជាពិសេសនៅតំបន់ដែលមានចំនួនអ្នកចេញទៅបោះឆ្នោតតិចតួច និងតំបន់ធ្លាប់ជួបឧបសគ្គក្នុងការចេញទៅបោះឆ្នោត។ អង្គការឡូវែលវ៉ូតស៍នឹងរៀបចំកិច្ចប្រជុំលើកដំបូងមួយនៅ**ថ្ងៃពុធ ទី១ ខែមេសា វេលាម៉ោង៦:៣០ល្ងាច**នៅឯសាលសហគមន៍ក្នុងបណ្ណាល័យ Pollard Memorial Library (អាសយដ្ឋានលេខ ៤០១ Merrimack St, Lowell)។ សាធារណជនទាំងអស់អាចចូលរួមក្នុងកិច្ចប្រជុំនេះបាន។ សូមអញ្ជើញចូលរួមទាំងអស់គ្នា។

## Public Notices

### LOWELL VOTES

Lowell Votes is a new organization committed to increasing the number of people who vote in city of Lowell elections, especially in neighborhoods with historically low turnout and among groups that have faced past barriers to voting. Lowell Votes will have its first meeting on Wednesday, April 1 at 6:30 pm at the Pollard Memorial Library's community room (401 Merrimack St, Lowell). The meeting is open to everyone. Please join us.

---

## ការិយាល័យ មេធាវី ថំមាស ស្ទាលីយ៉ាណូស

**Law Office of Thomas Stylianos Jr.**

**287 Appleton St. Lowell MA 01852**

- Immigration •អន្តោប្រវេសន៍
- Auto Crash •គ្រោះថ្នាក់រថយន្ត
- Divorce •លែងលះប្តីប្រពន្ធ

សូមទាក់ទង សោភា ឬ ធំ **978-459-5000 or 800-308-3766**

---

GREATER LOWELL CHAMBER OF COMMERCE

131 Merrimack Street – Lowell MA

**978-459-8154**

www.greaterlowellchamber.org

**A resource for your business or organization!**

Networking Events

Seminars

Resources

TV & Radio Shows

And more!

**សភាពាណិជ្ជកម្មនៅក្រុងឡូវែល គឺជាធនធានមួយសម្រាប់មុខរបរ ឬសម្រាប់អង្គការរបស់លោកអ្នក**

ព្រឹត្តិការណ៍ទំនាក់ទំនង

សន្និសីទ

រកធនធាន

កម្មវិធីទូរទស្សន៍ និងវិទ្យុ

និងនៅមានច្រើនទៀត

តមកពីទំព័រទី ០៦

## ដំណើរពីអាមេរិកទៅអាស៊ី...

របស់ចិនជាទូទៅដែលខិតខំរត់លូនឆ្លងកាត់គ្រោះថ្នាក់១ពាន់ជំពូក ពីដែនដីគោកមកកសាងជីវិតថ្មីនៅហុងកុងបានជោគជ័យស្មើរគ្រប់គ្នា ។ ការខិតខំថែរក្សាសង្គមពីគ្រួសារទៅដល់សង្គមប្រទេសជាតិបានល្អនេះ ធ្វើឱ្យចិនដីកោះហុងកុងនេះក្លាយទៅជាជើងឯកពីភពលោកខាងអ្នកចេះដឹងច្រើនខាងអ្នកមានសម្បត្តិស្តុកស្តម្ភខាងអ្នកផលិតខ្សែភាពយន្តខាងវប្បធម៌កីឡាថែរកម្លាំងកាយនឹងចិត្តខាងថ្នាំបូរាណធម្មជាតិ...។ល។ គឺជាគុណសម្បត្តិរាប់មិនអស់ដែលចិនហុងកុងបញ្ជូនពីប្រទេសខ្លួនទៅបរទេស ។ហើយ"លក្ខណៈសម្បត្តិ" នឹង"សំណាងល្អ" របៀបនេះ គេប្រទះឃើញដូចគ្នា នឹងហុងកុងនេះនៅសិង្ហបូរី នៅកោះតៃវ៉ាន់ នៅជប៉ុន នឹងនៅកូរ៉េខាងត្បូង...។

នាថ្ងៃចុងក្រោយដែលស្នាក់អាស្រ័យនៅហុងកុងនេះ យើងត្រឡប់ទៅផ្សារ"ឡេឌី"នោះម្តងទៀតក្នុងបំណងទិញរបស់អនុស្សាវរីយ៍ប្លែកៗខ្លះយកមកផ្ញើរមិត្តភ័ក្តិនៅអាមេរិក ។ នៅហុងកុងមានរបស់របរលក់ក្នុងតម្លៃខ្ពស់កប់ពពក ដូចនៅសហរដ្ឋអាមេរិកដែរ តែក៏ជាកន្លែងដែលមានលក់របស់ល្អដូចគ្នា ក្នុងតម្លៃថោកសម្រាប់ពលរដ្ឋទូទៅដែរ ដូចជាល្បែងក្មេងលេងគ្រឿងតុបតែងខ្លួនឧបករណ៍អេឡិកត្រូនិករបស់ប្រើប្រាស់ក្នុងផ្ទះ... ដែលធ្វើឱ្យយើងគិតថា របស់ថោកយ៉ាងនេះ តើលក់ចំណេញយ៉ាងណាទៅបាន? ចុងបញ្ចប់យើងងាកមកគិតខ្លីថា នេះជាគន្លឹះសម្ងាត់នៃពាណិជ្ជកម្មរបស់គេដែលបើរកស៊ីទៅវាខាតចុងខាតដើមគេនឹងមិនធ្វើទេ ។ ម្លោះហើយបានជានៅពេលចេញពីផ្សារនោះមកវិញ យើងមានកាន់ថង់នឹងកញ្ចប់រយីងរយោងពេញដៃគ្រប់គ្នាទាំងប៉ុណ្ណោះក៏មានរបស់ជាល្បែង"ថយ"របស់ខ្លួនដែរ ហើយទាំងអស់គ្នារីករាយណាស់ ដោយគិតថា បានទិញរបស់ផ្ញើរកូនក្មួយបានគ្រប់ៗគ្នា ។ យើងឡើងតាក់ស៊ីត្រឡប់មកសណ្ឋាគារយើងវិញ ពីគ្រោះគ្នាថាតើនឹងដាក់របស់របរដែលទើបនឹងទិញនោះយ៉ាងដូចម្តេច បើរបស់ច្រើនម្លឹងៗនោះ?

ថ្ងៃចេញដំណើរមកដល់យន្តហោះជាតហាយ. បាននាំដំណើរត្រឡប់របស់យើងបោះពួយសំដៅមកបូស្តុនវិញ បន្ទាប់ពីធ្វើដំណើរយ៉ាងគ្មានទៀយហាត់ចំនួន៦សប្តាហ៍ក្នុងប្រទេសចំនួន៤ មាន ថៃ កម្ពុជា កម្ពុជាក្រោមនឹងនៅហុងកុងមក ។ យើងអង្គុយយ៉ាងស្ងៀមស្ងាត់តែរៀង១ខ្លួន នៅក្នុងកៅអីយន្តហោះដ៏តូចចង្អៀតបង្ហើរអារម្មណ៍ទៅដល់ទេសភាព រូបភាពថ្មីៗ ស្មុគស្មាញ នៃព្រឹត្តិការណ៍ដ៏សន្ធឹកសន្ធាប់ដែលទើបកន្លងផុតទៅ ស្រាប់តែខ្ញុំនឹកទៅដល់ចម្រៀងស៊ិនស៊ីសាមុតបទ "រាត្រីនៅហុងកុង" របស់អ្នកចម្រៀងខ្មែរដ៏ល្បីល្បាញច្រៀងបំពេរខ្ញុំអោយលក់ស្កប់ស្កល់រហូតដល់ដល់មានគេដាស់ដើម្បីស្រស់ស្រូប ។ យើងចេញពីបូស្តុន នាចុងបញ្ចប់នៃរដូវក្តៅដល់ត្រឡប់មកដល់បូស្តុនវិញ ខ្យល់ត្រជាក់ក៏ផ្តើមធ្លាក់មកហើយដែរ ៕ **....ចប់ជាស្ថាពរ....**






តមកពីទំព័រទី ១២

## ទឹកដីកម្ពុជាក្រោម និង...

គេទទួលបានជំនួយទាំងសេដ្ឋកិច្ច និងយោធាតាមរយៈកំពង់ផែព្រៃនគរ ។

រហូតមកដល់ឆ្នាំ១៨០៤ស្តេចយួនឈ្មោះ យ៉ា ឡុង បានផ្លាស់ឈ្មោះ នគរ ដាយ វៀត ទៅជាចក្រភពវៀតណាមនេះជាការផ្លាស់ឈ្មោះលើកទី២០រួចមកហើយ និងមានការផ្លាស់ឈ្មោះចំនួន៨ទៀត រហូតដល់ឆ្នាំ១៩៧៥ ទើបវិលមកយកឈ្មោះវៀតណាមម្តងទៀត ។

ទោះជាយ៉ាងនោះក៏ដោយ, លោក សឺន គុយ បានលើកទ័ពប្រឆាំងតទល់អស់រយៈពេល៤៤ឆ្នាំ ទើបព្រមទទួលនៅការចរចាពីស្តេចយួនឈ្មោះ ង្វៀន ផុក ដាម (Nguyen Phuc Dam) នាម ថា: ម៉ិញ ម៉ាង (Minh Mang) កូនប្រុសពៅបង្អស់របស់ស្តេចយួន នាម: យ៉ា ឡុង (Gia Long) បន្ទាប់ពីកិច្ចចរចានេះយួនក៏បានកាត់ក្បាលលោកចៅហ្វាយ សឺន គុយ នៅឆ្នាំ១៨៤១ ៕






# តមកពីទំព័រ ២៧ ព្រំប្រទល់ដែនកម្ពុជាមិនច្បាស់លាស់

-ធុកឲ្យមានកំហឹងជាតិនិយមប្រឆាំងនឹងប្រទេសថៃ ដើម្បីជួយគាត់ធ្វើឲ្យប្រជារាស្ត្រខ្មែរបំភ្លេចអំពីការលំបាកខាងផ្នែកជីវភាព ដោយសារវិបត្តិសេដ្ឋកិច្ច អំពើពុករលួយ និងអសមត្ថភាពរបស់រដ្ឋាភិបាល ។

សំរាប់ប្រទេសវៀតណាមដែលជាអ្នកការពារគាត់

-បង្កើនពាណិជ្ជកម្មជាមួយប្រទេសកម្ពុជា និងបង្កើនឥទ្ធិពលសេដ្ឋកិច្ចលើប្រទេសកម្ពុជា

-បង្កើនការត្រួតត្រាមកលើសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា តាមរយៈការបង្កើនវិនិយោគពីប្រទេសវៀតណាម ដែលក្រុមហ៊ុនរបស់គេមានបុព្វសិទ្ធិលើសគេឯងនៅប្រទេសយើង នៅពេលដែលក្រុមហ៊ុនពីប្រទេសថៃកំពុងចុះថយ និងដកខ្លួនថយដោយសារភាពតានតឹងរវាងប្រទេសកម្ពុជា និងប្រទេសថៃ នាពេលបច្ចុប្បន្ននេះ ។ ស្ថានភាពបច្ចុប្បន្នធ្វើឲ្យយើងនឹកឃើញដល់កុប្បកម្មប្រឆាំងថៃនៅភ្នំពេញ ដែលរៀបចំឡើងដោយក្រុមអន្ធពាលបំរើលោក ហ៊ុន សែន កាលពីខែមករា ឆ្នាំ២០០៣ ។

មើលតាមទស្សនៈវិស័យប្រវត្តិសាស្ត្រ និងភូមិសាស្ត្រនយោបាយ ប្រទេសថៃ គឺជាគូប្រកួតដ៏សំខាន់របស់ប្រទេសវៀតណាម នៅជ្រោយឥណ្ឌូចិន ។ ដូច្នេះការធ្វើឲ្យប្រទេសថៃចុះទន់ខ្សោយ គឺជាការធ្វើឲ្យប្រទេសវៀតណាមទទួលបានផលប្រយោជន៍ក្នុងរយៈពេលយូរអង្វែងនាពេលខាងមុខ ។ ការវាតទីរបស់វៀតណាមនៅថ្ងៃណាមួយអាចទៅហួសឆ្ងាយជាងប្រទេសកម្ពុជា និងប្រទេសឡាវទៅទៀត ពីព្រោះប្រទេសទាំងពីរនេះស្ថិតក្រោមការត្រួតត្រារបស់វៀតណាមរួចស្រេចហើយនៅពេលនេះ ទោះច្រើនក្តី តិចក្តី ។ ដើម្បីធ្វើឲ្យប្រទេសថៃចុះទន់ខ្សោយ គ្មានអ្វីដែលមានប្រសិទ្ធភាពជាងការធ្វើឲ្យប្រជាជនថៃបែកបាក់គ្នាកាន់តែខ្លាំង ហើយគាំទ្រក្រុមមួយឲ្យប្រយុទ្ធប្រឆាំងក្រុមមួយទៀតនោះទេ ។ លោក ហ៊ុន សែន ជាឧបករណ៍ប្រើប្រាស់ដ៏មានប្រសិទ្ធភាព ដែលប្រទេសទី៣ កំពុងយកទៅប្រើក្នុងល្បែងដែលពោរពេញដោយល្បិចកលសំរាប់អនុវត្តផែនការដ៏ខ្មៅងងឹតមួយ ។ អ្នកណាក៏ដោយដែលយកខ្លួនទៅផ្សាភ្ជាប់ជាមួយលោក ហ៊ុន សែន ដើម្បីគាំទ្រដោយចេតនាក្តី អចេតនាក្តី នូវការអនុវត្តន៍ផែនការដ៏ខ្មៅងងឹតបែបនេះ គឺគ្រាន់តែធ្វើជាអាយ៉ងគេ ហើយត្រូវគេជំរុញឲ្យធ្វើសកម្មភាពប្រឆាំងនឹងប្រទេសខ្លួនឯង ។

នៅពេលដែលស្ថានការណ៍នៅតាមបណ្តោយព្រំដែនភាគខាងលិចរបស់យើង នៅអាចគ្រប់គ្រងបាននៅឡើយ ប្រទេសកម្ពុជា ជាដំបូងត្រូវខិតខំដោះស្រាយបញ្ហាមនុស្សធម៌មួយចំនួន ដូចជាជោគវាសនាពលរដ្ឋខ្មែរជាង២០ម៉ឺននាក់ ដែលបច្ចុប្បន្នកំពុងរស់នៅធ្វើការនៅប្រទេសថៃ ពីព្រោះគ្មានការងារធ្វើនៅប្រទេសកម្ពុជា ដោយសារបញ្ហាសេដ្ឋកិច្ច និងសង្គមដែលរដ្ឋាភិបាលលោក ហ៊ុន សែន មិនអាចដោះស្រាយបាន ។

ល្បែងនយោបាយដែលលោក ហ៊ុន សែន កំពុងតែលេងសព្វថ្ងៃ ពិតជាគ្មានប្រយោជន៍អ្វីដល់កម្ពុជាទេ ។ ផ្ទុយទៅវិញ ល្បែងនេះជាល្បែងគ្រោះថ្នាក់ ។ យើងមិនត្រូវអនុញ្ញាតឲ្យលោក ហ៊ុន សែន បន្តធ្វើឲ្យមានគ្រោះថ្នាក់ដល់សន្តិសុខប្រទេសយើងទេ ។ ប្រទេសកម្ពុជាត្រូវរក្សាអព្យាក្រឹត្យភាពនៅក្នុងជម្លោះផ្ទៃក្នុងរបស់ប្រទេសដទៃទៀត ។ ការរាលដាលណាមួយពីភាពតានតឹង ឬភាពច្របូកច្របល់នៅប្រទេសថៃ អាចធ្វើឲ្យខូចខាតដល់ប្រទេសកម្ពុជាយ៉ាងធ្ងន់ធ្ងរ ។ ការគិតខុសរបស់លោក ហ៊ុន សែន នៅពេលគាត់ចាក់ប្រេងលើភ្លើងនៅប្រទេសជិតខាងមួយនោះ នឹងនាំមកនូវផលអាក្រក់ ក៏លោក ហ៊ុន សែន អាចរេះដៃ និងរេះខ្លួន តែវាអាចលើសពីនេះទៀត គឺ ប្រទេសកម្ពុជាទាំងមូលអាចរេះសន្ធោសន្ធៅតែម្តង ដូចដែលបទពិសោធន៍ពីអតីតកាលបានបង្ហាញឲ្យឃើញស្រាប់ នៅពេលណាដែលយើងលូកដៃទៅកាន់ជើងភាគីជម្លោះម្ខាង ប្រឆាំងនឹងភាគីជម្លោះម្ខាងទៀតនៅក្នុងជម្លោះផ្ទៃក្នុង របស់ប្រទេសជិតខាងនោះ ៕

*ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៩*

សម រង្ស៊ី

អ្នកតំណាងរាស្ត្រ

ប្រធានគណបក្ស សម រង្ស៊ី

Continued from page 14

## Customs Official's Son Involved in...

early hours of Sunday morning.

"The shooting occurred inside the Rock nightclub in the early morning today, at 2:10 a.m., by the customs chief's son's group and caused at least one man to be injured," he said.

Municipal military police chief Roth Sreang said a Lexus SUV and an AK-47 assault rifle were seized from Mr. Sokheng's home later in the day but declined to say more because the case had been handed over to the municipal police "to find the suspects."

Municipal police chief Chuon Sovann could not be reached for comment.

A guard at the entrance of the gated community in Sen Sok district where Mr. Sokheng lives, who spoke on condition of anonymity out of fear for his safety, confirmed that the SUV had been seized and added that he did not see police take anyone into custody at the time.

"They only seized the car. I did not see police arrest the owner," he said, adding that he overheard police say that about 30 shots had been fired at the nightclub.

Neither police nor the National Police website provided information about the motive for the shooting, or the identity or condition of the victim.

Local television station BTV-controlled by Prime Minister Hun Sen's daughter-identified Mr. Sokheng's son as Keo Vitou, 24.

LOWELL ELDER CARE
978-596-1111

# មជ្ឈមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល

345 Chelmsford St. Lowell, MA 01851/ – www.lowelleldercare.com

### អ្វីទៅជាមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល?

គឺជាលំនៅដ៏កក់ក្តៅមួយ ដែលផ្តល់សេវាមានកម្មវិធីជាក់លាក់ដល់សហគមន៍បំណង គឺគាំទ្រឲ្យមនុស្សចាស់ជរាអាចរស់នៅដោយឯករាជ្យខ្លួនឯង និងជួយឲ្យមានសុខុមាលភាពផ្នែកផ្លូវកាយ ផ្លូវចិត្ត និងផ្នែកសង្គម ។ កម្មវិធីរបស់យើងធានានូវបរិស្ថានរស់នៅមួយប្រកបដោយសុវត្ថិភាព និងមានបរិយាកាសដូចជាផ្ទះរបស់ពួកគាត់ ។

### ទីតាំងនៃមណ្ឌល

ទីតាំងអាចរកឃើញដោយងាយក្នុងអគារថ្មី ជាមួយនូវការតុបតែងរចនាបែបសិល្បៈខ្មែរយ៉ាងល្អប្រណិត ។ មានបន្ទប់ទទួលទានអាហារស្អាត និងមានពន្លឺគ្រប់គ្រាន់ បន្ទប់អានសៀវភៅ បន្ទប់កុំព្យូទ័រ បន្ទប់សម្រាក បន្ទប់មើលភាពយន្ត និងកន្លែងផ្សេងៗទៀតជាទីពេញចិត្តរបស់លោកអ្នក ។





### មណ្ឌលផ្តល់សេវាដល់មនុស្សចាស់

- មានរថយន្តជូនដំណើរទៅវិញទៅមកពីផ្ទះលោកអ្នក
- ការពិនិត្យ និងថែទាំសុខភាព
- ការព្យាបាលតាមរយៈការហាត់ប្រាណ
- កិច្ចការសង្គម (ផ្តល់ការពិគ្រោះផ្ទាល់ខ្លួន និងក្រុមគ្រួសារ)
- ម្ហូបខ្មែរក្តៅៗ និងចំណីផ្សេងៗ
- ការហាត់ប្រាណសំរាប់សុខភាពរាងកាយ
- កម្មវិធីសិល្បៈ និងតន្ត្រី
- ការអប់រំពីសុខភាព
- ការពិភាក្សាលើព្រឹត្តិការបច្ចុប្បន្ន (និងការសំណេះសំណាលគ្នា)
- សកម្មភាព និងដំណើរកំសាន្តក្រៅមណ្ឌល

### Our Services

- Door-to-Door Transportation
- Medical Care and Support
- Physical Therapy
- Social Worker
- Khmer Meals and Snacks
- Adaptive Physical Exercise
- Music Programs
- Health Educational Seminars
- Discussions on current events, (and times of reminiscing)
- Outdoor Field Trips

សូមហៅលេខទូរស័ព្ទ (978) 596-1111

KhmerPost USA

The Cambodian-American Biweekly Newspaper

សារព័ត៌មានខ្មែរ-អាមេរិក ចេញពីរសប្តាហ៍ម្តង

a free local newspaper reaching over 20,000 Cambodian readers in the Greater Lowell area every two weeks

ផ្តល់ជូនកាសែតឥតគិតថ្លៃដល់អ្នកអានខ្មែរច្រើនជាង២០០០០នាក់នៅតំបន់ឡូវែលរាល់ពីសប្តាហ៍ម្តង

Soben Pin, Managing Partner អ្នកគ្រប់គ្រង សុបិន្ត ពិន

978.677.7163 (Office) 978. 656.8141 (Mobile)

សូមកក់ពាណិជ្ជកម្មអ្នកជាមួយយើងខ្ញុំ ហើយទទួលបានការបញ្ចុះតម្លៃ២០%

Reserve Your 2015 Ads with us today and receive up to 20% OFF!

Sample of our affordable pricing បញ្ជីតម្លៃពាណិជ្ជកម្មក្នុងតម្លៃសមរម្យ

| ទំហំទំព័រ<br>Page Size | ប្រវែង<br>Length x Width | 1ខែ<br>1 month<br>10%OFF |
|---|---|---|
| 1/2 page color | (6.5"x10") | $484 |
| 1/4 page color | (6.5"x5") | $264 |
| 1/8 Classify ad | (3.25"x5") | $100 |
| Business Card | | $50 |

Our 2015 Publishing Dates កាលវិភាគបោះពុម្ព

| | |
|---|---|
| April | 3rd & 24th |
| May | 1St & 22nd |
| June | 5th & 26th |

*all ad materials are due one week prior to publishing date

រាល់គំរូពាណិជ្ជកម្មត្រូវបញ្ជូន1សប្តាហ៍មុនចូលរោងពុម្ព




Call or Visit our Sales Office

45 Merrimack Street. Suite 218A. Lowell, MA 01852

Tel: 978.677.7163. Cell: 978. 656.8141 Fax: 978.677.7092

Email: sobenpin@khmerpost.us or KhmerPostUSA@gmail.com

www.khmerpost.us | www.facebook.com/KhmerPostUSA



# សួស្តីឆ្នាំថ្មី



# HAPPY NEW YEAR

## 2015 - YEAR OF THE GOAT

**SATURDAY APRIL 4, 2015**
**9:00 AM - 3:00 PM**

## ចូលរួមដោយឥតគិតថ្លៃ

សូមអញ្ជើញចូលរួមអបអរបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរ
ដើម្បីលើកស្ទួយវប្បធម៌ និង ទំនៀមទម្លាប់ខ្មែរ។

## FREE ADMISSION

You're invited to the 6th annual Cambodian New Year Celebration to honor traditional Khmer Arts and Culture.

## FREE FOOD AND CULTURAL PERFORMANCES!

LOWELL SENIOR CENTER 276 BROADWAY ST., LOWELL, MA 01854
CONTACT INFO BUNRITH SATH - 978.452.7523 x809




C.B.A
LOWELL COMMUNITY HEALTH CENTER
LOWELL ELDER CARE
THE LOWELL ALLIANCE FOR FAMILIES AND NEIGHBORHOODS
LOWELL POLICE MA